# បណ្ដាំក្រមង៉ុយ



បោះពុម្ពផ្សាយដោយអង្គការសន្តិស្ម័គ្រចិត្តកម្ពុជា ( អេស វី អេ )

ភ្នំពេញ

ព.ស ២៥៤៩ - គ.ស ២០០៥

# ច្បាប់ល្បើកថ្មី

អ្នកព្រះភិរម្យ ភាសាអ៊ូខ្ញុំ បង្គំនឹកគុណ
ព្រះពុទ្ធព្រះធម៌ ព្រះសង្ឃជាមុន គុណគាប់មហាធ្ងន់
មាតាបិតា ។

ឧបជ្ឈាយ៍ជាធំ កាលចាប់ដៃខ្ញុំ ឱ្យធម៌កេសា
អនុសាវន ព្រះកម្មវាចា គុណតួអក្ខរា
ទាំងសាមសិបបី ។

ខែចេត្រឆ្នាំច ចត្វាស័កក កគិតកាព្យថ្មី
លើកច្បាប់ប្រដៅ កូនចៅប្រុសស្រី តូចក្តីធំក្តី
ចូរស្តាប់គ្រប់គ្នា ។

ដ្បិតមនុស្សឥឡូវ យកខុសជាត្រូវ យកឆ្កួតធ្វើជា
អំពើអាក្រក់ ឡិកឡក់លីលា ព្រហើនពានពារ
អាងមាសអាងប្រាក់ ។

៥- អាងព្រើលអាងប្រាជ្ញ អាងកោងអាងកាច អាងកាប់អាងចាក់
អាងជើងអាងដៃ អាងវាយអាងធាក់ អាងគុកច្រវាក់
អាងម៉ាស៊ីនកាត់ក ។

អាងសុទ្ធតែខុស កូនអើយចាំចុះ អាងនោះមិនល្អ
អ្នកគិតឱ្យល្អិត ដ្បិតស្រុកលោកក្រ ប្រមាណតំណ
តទៀតទៅមុខ ។

សាសនានៅឆ្ងាយ លែងបានសប្បាយ មានតែកើតទុក្ខ
កើតទាន់លោកីយ៍ ឮតែទំនុក ដំណែលអាពុក



Websites: WatKhmers.org or WatKhemaraRatanaRam.org

ចូរចាំគ្រប់គ្នា ។

អ្នកជឿពាក្យចាស់ ជឿចាំឱ្យណាស់ កុំធ្វើបំពារ
អ្នកហ៊ានស្បែកដាច អ្នកខ្លាចស្បែកជា មនុស្សចោរប៉ោបៀ
កុំយកខ្លួនបៀត ។

ឃើញឫកគេល្អ ទោះបីមានក្រ យកគេជាញាតិ
គួររាប់អ្នកក្រៅ ផៅអ្នកឯទៀត រាប់រើសមារយាទ
សុចរិតត្រឹមត្រូវ ។

១០- រៀនបទរៀនបាទ កុំកោងហួសខ្នាត កុំភ្លាត់ហួសផ្លូវ
កុំភ្លើនភ្លេចម៉ែ កុំប្រែហួសឪ ឃើញចាស់សក់ស្កូវ
កុំសូវមើលងាយ ។

បន្ទន់អាត្មា ខ្លាចមេខ្លាចបា ខ្លាចតាខ្លាចយាយ
បម្រើមហាក្សត្រ ប្រយ័ត្នស្ដេចទាយ ពាក្យពិតទំនាយ
រលាយកេរ្តិ៍ឈ្មោះ ។

ពាក្យស្ដេចពាក្យគ្រូ មានប្រែមានជូរ កម្រពីរោះ
ជូនទាយឱ្យទាប ជូនទាយឱ្យខ្ពស់ ទាយឱ្យសក្តិយស
ទាយចុះកុំខឹង ។

បម្រើមើលភេទ ចំណាំព្រះនេត្រ ហេតុខ្លួនឱ្យដឹង
ខ្លួនខ្ជិលហែព្រើល លោកមើលសំឡឹង សំឡក់ឱ្យប្រឹង
ខំប្រិតសូត្ររៀន ។

បម្រើមើលពុត ប្រាជ្ញាឱ្យមុត ស្មារតីឱ្យមាន
បើខ្លៅឱ្យប្រាជ្ញ បើខ្លាចឱ្យហ៊ាន ចង់បានរបៀន



Websites: WatKhmers.org or WatKhemaraRatanaRam.org

កុំអៀនកុំខ្មាស ។

១៩- ពុតលោកជាធំ ជ្រៅជ្រៅប៉ុនភ្នំ ឯងមើលមិនច្បាស់
បម្រើលោកណា លោកហ្នឹងជាម្ចាស់ លោកស្អប់អ្វីណាស់
ប្រាសចោលឱ្យឆ្ងាយ ។
កុំឈមឈរជិត កុំយកធ្វើមិត្រ ភ្ជាត់ខ្លួនអន្តរាយ
បើប្រពន្ធកូន បងប្អូនចៅហ្វាយ អាពុកឬម្ដាយ
ឱនកាយប្រតិបត្តិ ។
អ្នកកុំមើលងាយ ឃើញគេរីករាយ ព្រួញខ្លួនប្រយ័ត្ន
ត្រកូលញាតិផៅ កូនចៅមហាក្សត្រ ស្មើថ្លើមប្រមាត់
ប្រមាថមិនបាន ។
ទោះអ្នកដទៃ អ្នកព្រៀងអ្នកព្រៃ ដែលលោករាប់អាន
កុំថាតែមនុស្ស ទោះសត្វតិរច្ឆាន ឯងស្អប់ប៉ុន្មាន
កុំហ៊ានប្រមាថ ។
របស់ឬទ្រព្យ ដែលជាសំអប់ កុំបាច់សំអាត
ទ្រព្យណាសំឡាញ់ អស់អញឱហាត ចូរចៅសង្វាត
ជួយថែរក្សា ។

២០- កុំជិះជុំជាន់ ស្មៅផ្ទីអាចម៍មាន់ ពាក្យចាស់ឧបមា
បុរាណហៅផ្ទី ពីរបីប្រការ កុំស៊ីត្រង់ណា
ជុះដាក់ត្រង់ហ្នឹង ។
សាច់សាលោហិត កុំផ្ដួលផ្ដេកផ្ដិត ផ្ដួចទោសកើតប្ដឹង
អាពុកផ្ដែផ្ដាំ ចូរចាំចេះថ្ងឹង សាច់ថ្លើមស្ងួតឆ្អឹង



Websites: WatKhmers.org or WatKhemaraRatanaRam.org

និងស្បែកខាងក្រៅ ។

សាច់សួតក្នុងខ្លួន ទុកស្មើបងប្អូន ប្រពន្ធកូនចៅ
សរសៃនិងស្បែក ចែកជាញាតិផៅ ខ្ញុំស្រីខាងក្រៅ
ជាស្មៅអាចម៍មាន់ ។

ស្រីខ្ញុំកំដរ បើឃើញរូបល្អ កុំលលូកលាន់
កុំលួចលបលេង ក្រែងម្ចាស់គេទាន់ កុំកប់កុំកាន់
អាប់អន់អាត្មា ។

បើអ្នកមានយស មានសក្តិខ្ពង់ខ្ពស់ គាប់នឹងរាជការ
ធ្វើធំធ្វើថី មន្ត្រីមានត្រា ព្រះហ្លួងឧកញ៉ា
សាលាកុង្ស៊ុយ ។

២៥- ចេះច្បាប់បារាំង កុំភ្លេចសច្ចំ កតញ្ញូ ខន្តី
កុំធ្មើងហួសមាឌ ភ្លេចញាតិប្រុសស្រី ជំនុំកាត់ក្តី
យកឧបេក្ខា ។

កុំកាន់សីហលោ កុំកាន់លោភោ ទោសោមោហា
កុំជក់អាភៀន កុំឃ្លានផឹកស្រា កុំស្អប់ខាងណា
សច្ចាយកត្រង់ ។

លួងលោមពិសោធ កុំធបញ្ឆោត បញ្ចូលឱ្យបង់
ឱ្យបែកឱ្យបាក់ ពាក្យសត្យពាក្យសង្ឃ កូនអើយផ្ចិតផ្ចង់
តម្រង់ស្មារតី ។

កុំភ្លើនឃើញប្រាក់ កុំភ្លើភ្លាត់សក្តិ ធ្លាក់ទៅអវិចី
កាន់ធម៌ទសពិធ រីតឡើងរាសី គាប់ពីលោកិយ៍



Websites: WatKhmers.org or WatKhemaraRatanaRam.org

ដល់បរលោកនាយ ។

អ្នកក្តីជាភ្លើង កុំកាត់កាន់ជើង អ្នកម្ខាងមើលងាយ
ចៅក្រមជាទឹក រំពុករំលាយ កុំជេរកុំវាយ
បង្ខំនាំខុស ។

៣០- ចោរខូចលួចប្លន់ រឺចោរស្ម័គ្រស្មន់ តណ្ហាស្រីប្រុស
កុំស្អប់ខាងណោះ បញ្ជោះខាងណោះ លួងលោមបញ្ចុះ
បញ្ចូលចិត្តក្តី ។

កុំដុតឱ្យក្តៅ បើឃើញគ្នាខ្លៅ ប្រាជ្ញាគ្នាខ្លី
កុំឃ្លានប្រាក់ប្រុស បន្ទុះខាងស្រី បើកាន់ច្បាប់ថ្មី
កុំចោលច្បាប់ចាស់ ។

កុំដៀលអ្នកស្រែ ត្រកូលឯងខ្មែរ កុំប្រែក្រឡាស់
ក្រឡេកឃើញគុណ ទន់ខ្លួនសំពះ កុំធ្វើអ្នកណាស់
កុំត្មះអ្នកក្រ ។

អ្នកកុំភ្លេចគុណ គ្រូលេខនព្វន្ត គ្រូសូត្រអក្សរ
កុំចាប់ដៃទាញ គំនាប់ផក់ក កុំជដៃកត
ស្មើមិត្រសំឡាញ់ ។

រាស្ត្រត់ចូលជ្រក សួរសោកទៅមក កុំអើងឯងអញ
ពាក្យពុំពីរោះ គេកើតមួក្នាញ់ គេដៀលផ្ដាលផ្ដាញ់
អន្តរាយកេរ្តិ៍ឈ្មោះ ។

៣៥- កុំឆ្មើងអាងបុណ្យ ស្រដីឱ្យទន់ ពោលពាក្យពីរោះ
ខ្លួនអ្នកនឹងថ្កើង នឹងឡើងសក្តិយស កុំឆ្មៀតនាំឈ្មោះ



Websites: WatKhmers.org or WatKhemaraRatanaRam.org

ញុះញង់អ្នកធំ ។
កុំស្អប់អ្នកតូច បើឃើញគ្នាខូច គួរគិតប្រមុំ
ទោសគ្នាតិចតួច ផ្ដួចឡើងជាធំ ផ្សែងពូតជាដុំ
ផ្ទុំឆេះជាភ្លើង ។
កុំភ្លើនភ្លេចខ្លួន បេះសាសន៍ចិនយួន កុំចោលខ្មែរយើង
កុំធ្វើក្រអឺត កុំពើតកុំពើង កុំពាក់ស្បែកជើង
ចូលវត្តលោកសង្ឃ ។
ដោះមួកដាក់ឆត្រ ឱនកាយប្រតិបត្តិ លំអុតឱនអង្គ
កុំស៊ីតាមឃ្លាន កុំហ៊ានតាមចង់ កាន់ច្បាប់ស្រុកហ្រ្វង់
កុំបង់សាសនា ។
កុំចង់ថ្កើងពេក កុំលើកដំណោក ហួសមេហួសបា
តែងខ្លួនឱ្យល្មម មើលពូជពង្សា សង្វេបនិដ្ឋិតា
រឿងផ្គាប់បុណ្យសក្តិ ។
៤០- បើទៅជារាស្ត្រ ប្រាជ្ញាវៃឈ្លាស គួរវាសធ្វកធ្វាក់
ឱ្យធ្មៀតវែកពុន បើធ្វូន់សុំដាក់ ខំរកមាសប្រាក់
ឱ្យគ្រាន់ទាន់ចាយ ។
រាជ្យបារាំងសែស កូនកុំប្រហែល កុំថ្នមរូបកាយ
ដើរគិតដេកគិត ជួញជិតជួញឆ្ងាយ បើចង់សប្បាយ
ស្រេចនៅមានទ្រព្យ ។
រាជ្យហ្វូង់ពីមុន រកស៊ីវែកពុន មានក្រតាមភ័ព្វ
រាជ្យលោកឥឡូវ ត្រូវខំឱ្យញាប់ តែខ្ជិលច្រើនដាប់



Websites: WatKhmers.org or WatKhemaraRatanaRam.org

ខ្មោះជើងខ្មោះដៃ ។
តាំងពីផ្ទាំច ចាំជាតំណ ទំនិញឡើងថ្លៃ
ចង់ក្បិនឱ្យតឹង ប្រឹងកុំសំចៃ សញ្ជឹងយប់ថ្ងៃ
កុំឱ្យក្រខ្សត់ ។
បើចង់ស្រាលខ្លួន រៀនសូត្រឱ្យមួន ឱ្យមាំឱ្យស្ទាត់
កុំចេះស្ទាក់ស្ទើរ ល្ងីល្ងើឥតបទ បើចេះប្រាកដ
ប្រាក់វត់តាមហៅ ។
៤៩- កុំថ្នមកម្លាំង កាប់ជីកចូកចាំង កុំថារងាក្ដៅ
រៀនអ្វីឱ្យឆ្អិន កុំឱ្យខ្ចោចឆៅ កុំដេកតែខ្ជៅ
ក្រក្រៅសណ្ដាប់ ។
បើល្ងង់ឱ្យចេះ រករៀនតម្រិះ រិះរកតម្រាប់
ឥន្ទ្រីយ៍ឆ្វេងស្ដាំ កុំចាំគេប្រាប់ រៀនស្ដីរៀនស្ដាប់
រៀនមើលឱ្យស្ដែង ។
កើតមកជាមនុស្ស ទាំងស្រីទាំងប្រុស មិនដែលចេះឯង
បើក្រឱ្យមាន វិញ្ញាណចេះក្រែង គិតគ្រប់កន្លែង
កុំដេកតែក្រ ។
កុំប្លន់កុំលួច កុំខ្ជិលកុំខ្ជួច កុហកឆ្ងវឆ
បោកប្រាសយកប្រាក់ ប្រវ៉ាក់ជាប់ក កាន់មារយាទល្អ
សុចរិតត្រឹមត្រូវ ។
កូនអើយរកស៊ី កកាយធរណី ធ្វើស្រែយកស្រូវ
កុំតាមអ្នកណា បាតាមតែឪ លើកភ្ជួរជិតផ្លូវ



Websites: WatKhmers.org or WatKhemaraRatanaRam.org

កុំស្រាស់បន្ទា ។
៥០- គេដើរយប់ថ្ងៃ    មុតជើងមុតដៃ    ដឹងចៀសទៅណា
ចៀសចុះដាន់ស្រូវ    ហើយដេរផ្ដាសា    កូនម្ដាយអាណា
ស្រាស់ដើរមិនរួច ។
កុំយកគល់ឈើ    ទៅដាក់ពីលើ    ទោះធំទោះតូច
ជំពប់ជើងគេ    គេថាឯងខូច    ដេរដៀលដល់ពូជ
ប្រដូចមេបា ។
លើកភ្លឺឱ្យធំ    បង្ហាប់ឱ្យមាំ    គាប់ភ្នែកទេវតា
ស្មើបានសង់ស្ពាន    នឹងមានផលា    កើតសាធុការ
អាយុយឺនវែង ។
កូនអើយធរណី    បើតាមគម្ពីរ    ដែលលោកសំដែង
កុំចង់បានធំ    ប្រមុំឆ្មៀលឆ្វែង    កុំលើកដីឯង
លបដាក់ស្រែគេ ។
អំពើអាក្រក់    មួយចំរៀកសក់    ធ្លាក់ទៅនិរយេ
បច្ចុប្បន្នលោកីយ៍    កើតក្ដីវាយដេរ    មិនដែលសុខទេ
ព្រោះដីមួយហត្ថ ។
៥៥- កុំជួញចង់ទាស់    ខូចខាតរបស់    អស់ទ្រព្យសម្បត្តិ
ចង់គង់ប្រយោជន៍    ឱ្យចេះប្រយ័ត្ន    ពាក្យឪមួយម៉ាត់
ឱ្យគិតមួយម៉ោង ។
សំអាតផ្ទិតផ្ទង់    លើកភ្លឺឱ្យត្រង់    កុំលើកឱ្យកោង
អ្នកកុំប្រហែស    ក្រែងមានប្រហោង    លើកមើលទំនង



Websites: WatKhmers.org or WatKhemaraRatanaRam.org

ទំនាបទឹកហូរ ។

ចំនួនទឹកស្អឹង ទឹកព្រែកទឹកបឹង ទឹកវាលទឹកអូរ
អ្នកលើលិចស្រូវ ត្រូវបើកបង្ហូរ អ្នកក្រោមកុំថ្ងូរ
បន្ទូរហួសទៅ ។

រាំងរើងថ្ងៃយប់ ធាប់លើកធាប់ទប់ កុំឱ្យបាក់ជ្រោ
កត្តិកចេញខ្យល់ តម្កល់ទឹកនៅ បើចង់បានស្រូវ
ស្រេចនៅត្រឹមថៃ ។

កុំយកគ្រាប់ត្នោត ទៅដាំទៅដោត ពីលើភ្លឺស្រែ
ចិត្តគិតប្រមាណ ចង់បានផ្កាផ្លែ ដាំដុះបង្អែ
បង្អិនខ្លួនឯង ។

៦០- ដល់ត្នោតឡើងគល់ ឡើងកើតនាំខ្វល់ ធាងលូតឡើងវែង
ភ្ជួរពាស់ជាប់នឹម ក្របីជាប់ស្នែង ទទើសទទែង
ភ្ជួរឆ្វេងមិនត្រូវ ។

ដល់ត្នោតវាធំ មានស្លឹកវាទុំ វាជ្រុះក្នុងស្រូវ
ស្រែឆ្ងាយពីផ្ទះ ឃ្លាតណាស់ពីផ្លូវ ទំរាំតែទៅ
រលួយស្រូវអស់ ។

កូនអើយកុំធោត បើចង់បានត្នោត ដាំដោយកៀនកោះ
ដីទូលចំការ ឯណាចន្ទោះ ដាំជារបោះ
ជាយជួររបង ។

របៀបចំការ ថៃទាំរក្សា យូរៗស្រាស់ម្ដង
ស្រាស់ឱ្យត្រូវជួរ មើលគួរសមផង កុំបើកមុជឆ្វង



Websites: WatKhmers.org or WatKhemaraRatanaRam.org

ទៅស្រាស់ខាងក្រៅ ។

មិនគាប់ប្រសើរ របងវាដើរ អ្នកម្ខាងវាក្ដៅ
កើតក្ដីកើតក្ដាំ អស់ខោអស់អាវ ទឹងអស់ញាតិផៅ
ពីព្រោះចំការ ។

៦៩- មួយទៀតរបង ជិតផ្លូវអ្នកផង គេទៅណាៗ
ធ្វើឱ្យទូលាយ កុំរាយបន្ទា កាប់គ្នុះទាត់ធ្នារ
ឱ្យឆ្ងាយពីផ្លូវ ។

កុំធ្វើចង្អៀត ក្រែងយប់អធ្រាត្រ ខ្លះមកខ្លះទៅ
ចៀសគ្នាមិនរួច បើកបរកាត់ស្រូវ ដេរម្ដាយតាមផ្លូវ
រហូតដល់ផ្ទះ ។

កូនអើយអ្នកចាំ អ្នកកុំចងកម្ម មានពៀរច្រើនណាស់
ជាតិក្រោយខ្វាក់ខ្វិន កខ្វេះកខ្វាស សូវបោលដីខ្លះ
មិនខាតប៉ុន្មាន ។

កុំខ្វាចតែត្រ ធ្វើឫកមិនល្អ ច្រើនកើតវឱស្ថាន
វអែករអោក បាត់ញាតិសន្ដាន ឥតគេរាប់អាន
មានតែគេស្អប់ ។

កាន់ឫកឱ្យខ្ពស់ ឱ្យខ្ពើមពាក្យឈ្មោះ ទើបបានជាគាប់
យកឆោតដាក់ខ្លួន ច្រើនមានគេរាប់ បើខ្លួនឥតទ្រព្យ
កុំផ្ទាប់ហ៊ានខ្វី ។

៧០- គ្រប់ការសារពើ ចង្កើរកញ្ចើ កន្ដាំងតៅល្អី
វនាស់វទេះ គោសេះក្របី បើបានជាខ្ចី



Websites: WatKhmers.org or WatKhemaraRatanaRam.org

ខ្ចីប្រាក់គេទិញ ។

យកមករកស៊ី ខែមួយខែពីរ សងប្រាក់គេវិញ
របស់បានយើង ជាដើមដួញចេញ ឯទ្រព្យនោះមិញ
ពេញជាទ្រព្យឯង ។

កុំខ្ចីគេប្រើ តែមួយដំណើរ មិនយូរអង្វែង
ជួនជាបាក់បែក ដដែកទាស់ទែង សងគេមិនលែង
ចាស់ផ្លាស់ជាថ្មី ។

កើតមកជាប្រុស គិតឱ្យសព្វសុស កុំឱ្យសល់អ្វី
បួសរៀនធម៌អាថ៌ សាស្ត្រាបាលី បរលោកលោកីយ៍
កុំបីចន្លោះ ។

សឹកមករកស៊ី កកាយធរណី ធ្វើជាគ្រហស្ថ
កុហកជឿបុល បំណុលរុំកោះ ច្រើនគេដាក់ខ្នោះ
អស់ស្រែចំការ ។

៧៥- ធ្វើពាស្ត្ររកស៊ី ចិញ្ចឹមគោញី ថែទាំព្យាបាល
ក្រហេតុពីខ្ជិល មានត្បិតឧស្សាហ៍ អ្នកមានប្រាជ្ញា
មិនស្មើគំនិត ។

កំណើតសំណាង សំណូមសូមសាង កកើតពីគិត
ពីកាលជាតិមុន បុណ្យព្រេងអតីត កើតរូបគំនិត
ទើបកើតសំណាង ។

ឯមនុស្សសំណល់ ល្ងង់ល្ងើងឿងឆ្ងល់ ទាស់ទែងក្អេងក្អាង
ដប់ឆ្នាំនេះហើយ ប្រកាន់ម៉្យាងៗ ខ្វះអួតសំណាង



Websites: WatKhmers.org or WatKhemaraRatanaRam.org

ខ្វះអាងគំនិត ។

កូនចៅប្រុសស្រី រកប្រពន្ធប្តី ឱ្យរកស្រុកជិត
បើរកស្រុកឆ្ងាយ ឱ្យម្តាយពិនិត្យ ឱ្យត្រឹមត្រូវពិត
ពូជពង្សរាវតារ ។

កូនអើយអ្នកចាំ កុំជឿខែឆ្នាំ កុំជឿតម្រា
ពាក្យក្បួនតម្រាយ កើតពីមនុស្សចារ ពីដូនពីតា
ចារតាមសម្គាល់ ។

៨០- អ្នកជឿតែពូជ អម្បូរធ្លាប់ខូច វាខូចរៀងរាល់
ពូជមានវាមាន ពូជទាល់វាទាល់ កុសលអកុសល
យើងមើលមិនដាក់ ។

ប្រពន្ធនិងប្តី អាយុវែងខ្លី យើងមើលឃើញច្បាស់
កុំយកពូជល្បែង ពូជក្មេងអារក្ខ បើម៉្វៃបង់ប្រាក់
រកអាយុវែង ។

អម្បូរពង្សពូជ ត្រកូលធ្លាប់ខូច វាខូចមិនលែង
ពូជចោរស្រីៗ យកប្តីចិត្តឯង មិនគិតកោតក្រែង
ខ្វាចចិត្តមេបា ។

កូនចៅស្រីៗ បើនឹងយកប្តី ឱ្យមើលកិរិយា
មួយក្មេងអារក្ខ មួយអ្នកបាណា មួយអ្នកផឹកស្រា
មួយអ្នកចងស្រី ។

មួយអ្នកក្រមាច់ លេងផោមលេងអាចម៍ អាយុច្រើនខ្លី
ប្រកាច់ដាច់លក្ខណ៍ ដាន់អារក្ខព្រៃ មួយគឺមន្រ្តី


Websites: WatKhmers.org or WatKhemaraRatanaRam.org

ផ្ញើក្រមជំទប់ ។

៨៩- ជំទយតែដើរ មេស្រុកគេប្រើ ទាំងថ្ងៃទាំងយប់
មានម្ចូកខ្វះធត្រ កម្រមានគ្រប់ មួយទៀតកុំកប់
ជួញប្រាំប្រការ ។
ប្រាកដជាខុស លក់សត្វទាំងរស់ មិនចេះអនិច្ចា
សព្វសត្វអ្វីៗ បក្សីបក្សា ព្រាត់មេព្រាត់បា
ទេវតាលោកលក់ ។
លោកិយ៍នេះខ្សត់ យម្មបាលគេកត់ នៅស្ថាននរក
មួយហួយអាប៉ោង ប៉ោបៀគ្រប់មុខ កូនអើយចាំទុក
ក្រគ្រប់ប្រាំបី ។
ឯអ្នកទាំងអស់ រកស៊ីម៉េះម៉ស់ ច្រើនជាងស្រីៗ
ប្រាជ្ញានោះវែង គំនិតនោះខ្លី ប្រពន្ធជេរស្តី
អាងឈ្មោះបំពាន ។
នេះពូជអ្នកក្រ រស់ទាំងត្រដរ ទាំងអត់ទាំងឃ្លាន
ធ្វើគុណនឹងគេ រកគេសង់គ្មាន ហេតុនេះកុំរៀន
ទាំងប្រាំបីផ្លូវ ។

៩០- យ៉ាងអ្នកនេសាទ មិនដែលសង្វាត ធ្វើស្រែបានស្រូវ
ប្រព្រឹត្តសាងកម្ម ប្រចាំរដូវ វង្វេងសុខត្រូវ
ព្យាយាមសម្លាប់ ។
អន្ទាក់ជង់កុក អង្រ្គុតឈ្នាងឈ្នក់ គ្រប់គ្រឿងប្រដាប់
ថ្នុកបៀត្រពាំង ទប់បាំងបាចចាប់ ចោលស្រូវកណ្តាប់



Websites: WatKhmers.org or WatKhemaraRatanaRam.org

កណ្ដៀវកាត់អស់ ។

កំពប់ខ្វាត់ខ្វាយ ខូចខាតអន្តរាយ មិនស្ដាយស្រណោះ
យប់រវល់ប្រុបកំ ចង់បានត្រីរ៉ស់ ខែភ្ញីរវល់ធ្នុះ
ដើរដេញសំពោច ។

វក់តែសប្បាយ ដើរដេញទន្សាយ ដើរចង់សន្ទូច
អំពើអស់នោះ ច្រើនខ្វះស្រូវពូជ ធ្វើបានតិចតួច
អាង់ជឿគេស៊ី ។

កូនអើយបំណុល ចង់ការជឿបុល មួយឡើងជាពីរ
អ្នកក្មេងអារក្ខ ច្រើនទឹមគោញី ធ្វើស្រែមួយពីរ
ធ្វើសោះតែខាន ។

៩៥- ថ្ងៃដេកក្រភ្នាក់ យប់លៀងអារក្ខ ឈើធ្លាលសន្ទាន
គេស្ដីគេពឹង នឹងឈប់ពុំបាន គេរករាប់អាន
កាលមានធុរៈ ។

ផ្ទុំប៉ុក្ងូតទ្រ ស្រែកច្រៀងវាយស្គរ មិនបានលុយកាក់
ឯងពឹងគេវិញ គេគ្មានជំពាក់ ពឹងបានម្នាក់ៗ
ដោយសារឱ្យថ្លៃ ។

ឡើងត្នោតគួរស្រែ កម្រទាន់គេ ដ្បិតដេកដល់ថ្ងៃ
ច្រូតកាត់ចង់ធាប់ ជួលគេពេញថ្ងៃ ចំណោះចង្រៃ
នាំខាតធ្វើការ ។

ឯខ្មោចអារក្ខ ស្លាប់ជប់រស់ម្នាក់ ថ្វាយចេកថ្វាយស្រា
សំពះនឹកគុណ ខ្មោចប្រេតជូនតា មិនដែលអ្នកណា



Websites: WatKhmers.org or WatKhemaraRatanaRam.org

នឹកគុណអ្នកភ្លេង ។

ឯអ្នកប្រមឹក ប្រមូលកនផឹក ធ្វើភ្លៀននឹងក្មេង
សំដីច្រើនតឹង ស្រវឹងវង្វេង ជំហរអួតក្អេង
មិនចេះក្រខ្សត់ ។

១០០- អួតទាំងបំពាន ផឹកម៉្ងៃលុយមាន ផឹកម៉្ងៃលុយអត់
ឯងចេះតែកិន ចិនចេះតែកត់ ផឹកដល់កំណត់
យកស្រែបញ្ចាំ ។

សល់ថ្នាលមួយពីរ វាយគោស្ទោរស៊ី មិនគិតខ្លាចកម្ម
ផឹកជ្រុលហួសល្បត់ អត់បាយរាប់ឆ្នាំ អស់ស្រែបញ្ចាំ
បញ្ចាំកូនទៀត ។

កំណើតផឹកស្រា ផឹកផុតមេត្តា ផឹកជ្រុលហួសមាឌ
អ្នកមួយផឹកស្ទើរ ល្វីល្វើចេះឆ្ងៀត ម៉្យាងផឹកផុតមារយាទ
ច្រើននៅខ្ញុំចិន ។

រែកទឹកពុះខុស វាទុញវាតុះ ចាក់កែវផឹកសិន
ស៊ូរែកខំអត់ សំពត់ខើចក្បិន ទំពាំបាយឆ្អិន
ចិនដួសហៅស៊ី ។

ឆ្ងាញ់តែម្នាក់ឯង ឆ្អែតហើយខំស្វែង ខំលើកខំលី
ដងទឹកស្រោចគ្រប់ ស្រោចខ្ទឹមម្ទេសជីរ ខ្ញុំចិនម្ង៉ៃពីរ
វិលទៅរាំងផ្ទះ ។

១០៥- ឯអ្នកចង់ស្រី ប្រពន្ធពីរបី ថាឯងអ្នកណាស់
គន់ឯសំពត់ តែមួយបន្ទាស់ ពាក់អាវបំណាស់



Websites: WatKhmers.org or WatKhemaraRatanaRam.org

កម្រមានថ្មី ។

ផ្ទះលេចវាលល្វឹង ជញ្ជាំងចង់ហ៊ឹង ស្វាជ័រឋាយសី
ខ្ជួចប្រេងក្រមួន ម្ទូស្វាបារី កំលោះពីរបី
ចោមរោមរៀនស្នេហ៍ ។

រៀនស្ទាលវេនស្និទ្ធ កើតក្ដីពីក្ដិត ព្រួយចិត្តឪម៉ែ
កូនអើយប្រពន្ធ អាងមន្តពូកែ ត្រូវគុក១០ខែ
អស់ស្រែត្រពាំង ។

ជម្ទាតាប្រពន្ធ បានដោយសិល្បមន្ត ដោយស្វាត់កំបាំង
រកស៊ីលៀនភ្នែក បានវែងខ្វះផ្ទាំង បានល្អឹកន្ទាំង
នៅខ្វះចង្អេរ ។

បាននេះខ្វះនោះ ក្រហេតុពីព្រោះ អាពុកម្ដាយជេរ
បើចូលជំនុំ មិនរម្យដូចគេ អង្គុយវេះវេរ
មិនហ៊ានហាលមុខ ។

១១០- នេះពុតអ្នកក្រ ចាំជាតំណ តជាទំនុក
ប្រយ័ត្នជំនៀល គេជៀលអាពុក កូនអើយចាំទុក
ចាំតកូនចៅ ។

រក្សាពូជពង្ស បើខ្លួនល្ងឹតល្ងង់ ស្ដាប់ចាស់ប្រដៅ
កុំស្អប់អ្នកប្រាជ្ញ កុំខ្លាចអ្នកខ្លៅ បើមនុស្សឆោតឆៅ
កូនឯងកុំភប់ ។

កុំភ័យខ្លាចអត់ មើលឱ្យប្រាកដ គួរយកគួរឈប់
គួរឈានគួរឈោង តោងមើលឱ្យគ្រប់ កុំចេះតែងប់



Websites: WatKhmers.org or WatKhemaraRatanaRam.org

មិនស្ដាប់ឪម៉ែ ។

រកប្ដីប្រពន្ធ ឱ្យគិតឱ្យគន់ ឱ្យមើលថ្ងូនថៃ
ត្រកូលក្រខ្សត់ ប្រាកដតាមខ្សែ បីដូចឈើផ្លែ
មិនដែលចេះក្លាយ ។

ដូវផ្អែមជំតូច ដើមក្រូចផ្លែក្រូច ដើមស្វាយផ្លែស្វាយ
ពូជស្រីចោរក្បត់ មិនអត់សាហាយ ពូជស្រីមេម៉ាយ
ពីម្ដាយដល់កូន ។

១១៩- រើសពូជមិនខុស ពូជសាំងនឹងប្រុស ទាំងអស់បងប្អូន
ពូជសែនមេបា ពីតាដល់ដូន ពូជល្អសុទ្ធសូន្យ
ពីដូនដល់ចៅ ។

រករូបមិនក្រ អាក្រក់ហើយស មារយាទល្អហើយខ្មៅ
ស្រីក្មេងមានខ្នាស ចាស់ចង់ប្រដៅ ប្រដូចតាមដៅ
មិនសូវខុសខាន ។

ពាក្យចាស់លោកថា ធ្វើស្រែចំការ ស្ដាប់មហាសង្ក្រាន្ត
ធ្វើម្ដងខុសខាត ធ្វើម្ដងទៀតបាន ធ្វើតាមប្រមាណ
ប្រមើលទឹកភ្លៀង ។

រកប្ដីប្រពន្ធ ឱ្យគយឱ្យគន់ រើសរករូបរាង
ពូជថ្លៃល្មមយក ពូជថោកល្មមវាង រូបល្អឬកល្អៀង
នាងកុំប្រសព្វ ។

ជាតិស្រីនិងប្រុស បើបានជាខុស ខុសទាល់ចាស់ផាប់
បើបានរូបល្អ កម្រមានភ័ព្វ មានខុសមានគាប់



Websites: WatKhmers.org or WatKhemaraRatanaRam.org

ដូចស្រែចំការ ។

១២០- មួយទៀតអ្នកចាំ អាពុកចំណាំ ទុកជាតម្រា
កុំយកតម្រាប់ កុំស្ដាប់អាចារ្យ បើនឹងរៀបការ
កុំការប្រជួន ។

ប្រដែងវេលា ឮស្គរឆ្លើយគ្នា ប្រទប់ប្រទូន
ស្រុកជិតភូមិផង របងដោយខ្លួន អាចារ្យអាងក្បួន
ថាសុខសប្បាយ ។

កូនអើយអ្នកចាំ យូរណាស់៤ឆ្នាំ ព្រាត់ប្រាសអន្តរាយ
ច្រើនស្លាប់៣នាក់ រស់ម្នាក់មេម៉ាយ កូនឃើញតែម្ដាយ
មិនឃើញអាពុក ។

មានកាលស្លាប់ស្រី ស្លាប់ចោលកូនខ្ចី ប្ដីនៅរងទុក្ខ
យកប្រពន្ធទៀត កម្រពេញមុខ កូននិងអាពុក
បែកគ្នាខ្វាត់ខ្វាយ ។

កូនចៅស្រីៗ បើនឹងយកប្ដី កុំយកពោះម៉ាយ
សូវនៅម្នាក់ឯង បន្ទែងនឹងម្ដាយ អាណិតរូបកាយ
ស្ដាយខ្លួនក្រមុំ ។

១២៥- ហៅប្រុសអភ័ព្វ ប្រពន្ធដើមស្លាប់ មានកូនតូចធំ
យកឯងជាចុង បំរុងតែយំ ច្រើនឈ្លោះជំនុំ
ព្រួយចិត្តម៉ែឪ ។

ហៅប្រុសចិត្តពីរ ពិបាករកស៊ី រញ៉ាំរញ៉ូវ
ឯងនៀយស្មើរស្លាប់ ផ្កាប់ចិត្តមិនត្រូវ បីប្អូនរដូវ



Websites: WatKhmers.org or WatKhemaraRatanaRam.org

ខ្លួនឯងស្លាប់ទៀត ។

ចង្រៃខាងប្រុស កូនអើយចាំចុះ កុំយកខ្លួនបៀត
ស្រីណាខំយក ស្រីនោះបង់មារយាទ ប្រុសព្រួយខ្ចប់ជាតុ
ខ្ចប់គ្រប់ជាប់បី ។

យកទៀតជាប្អូន គ្រោះដល់ស្លាប់ខ្លួន មេម៉ាយខាងស្រី
ប្រាកដមិនខុស ប្រុសក្នុងលោកីយ៍ ស៊ូនៅអត់ប្ដី
ស្លាប់រស់រូបមួយ ។

បើខ្លួនកំព្រា រំពឹងមីងមា រកស៊ីមិនព្រួយ
កាន់មារយាទល្អ មិនក្រគេជួយ បងប្អូនកូនក្មួយ
រត់ចូលឱ្យប្រើ ។

១៣០- ពោះម៉ាយមានបី កុំយកធ្វើប្ដី មិនគាប់ប្រសើរ
អាមួយស្រីលែង ស្រីគេគ្រាន់បើ ពោះម៉ាយក្លាយដើរ
អាងលែងប្រពន្ធ ។

ពោះម៉ាយទាំងអស់ កុំយកឱ្យសោះ ហៅប្រុសទុរជន
ទុរជាតិអប្រិយ ស្រីកើតទុក្ខធ្ងន់ ហៅមួយជំនាន់
ចំណាំមិនខុស ។

កំលោះចាស់យូរ ចាស់ទុំគេប្ដូរ ល្មមព្រមយកចុះ
រកស៊ីមានបាន សុខសាន្តឥតឈ្មោះ ចម្រើនរូបរស់
អាយុយឺនយូរ ។

កុំយកប្ដីប្អូន ថោកពាសីខ្លួន រកស៊ីមិនធូរ
គេហៅឯងធំ សមហៅគេពូ ច្រើនខ្ជិលមូទូ



Websites: WatKhmers.org or WatKhemaraRatanaRam.org

ម៉េះមស់នឹងល្បែង ។
វាច្រើនមើលងាយ ហៅស្ដីនិយាយ ហៅហងហៅឯង
ខ្លួនយើងជាស្រី ស្រដីឥតក្រែង យល់គេប្អូនឯង
ឯងមើលងាយដេរ ។
១៣៩- ពាក្យចាស់លោកចង ប្ដីទុកស្មើបង ប្រពន្ធស្មើម៉ែ
មើលងាយរាល់ថ្ងៃ ចង្រៃរាល់ខែ រកស៊ីធ្វើស្រែ
ច្រើនខាតគ្រាប់ស្រូវ ។
គួរយកប្ដីបង ពាក្យចាស់លោកចង ទុកប្ដីស្មើឪ
ខ្លួនឯងប្រមាថ ប្រតិបត្តិឱ្យត្រូវ រាសីគង់នៅ
ទេព្រក្សរក្សា ។
ប្រពន្ធនិងប្ដី ធំស្រេចនឹងស្រី គត់គង់កិរិយា
ឈ្មោះហើយច្រើនខ្សត់ ស្រីអត់លក្ខណា ប្ដីខ្ជិលឧស្សាហ៍
ព្រោះឫកប្រពន្ធ ។
ជាតិស្រីមានលក្ខណ៍ ទេវតាពំនាក់ កបកើតទ្រព្យធន
ប្រទេចដេរវាយ ចង្រៃទុរជន ជួជាតិលើសលន់
លើសលុបលើប្រុស ។
ហៅកាឡកិណី វាយកូនដេរស្ដី មិនដឹងត្រូវខុស
បើមានភ្ញៀវមក រឹតរករឿងឈ្លោះ អសោចសាយសុស
រង្គោះធនធាន ។
១៤០- រកស្រីមារយាទខ្ពស់ ចេះខ្លើមពាក្យឈ្មោះ ចេះទ្រាំអត់ឃ្លាន
ចេះស្ងួតចេះកាច ចេះខ្លាចចេះហ៊ាន ចេះខ្មាសចេះអៀន



Websites: WatKhmers.org or WatKhemaraRatanaRam.org

កាចមានប្រាជ្ញា ។

កូនចៅស្រីប្រុស ចំណាំទុកចុះ ទុកជាតម្រា
គួរយកតម្រាប់ គួរស្ដាប់ពុទ្ធដីកា ព្រះអង្គទេសនា
គាថាប្អូនបទ ។

រៀនគ្រាប់អ្នកប្រាជ្ញ បើចង់ឈ្នះកាច យកស្លូតសង្កត់
ចង់ឈ្នះមនុស្សខឹង ឱ្យប្រឹងខំអត់ វាដេរវាហាត់
វាស្បថលែងខឹង ។

ចង់ឈ្នះអសុរោះ ស្ដីលេងឡេះឡោះ កុំធ្វើជាដឹង
យើងស្ដីត្រង់ណា ឱ្យចំត្រង់ណឹង ឃើញឬកយើងរឹង
ខ្លាចយើងខាងក្រោយ ។

ចង់ឈ្នះកំណាញ់ ក្រដេក្រដាញ់ សុំអ្វីមិនឱ្យ
បើបានចំណី ហុចវាញយៗ តិចដោយច្រើនដោយ
ក្នុងតែវាដឹង ។

១៤៩- នេះមន្តព្រះពុទ្ធ ប្រាជ្ញាឱ្យមុត ឱ្យគិតថ្លៃងថ្លឹង
កុំកាចសុខខ្នាត កើតខាតដ្បិតខឹង កូនអើយខំប្រឹង
កាន់ច្បាប់ទាំងប្អូន ។

កុំជួញវល់ កុំតប តទល់ កើតទាស់គុំគួន
កូនណាកាន់បាន កូននោះសុខខ្លួន ទោសទាស់លែងជួន
លែងជួបមួយជាតិ ។

បើមនុស្សវៃកទូល មកនៅចំណួល ញ៉េះញ៉ោះធ្វើញាតិ
ឱ្យមើលលៃលក កុំយកខ្លួនបៀត វាទូលទៅទៀត



Websites: WatKhmers.org or WatKhemaraRatanaRam.org

អសារឥតការ ។
ចំណីចំណុក បើឱ្យស៊ីចុក ឱ្យដោយមេត្តា
កុំឱ្យជឿខ្ចី គ្រែងខុសសន្យា កើតទាស់កាលណា
វេរៃករត់បាត់ ។
មនុស្សគ្មានកន្ទេង ខុសពីមារយាទឯង មិនប្រុងប្រយ័ត្ន
តាមទាន់តឹងទារ វាខឹងក្តៅក្តាត់ គុំគួនដោយស្ទាត់
បំភ្លាត់ឯងបាន ។
១៥០- ហេតុនេះគួរគិត គួរកូនពិនិត្យ ច្បាស់សុំរាប់អាន
គួរឱ្យសឹមឱ្យ គួរខានឱ្យខាន ដ្បិតពាក្យបុរាណ
មានពីរចំណែក ។
ចង់ទុកជាក្សួន ចិត្តល្អក្រខ្លួន នេះពាក្យមួយប៉ែក
មួយទៀតចិត្តល្អ មិនក្រយូរពេក ឆ្នាំនេះឆ្នាំស្អែក
ក្នុងតែនឹងមាន ។
ចិត្តល្អក្រខ្លួន ចាំទុកជាក្សួន ជាក្បាលនិទាន
ឃើញអ្នកទូរគត កំសត់អត់ឃ្លាន មិនស្គាល់ពោះវៀន
ហ៊ានឱ្យជឿខ្ចី ។
ទៅទារមិនឱ្យ តឹងតឿនញយៗ ខឹងប្តឹងកើតក្តី
ខាតទាំងទ្រព្យចាស់ អស់ទាំងទ្រព្យថ្មី ស្គមគោក្របី
រវល់ក្តីខានថៃ ។
ចិត្តល្អមួយទៀត មេត្រីជាញាតិ សំដីខ្ទីស្រែ
បានស្រូវស៊ីស្កប់ ត្រឡប់កាច់កែ រំលងឆ្នាំខែ



Websites: WatKhmers.org or WatKhemaraRatanaRam.org

ដកហូតមិនបាន ។

១៥៩- ឯងប្ដីវា-ត ក្ដីទាល់តែក្រ អស់ផ្ទាំងអស់ចាន
របស់ក៏ខាត របរក៏ខាន ដីផងអស់ប៉ុន្មាន
ទំពាំចាញ់ឈ្នះ ។

ទ្រព្យធនអ្វីៗ ចងការជឿខ្ចី មើលមុខឱ្យច្បាស់
កុំបោលច្បាប់ខ្មែរ កុំភ្លេចច្បាប់ព្រះ តាមតែប្រទះ
ប្រទាញសងខាង ។

ចាំចិត្តកណ្ដាល បើនឹងឈឺឆ្អាល សប្បុរសមើលយ៉ាង
រៀនសូត្ររៀនប្រាជ្ញ កាចកុំក្អេងក្អាង ក្រែងគ្រោះសំណាង
ខ្មោចខាងវាស្អប់ ។

ល្អមិនក្រយូរ ស្វែងរៀនរកគ្រូ ស៊ូកុំស្ដាយទ្រព្យ
គ្រូវាយកុំខឹង ឱ្យប្រឹងខំផ្ដាប់ ចេះមន្តសាយសព្វ
ត្រឡប់ជាមាន ។

ធម្មតាអ្នកចេះ អ្នកស្វែងចំណេះ ចេះដ្បិតខំរៀន
ឆ្លាក់គួរក្បូរក្បាច់ សាច់សិល្ប៍របៀន អ្នកខ្សត់អត់ឃ្លាន
ព្រោះចិត្តអាក្រក់ ។

១៦០- ខូចខិលល្ងង់ខ្លៅ គ្រូជេរប្រដៅ ខឹងលបសំឡក់
របេញរបុញ ភូតភរកុហក ស៊ូប្លន់លួចឆក់
មិនខំធ្វើស្រែ ។

អ្នកប្លន់អ្នកលួច ឆក់បានតិចតួច បានគ្រាន់បើដែរ
ដល់គេឃើញមុខ ត្រូវគុកច្រើនខែ អាក្រក់ដល់ម៉ែ



Websites: WatKhmers.org or WatKhemaraRatanaRam.org

ខូចកេរ្តិ៍ដល់ឪ ។

ចង់ខ្ពស់បានទាប ចចើងចង់លាភ វែងបាត់ធនទៅ
ពាក្យពីបុរាណ លោកអានតម្រូវ ឫកមនុស្សឥឡូវ
ត្រូវតាមតម្រាយ ។

អ្នកលួចអ្នកប្លន់ ចង់បានប្រពន្ធ ចេញជួញស្រុកឆ្ងាយ
ទិញផ្ការមេស្រុក សូកធ្វើចៅហ្វាយ ចង់ធ្វើសប្បាយ
ចាយប្រាក់រាជការ ។

ធបាំងបំបាត់ លួចបានដោយស្ងាត់ អាងមានប្រាជ្ញា
ក្រឡេចថ្នាំងដៃ កាឡៃបោះត្រា ទាស់ភ្នែកទេវតា
រក្សាផែនដី ។

១៦៥- មួយទៀតទុរជន ធ្វើបាបបានបុណ្យ គឺបុណ្យមន្ត្រី
ទោសទៅចង់ចាប់ កាប់ឥតប្រណី បានបុណ្យមន្ត្រី
ព្រោះបុណ្យធ្វើបាប ។

អំពើទាំងអស់ កុំសាងឱ្យសោះ ចៀសវាងដរាប
កាន់សីលព្រះពុទ្ធ ឱនលុតលូនក្រាប បើក្រដុនដាប
មានទេវតាជួយ ។

កូនអើយទេវតា ស្ថិតសព្វព្រឹក្សា រវើករវ្វយ
មនុស្សទ្រុស្តឫស្យា ឯណាទីមួយ ទេវតាពុំជួយ
ចំណាំស្គាល់មុខ ។

មិនដែលកំបាំង រាជការបាពាំង គេចាប់ដាក់គុក
ដល់ខ្លួនស្លាប់ទៅ នៅរង់សោយទុក្ខ សោយទោសនរក



Websites: WatKhmers.org or WatKhemaraRatanaRam.org

ទាំងពីរកន្ទែង ។
នរកបាពាំង   មានខ្សោយមានខ្លាំង   មានខ្វីមានវែង
នរកយម្មបាល   គេផ្ដាលឥតក្រែង   ព្រះអង្គសំដែង
ថាលានកោដិឆ្នាំ ។
១៧០- ហេតុនេះគួរវាង   គួរចោលគួរពាង   គួរចងគួរចាំ
គួរកុំធ្វើបាប   ដរាបខ្វាចកម្ម   គួរកាន់សីលប្រាំ
បណ្ដាំសាសនា ។
ហៃកូនចៅអើយ   ក្រឡាប់អស់ហើយ   មិនដូចដូនតា
ភ្លៀងជន់ខែប្រាំង   ពាំងខែវស្សា   ឆ្នាំវករកា
ត្រីស័កនេះឯង ។
រនោចផល្គុន   រកាពីមុន   ឯកស័កដាក់ស្ដែង
ក្នុងខ្នើតផល្គុន   ជន់គ្រប់កន្ទែង   ទាំងគេទាំងឯង
ធ្វើស្រែបានផល ។
ឆ្នាំពោងឆស័ក   វិសាខភ្លៀងធ្លាក់   ពីរពោចសំគាល់
យប់ថ្ងៃអាទិត្យ   ផងផឹតព្យុះខ្យល់   ភ្លៀងជន់ពេញថ្នល់
ពេញវាលតូចធំ ។
ពេញអូរពេញជ្រោះ   ដើមឈើទាបខ្ពស់   រលុះរលំ
ឫស្សីស្រុកយើង   រលើងទាំងគុម្ព   ទើបគ្រាប់វាផ្ដុំ
ផ្ដួចផុះជាថ្មី ។
១៧៥- ឆ្នាំចកុរជូត   ពាំងរីងរហូត   គ្រប់ឆ្នាំទាំងបី
កើតទាំងជម្ងឺ   ស្លាប់មនុស្សប្រុសស្រី   ខាលជោះអស់ក័យ



Websites: WatKhmers.org or WatKhemaraRatanaRam.org

ធ្វើស្រែស្រូវបាន ។
ភ្លៀងឆ្នាំម្យ៉ាញ់ រលើងក្បាលក្រាញ់ ត្រូវតាមបុរាណ
កត្តិកជន់វាល ពលសព្វស្មសាន អ្នកស្ទឹងប៉ុន្មាន
រលួយស្រូវអស់ ។
ដាច់ថ្នល់ខានដើរ ពជការគេប្រើ ទាំងចាស់កំលោះ
មមៃរងកម្ម បញ្ចាំកេរ្តិ៍កោះ គ្មានអ្វីស៊ីសោះ
ដាច់ពោះក្សិណក្ស័យ ។
ខែចេត្រឆ្នាំរក ស្រឡះពពក កើតមានសម័យ
ជាហេតុអស្ចារ្យ សុរិយាល្ងាចថ្ងៃ ឧត្បាតចង្រៃ
ឃើញសត្វអ្វីហោះ ។
ពីជើងទៅត្បូង ចាស់ក្មេងមើលច្រូង បានឃើញទាំងអស់
មើលមិនស្គាល់ជាក់ ធ្លាក់ចំចន្ទោះ បាត់ឈឹងសូន្យសោះ
មិនដឹងទៅឯណា ។
១៨០- កាលមុននោះមក ខែបុស្សឆ្នាំរក លែងមានអាជ្ញា[១]
មានតែមេស្រុក រាស់បែងក្រឡា ដីមួយហិតា
ស្រូវសែសិបថាំង ។
រង្វាន់មេស្រុក ត្រូវហូតមួយទុក ជប់ជូនបារាំង
ទៅដល់ប៉ុយរ៉ូ បង្ហូវដាក់ឃ្លាំង ពូជពីរកន្ទាំង
ក៏ជាប់ពន្ធដែរ ។
គ្មានផ្លូវគ្មានតឹង កូនអើយខំប្រឹង ជាតិឯងជាខ្មែរ

(១) អាជ្ញាហ្លួងពន្ធស្រូវ អាជ្ញាហ្លួងអ្នកទាយផលស្រូវហើយហូតពន្ធ ។



Websites: WatKhmers.org or WatKhemaraRatanaRam.org

ក្មេងប្រុសជំទង់ នៅក្នុងឪម៉ែ រាជការប្រិតប្រៃ
ថាឱ្យបង់ប្រាក់ ។
កូនចៅប្រុសស្រី កើតមកលើដី ខំរកលុយកាក់
បានហើយប្រឹងខំ ផ្សំគ្នាទុកដាក់ គ្រាន់ទិញស្បៀកពាក់
បង់ថ្ងៃរាជការ ។
កទ្រូបទផ្ទាំច ចាប់គោខ្មៅស ដុតដែកបោះត្រា
ដល់កុរជូតធ្នូរ តម្រូវយ៉ាងណា នឹងកើតអស្ចារ្យ
រហូតរាល់ឆ្នាំ ។

១៨៥- នរគថ្កើងប្លែក សប្បាយតែក្អែក ក្នុងចិត្តរងកម្ម
កូនប្រុសបណ្តាច់ កុំភ្លេចបណ្តាំ កប្បាសសូត្រថ្នាំ
ត្រីម៉ាំលែងថោក ។
ដូងស្វាអំពៅ អំបិលស្ករស្រូវ មានទៅមានមក
មានចុះមានឡើង រាស្ត្រយើងល្មមរក ល្មមរលែលក
គួរយកគួរខាន ។
កប្បាសនិងថ្នាំ គួរដាស់ដីដាំ ធ្វើដៃឯងបាន
កុំអាងខ្ជិលពេក កុំដេកឈប់ខាន កុំចោលបុរាណ
ម៉ែឪជូនតា ។
ដីកេរគរគោក កុំអាងខ្ជិលដោក ទៅឈ្មោកចិនផ្សារ
កូនចៅស្រីៗ ខំរៀនធ្វើការ បើគ្មានប្រាជ្ញា
មានមាត់ចេះស្តី ។
ឱ្យសួរចាស់ៗ រៀនបោះកប្បាស ថ្ពេចមូរសំឡី


Websites: WatKhmers.org or WatKhemaraRatanaRam.org

រៀនកូតរៀនការ ត្រសារពាត់វៃ ហូលគោមគាតក្ដី
កុំបីចន្លោះ ។
១៩០- រៀនថ្លុររៀនត្បាញ ឱ្យចាស់បង្ហាញ បង្ហាត់ទាំងអស់
សំពត់បែបផាយ លាយសូត្រអម្បោះ កុំទិញគេសោះ
ឈ្មោះការជាស្រី ។
ទិញដូរតែល័ក្ខ(២) អញ្ចូលចេសចាក់ ព្រហូតជាបី
ធ្មេញឈើឈ្នាន់ផ្សំ ក្ដារម្ធូរក្ដារកី ត្រល់ខ្នារឫស្សី
មុខប្ដីជាប្រុស ។
តាំងពីឆ្នាំច ការអ្វីក្រៗ ខំរៀនទៅចុះ
ទាន់មានចាស់នៅ ស្គាល់ត្រូវស្គាល់ខុស ចាស់ស្លាប់រលស់
គ្មានមនុស្សចេះដឹង ។
រកស៊ីឱ្យញឹក ដេកយប់រលឹក រឹតក្បៀនឱ្យតឹង
បើភ្ញាក់កាលណា កាន់ការកាលនឹង កូនអើយខំប្រឹង
ទាំងប្រុសទាំងស្រី ។
រមៀតស្លឹកគ្រៃ ដីរម្ទេសខ្ទឹមខ្ញី មានដីដាំចុះ
ដាំដើមអ្វីៗ ចំណីគ្រប់ឈ្មោះ គ្រឿងស៊ីផ្អែតពោះ
ផុះចោលទទេ ។
១៩៥- ផុះទិសខាងជើង ផុះដាក់ដីយើង កុំផុះដីគេ
កុំផុះដាក់ផ្លូវ ត្រូវមាត់ក្មេងដេរ ដីសល់ទំនេរ
ល្មមរមាត់ផុះទៅ ។

(២) ល័ក្ខ ផង់ល្អិតឬកករឹងជាដុំ មានពណ៌ផ្សេងៗ សម្រាប់ប្រើជាគ្រឿងជ្រលក់ ។



Websites: WatKhmers.org or WatKhemaraRatanaRam.org

សក់មួយជាដប់ ជ្រៀតសិតឱ្យសព្វ កុំអោយសល់នៅ
បើប្រាថ្នាពាក់ ចាក់ចិត្តឱ្យជ្រៅ ដាំចេកអំពៅ
ដូរស្រូវអង្ករ ។

កើតមកជាមនុស្ស មួយព្រួយចង់រស់ មួយព្រួយចង់ល្អ
ពីរនេះជាធំ វានាំឱ្យក្រ ចាំជាតំណ
តជាទំនុក ។

មនុស្សមារយាទមិនប៉ិន កូននៅខ្ញុំចិន ព្រោះម្ដាយឪពុក
ធ្វើស្រែមិនត្រូវ គ្មានស្រូវជង្រុក កូនអើយចាំទុក
នេះមុខមេក្រ ។

មេ១ជាធំ កំលោះក្រមុំ ស្ទៀកពាក់ចង់ល្អ
បើបានបែបខ្មៅ ថានៅបែបស ទើបគ្រាន់អន់ក្រ
ត្រូវជរចង់ថ្កើង ។

២០០- ក្រឡាប់នគរ រឹងរឹតកើតចោរ ច្រើនឡើងច្រើនឡើង
ពាលរឹងក្រអើត ចើតម៉ើតចើតម៉ើង ក្រជាសយ៉ាងស្ដើង
ចាយរហែកនៅដៃ ។

ប្រាក់ចាស់អស់ទៅ ព្រោះមនុស្សឥឡូវ ឧត្បាតចង្រៃ
ជាតិខ្មែរប្រែភេទ ក្រឡេតក្រឡៃ ក្រឡាស់សាសន៍សៃយ៍
សព្វសត្វនានា ។

ជាតិខ្មែរប្រែខុស ស្រីក្មេងធ្វើប្រុស ប្រុសក្មេងធ្វើផ្កា
យកប្ដីប្រពន្ធ មិនស្គាល់មីងមា បុណ្យទានការងារ
កាប់គ្នាឥតក្រែង ។



Websites: WatKhmers.org or WatKhemaraRatanaRam.org

លួងបូកធ្វើចេះ គោចង់ត្រដោកសេះ ប្រុសៗដុះស្នែង
ស្រីពាក់អាវខ្វី ប្រុសពាក់អាវវែង សារុងហៀរកែង
ធ្វើឯងអ្នកគ្រាន់ ។

កាន់ចិត្តសីហលោ សេះទឹមនឹងគោ ចាក់ហ៊ោលាន់ៗ
រកស៊ីមួយថ្ងៃ ចង់បានមួយពាន់ បរគោជល់មាន់
ចាក់កាប់ជាប់គុក ។

២០៥- រីល្បែងបៀប៉ោ ច្រើនទៅជាចោរ ប្រកាសហាមទុក
ចូរកូនប្រយ័ត្ន ប្រយោជន៍ទៅមុខ ចាំជាទំនុក
តំណកូនចៅ ។

អ្នកកុំប្រហែស រាជការនិរទេស កុំចាត់ចេញទៅ
រាជការអាណិត ខំប្រិតប្រដៅ កុំលោភល្ងង់ខ្លៅ
ថោកផៅត្រកូល ។

ប្រយ័ត្នក្រែងក្រ ផ្លូវច្បាប់ល្អៗ អ្នកខំប្រមូល
ផ្លូវវៀចអាក្រក់ អ្នកកុំដើរចូល ហៅផ្លូវមិនស្រួល
លង់ផុតគំនិត ។

ដើរផ្លូវកណ្ដាល ស្រឡាញ់ស្និទ្ធស្នាល ឈឺឆ្អាលដោយពិត
មគ្គផលសីលទាន ឈានចូលឱ្យជិត យកធម៌ជាមិត្ត
មិនឥតអំពើ ។

មនុស្សម្នាក់ច្រើនឆោត ច្រើនគ្នានគេកោត ឈឺគ្មានគេមើល
ស្លាប់ឥតគេព្រួយ គេជួយទាំងស្នើរ មិនដែលឡើងលើ
ប្រមុះចុះក្រោម ។



Websites: WatKhmers.org or WatKhemaraRatanaRam.org

២១០- កូនចៅស្រីៗ ក្រមុំសាវខ្ចី រៀនតោតឱ្យល្មម
ប្រុសស្មើម៉ែឪ ធូវធប្រលោម មើលរូបមើលតោម
កុំព្រមដោយងាយ ។

កុំក្និចក្នក់ក្នាញ់ បើចិត្តស្រឡាញ់ កុំចេញនិយាយ
បើស្អប់កុំប្តឹង បើខឹងកុំធ្លាយ កុំពោះកុំពាយ
កុំងាយធ្វើស្និទ្ធ ។

កុំដើរប្រាប់គេ កុំអាងអួតជេរ ក្រែងប្រុសឈឺចិត្ត
នៅឱ្យតែនឹង កុំរវល់ធ្វើស្និទ្ធ ប្រុសនឹងអាណិត
គិតចូលដណ្តឹង ។

បើម៉ែឪឱ្យ មើលមុខមើលក្រោយ អាក្រក់ខ្មៅធ្អឹង
ប្រកែកដោយស្ងាត់ កុំខ្វាចម្តាយខឹង កើតកូនមកតឹង
ពិបាកចាយណាស់ ។

កុំឃ្លានចំណី កុំខ្លាច់អត់ប្តី កុំភ័យខ្លាចចាស់
មើលមុខឯងផង កុំរើសឥតខ្នាស ខ្លួនល្អស្រឡះ
មិនខ្វះគេស្តី ។

២១៥- បើបានជាខូច ទាន់ផើមនៅតូច ខែពីរខែបី
រវៀសធ្វើយប្រញាប់ ប្រាប់គ្នាស្រីៗ កុំលាក់ធ្វើអ្វី
ក្នុងតែគេដឹង ។

កុំមាយាបេះក្រូច មារយាទចេះតែខូច មាត់ចេះតែខឹង
គេថាត្រូវណា ជេរគេត្រូវហ្នឹង ជេរហើយខំប្រឹង
យកថ្មសង្កត់ ។



Websites: WatKhmers.org or WatKhemaraRatanaRam.org

| | | |
|---|---|---|
| រំលាយរំលូត | អាក្រក់តែគូទ | អួតល្អតែមាត់ |
| មានគេឃើញច្បាស់ | ម្នះរើងហ៊ានស្បថ | ទោសនេះនឹងភ្ជាត់ |
| | ធ្លាក់ទៅអវិចី ។ | |
| ចោរកាចល្ងង់ខ្លៅ | ប្រាជ្ញប្រាមប្រដៅ | ហៅបាពជិកស្រី |
| មេបាកាច់គេ | ស្លាប់ពីរស្លាប់បី | រំលូតកូនខ្ចី |
| | ស្មើរំលាយព្រះ ។ | |
| មានកាលមិនក្បែរ | ខ្វិនជើងខ្វិនដៃ | កខ្វេះកខ្វាស |
| ខ្វាក់ភ្នែកអន្ធការ | អនិច្ចារូបណាស់ | អាក្រក់កេរ្តិ៍ខ្មាស |
| | តកូនតចៅ ។ | |
| ២២០- អសោចសុសសាយ | សុសសព្វដល់ម្ដាយ | ដល់ពូជពង្សផៅ |
| ស្លាប់ទៅវេទុក្ខ | នរកឋានក្ដៅ | គេស្រុសទឹកក្ដៅ |
| | ស្លាប់ទៅរស់ទៀត ។ | |
| ស៊ីខ្ទុះឈាមឯង | ព្រះអង្គសំដែង | ថាមុឺនសែនជាតិ |
| ឡើងមកជាប្រេត | ហេតុកម្មមិនឃ្លាត | អត់ឃ្លានគ្មានញាតិ |
| | ហែកកូនឯងស៊ី ។ | |
| ព្រះពុទ្ធលៃងប្រោស | ធម៌លៃងសន្តោស | សោយទុក្ខវក់វី |
| ហេតុចិត្តឫស្យា | មិច្ឆាទិដ្ឋី | កើតជាជ្រូកញី |
| | គេគ្រៀវគេចាក់ ។ | |
| អសង្ហើយ្យឆ្នាំ | ហេតុផលសេសកម្ម | កើតជាមនុស្សខ្វាក់ |
| មនុស្សខ្វិនទ្រមទ្រម | ជាគមជាគាក់ | ខ្ទើយឆ្លូតអបលក្ខណ៍ |
| | ជាអ្នកឥតប្ដី ។ | |



Websites: WatKhmers.org or WatKhemaraRatanaRam.org

បើម្ដាយជួយព្រួត ជួយដាន់រំលូត រំលាយកូនខ្ចី
នរកប្រេតព្រមគ្នា មិនឃើញរស្មី ដ្បិតចិត្តតិរ្ថិយ
ទាំងម្ដាយទាំងកូន ។

២២៩- ហេតុនេះគួរខ្លាច ធម្មតាចោរកាច មិនដែលស្ងាត់ស្ងៀម
អសោចកេរ្តិ៍ឈ្មោះ ទាំងអស់បងប្អូន មេបាតាដូន
កាត់កាល់លែងរាប់ ។

គួរប្រុងឥរិយា កើតទាន់សាសនា ហៅមហាមានភ័ព្វ
ទាំងប្រុសទាំងស្រី កុំបីឱ្យផ្ដាប់ គួរខំរៀនផ្ដាប់
បរលោកលោកីយ៍ ។

ឯខុសនឹងគាប់ បើនឹងរៀបរាប់ រាល់រូបប្រុសស្រី
គាប់ខុសនៅចិត្ត ខុសគាប់នៅស្ដី គំរប់ជាបី
ខុសត្រូវនៅកាយ ។

កូនប្រុងប្រព្រឹត្តិ ការកេរ្តិ៍ឱ្យជិត គំនិតឱ្យឆ្ងាយ
កើតមកជាខ្មែរ កុំប្រែក្លែងក្លាយ ធម្មតាសប្បាយ
វាតែងឱ្យទុក្ខ ។

ឱ្យទោសទាស់ទែង ទាស់តែម្នាក់ឯង ដល់ម្ដាយឪពុក
រឿងរឿងទោស មានតែពីរមុខ មួយទៅនរក
មួយនាលោកីយ៍ ។

២៣០- លោភោទោសោ កើតពីមោហោ រាល់រូបប្រុសស្រី
គួរកាន់មេត្តា កតញ្ញូខន្តី នេះគឺបាលី
ទៅកាន់បរលោក ។



Websites: WatKhmers.org or WatKhemaraRatanaRam.org

ពាក្យពិតប្រដៅ ឱ្យអស់កូនចៅ ប្រព្រឹត្តរៀនយក
កូនណាមិនរៀន កូននឹងមារយាទថោក នឹងធ្លាក់ជ្រុលជ្រក
ក្នុងចតុរាបាយ ។

ធំស្រេចនៅស្លូត សុខខ្លួនរហូត ដរាបវែងឆ្ងាយ
ខន្តីអំណត់ សង្កត់ក្នុងកាយ ជាតិជនទាំងឡាយ
កម្រកាន់បាន ។

ចេះហើយមិនដឹង ចិត្តនៅម្នះរឹង ប្រឹងរកកម្មដ្ឋាន
រកធម៌មិនយល់ ខ្ជិលខ្វល់ឈប់ខាន បន្ទោសបុរាណ
ថាគ្មាននិស្ស័យ ។

រីបាបនិងបុណ្យ មានចិត្តជាមុន មាត់ជាបច្ច័យ
នាំចុះនាំឡើង ពីជើងពីដៃ សន្សំសព្វថ្ងៃ
ឈ្មោះហៅសំណាង ។

២៣៩- កើតក្នុងលោកិយ៍ រាល់រូបប្រុសស្រី មានចិត្តជាអាង
កុសលអកុសល ប្រទាញសងខាង រូបនៅតែងតាង
តែងតាមទៅមក ។

មគ្គផលសីលទាន បើល្ងង់ឱ្យរៀន បើគ្មានឱ្យរក
យល់ល្អសាងស្អាត សង្វាតជ្រៀតជ្រក ជ្រើសរើសរៀនយក
រក្សារូបកាយ ។

នេះគឺហៅច្បាប់ ជាទីសណ្ដាប់ សន្ដានទាំងឡាយ
កូនចៅប្រុសស្រី កុំបីនឿយណាយ សង្ខេបបរិយាយ
និដ្ឋិតំបែងចប់ ។



Websites: WatKhmers.org or WatKhemaraRatanaRam.org

អ្នកព្រះភិរម្យ អាចារ្យង៉ុយខ្ញុំ បង្គំម្រាមដប់
លើសលស់ផ្ដាំផ្ដង រំលងពុំគាប់ ពុំគួរសមសព្វ
សុសសាយសេចក្ដី ។
កាយកម្មវចីកម្ម ឈ្មោះច្បាប់បណ្ដាំ កូនចៅប្រុសស្រី
ជាបរមត្ថក្រៅ មិនហៅបាលី បរលោកលោកីយ៍
ទាំងពីរកន្លែង ។
២៤០- បើលោកឯណា ចេះចាំធម៌អាថ៌ ប្រាកដជាក់ស្ដែង
ឃើញខុសត្រង់ណា កុំថាជាល្បែង ដ្បិតពាក្យខ្ញុំតែង
ឱ្យក្មេងវាភ័យ ។
មិនមែនភរភូត កុំថាខ្ញុំអួត ប្រាជ្ញាខ្ញុំវៃ
ឃើញមនុស្សវង្វេង ខ្ញុំតែងច្បាប់ថ្មី អស់អាថ៌សេចក្ដី
ឯរំចប់ហោង ។



Websites: WatKhmers.org or WatKhemaraRatanaRam.org

# ច្បាប់ កេរកាលថ្មី

នេះបទព្រហ្មប្រាជ្ញប្រាយ ខ្ញុំអធិប្បាយលើកល្បត់ល្បង
ប្រដៅកូនចៅផង បងជាច្បាប់ខុសនិងត្រូវ ។
កត្តិកខ្នើតគ្នេរគ្នាន់ ក្នុងវស្សន្តរដូវ
ទឹកស្រែជន់លិចស្រូវ នៅសំណល់សំណាបខ្ចី ។
កេរកាលពីព្រេងព្រឹទ្ធ ដើមគំនិតពីសេដ្ឋី
ខ្ញុំលើកកេរកាលថ្មី បែងសេចក្ដីជាបរមត្ថ ។
ក្នុងថ្ងៃពេញបូរមី ម៉ោង៨ព្រលប់ស្ងាត់
ឆ្នាំបបត្វាក្សត្រ ផាត់សករាជកន្លងឆ្ងាយ ។

៥- សាសនាព្រះសមណៈ បានពីររពាន់បួនរយប្លាយ
ហុកសិបប្រាំកំចាយ បាត់អធិប្បាយពីខុសត្រូវ ។
កេរកាលដំណាលទុក ជាទំនុកដំណែលនៅ
ដំណាតរៀងទៅ តម្រូវចិត្តជនប្រុសស្រី ។
កូនអើយពាក្យអាពុក ជាទំនុកទំនើបថ្មី
អនិស្រាយរាយបាលី អាពុកស្ដីឱ្យកូនស្ដាប់ ។



Websites: WatKhmers.org or WatKhemaraRatanaRam.org

| | |
|---|---|
| គួរស្តាយកេរ្តិ៍ម៉ែឪ | កិរិយាត្រូវឱ្យខំត្រាប់ |
| កិរិយាណាខុសច្បាប់ | គួរក្រឡាប់ក្រឡាស់បោល ។ |
| ម្តាយអាពុកនិងកូន | បីដូចខ្លួននិងស្រមោល |
| ឃើញខុសកុំដេញដោល | កុំបង្កោលទោសអ្នកមានគុណ ។ |
| ១០- ល្ងង់ខ្លៅត្រូវតែសួរ | ពាក្យឱ្យគួរកុំឱ្យស៊ុន |
| យកពាក្យផ្អែមជាមុន | ទន់លំទោនឱនប្រតិបត្តិ ។ |
| ទោះម៉ែឪស្លូតកាច | គួរតែខ្លាចដូចមហាក្សត្រ |
| ម្តាយជេរពីរបីម៉ាត់ | គួរតែស្ងាត់ស្ងៀមឱ្យឈឹង ។ |
| ប្រដៅត្រូវតែស្តាប់ | យកតម្រាប់កុំទទឹង |
| ម្នោម្នះបបេសរឹង | នឹងហើយហៅកូនសេសកម្ម ។ |
| ធមិអាចិបេះតែភ្លេប | ជេរប្រទេចបេះតែបាំ |
| អាពុកពត់ទៅស្តាំ | អកុសលកម្មទាញទៅឆ្វេង ។ |
| អវជាតបុត្រ | ខូចបំផុតតាំងពីក្មេង |
| ប្រព្រឹត្តព្រើលផ្សេងៗ | បើលេងអ្វីស៊ីមិនស្តាប់ ។ |
| ១៤- មិនស្តាយជាតិកំណើត | ល្ងង់ស្លុតស្លើតដល់បាស់ស្លាប់ |



Websites: WatKhmers.org or WatKhemaraRatanaRam.org

ត្រឹមត្រូវមិនសូវស្គាល់ ព្រួយគេប្រាប់ទាំងយប់ថ្ងៃ ។
ម៉ែឪមានគុណណាស់ មិនសំពះខ្មាសអៀនដៃ
បើអ្នកក្រៅដទៃ វិស័យសោះសំពះបាន ។
ឆ្លើយបាទបាះបាំខ្ញុំ រាបរម្យទមនឹងសន្ដាន
ម៉ែឪឯងក្នុងឋាន ហ៊ានឆ្លើយអឺអញអឺអើ ។
អនុជាតបុត្រ ស្លូតបំផុតស្រណុកប្រើ
ប្រកបការប្រសើរ ដើរតែតាមលំអានឪ ។
ប្រដៅទទួលយក បេះលៃលកស្គាល់ខុសត្រូវ
ស្រណុកញាក់ធ្លាក់ផ្លូវ មិនសូវភ្លេចដំបូន្មាន ។
២០- អតិជាតបុត្រ ល្អបរិសុទ្ធស្គាល់សីលទាន
នាំឪទៅនិព្វាន ឈានទៅរកកន្លែងសុខ ។
បេះលើសគេជរាប ជឿបុណ្យបាបប្រែតនរក
មិនល្មោភនឹងមុត្រលាមក ភ័យនឹងភក់ភពសង្សារ ។
នេះគឺដើមបាលី បុត្រទាំងបីបែបកិរិយា



Websites: WatKhmers.org or WatKhemaraRatanaRam.org

ស្រឡាញ់ណាស្អប់ណា តាមសញ្ញាចូលបិត្តចុះ ។
អវធ្លាក់ផ្លូវក្រោម ប្រព្រឹត្តព្រមតែខាងខុស
អតិជាតមារយាទខ្ពស់ អនុវោះយ៉ាងកណ្ដាល ។
អតិ១០០មានមួយ គួរតែស្ងួយដាក់លើក្បាល
អវគឺស្រើបស្រាល ត្រូវអាលយកតែពីរយ៉ាង ។

២៥- អតិជាតកំណើត គំនិតកើតពីកសាង
កុសលតម្កល់ខាង សំណាងកើតពីគំនិត ។
អនុអាធាងអើយ ខ្លួនធំហើយឱ្យបេះគិត
បេះកាញ់ស្គាល់ឆ្ងាយជិត ប្រព្រឹត្តយកតែខាងត្រូវ ។
រៀនរិះរកទ្រព្យធន យកប្រពន្ធមើលធុនឱ
ធុនថោកជ្រកខុសត្រូវ អ្នកកុំទៅខ្លាចបន្ទា ។
ផ្លូវវៀចកុំបោះបង់ ផ្លូវព្រៃត្រង់កុំយាត្រា
ឈានឈរពិចារណា ឆ្ការឱ្យស្អាតសឹមដើរទៅ ។
កុំដើរភ្លើភ្លេចខ្លួន ខ្លាចក្រែងជួនធ្លាក់ជ្រោះជ្រៅ



Websites: WatKhmers.org or WatKhemaraRatanaRam.org

ជ្រកម្លប់សំណាក់នៅ កុំបោះពៅផ្ទប់គល់ឈើ ។

៣០- ឆេះខ្លោចសំបកក្រោម ស្រពោនញមស្លោកស្លឹកលើ

មានភ្នែកឱ្យបេះមើល កុំល្ងីល្ងើល្ងង់ល្ងិតពេក ។

រៀនដើរឱ្យមើលផ្លូវ ធ្វើស្រែស្រូវឱ្យមើលមេឃ

ម្លប់ធ្លកធ្លាប់ជ្រកដេក ជាដំណេកអ្នកដំណើរ ។

ដំណែលដែលគេដាក់ ជាដំណាក់ទំនួលផ្ញើ

បំណាំចាំគ្រាន់បើ ដើរក្រោយៗគ្រាន់ជ្រកទៀត ។

ឈើណាទោសសត្រូវ ដុះជិតផ្លូវនាំបង្អៀត

ដំពប់យប់អធ្រាត្រ ឆ្កៀតកាប់ចេញកុំទុកវា ។

បន្លាគល់ដង្គត់ កន្លងផុតតែភ្នែកជា

ដើរយប់ដំពប់ពារ ក្រែងគ្រោះគ្នាអ្នកដើរក្រោយ ។

៣៤- គ្នាមុតកុំបាំផ្ទាត់ ឃើញគួរដាត់កុំបណ្ដោយ

បណ្ដើរមើលខ្លាំងខ្សោយ ឱ្យពិនិត្យពិចារណា ។

ពាក្យពិតត្រង់ប្រាកដ ត្រូវប្រើនបទប្រើនប្រការ



Websites: WatKhmers.org or WatKhemaraRatanaRam.org

ប្រកបជាប្រស្នា    ប្រាជ្ញាអាប់ស្លាប់នឹងធ្ងល់ ។
ផ្លូវពិតទាំងជិតឆ្ងាយ    សព្វសុសសាយមិនសេសសល់
អ្នកណាប្រាជ្ញាដល់    ដឹងយោបល់ច្រើនកន្លែង ។
កូនអើយការកេរ្តិ៍ឈ្មោះ    កុំបង់រស់តែម្នាក់ឯង
គិតអ្វីគិតឱ្យវែង    ក្រែងក្រក្រោយស៊យគំនិត ។
កំណើតរាល់រូបកាយ    ចេញផ្លូញឆ្ងាយស្តាយផ្លូញជិត
បិញ្ចឹមជន្មជីវិត    គិតឱ្យស្រេចទើបបានស្រួល ។
៤០- ធ្វើស្រែចង់បានស្រូវ    ដើមរដូវធ្វើស្រែទួល
ស្រែទាបមើលទំនួល    លើកទំនប់ឱ្យមាំមួន ។
កូនអើយកេរ្តិ៍មេបា    ចាំរក្សាមើលថែថ្នួន
ធុញថប់ថយថោកខ្លួន    ជួនជាខ្សត់គេថាខ្សោយ ។
ស្រូវខ្សោយអង្ករថ្លៃ    លក់សំបែទុកឆ្នាំក្រោយ
អ្នកក្ររកញយៗ    ឱ្យអ្នកសុំជាងអ្នកខ្ចី ។
សប្បុរសពេកថយធន    មូទូជនថយរាសី



Websites: WatKhmers.org or WatKhemaraRatanaRam.org

ប្រពន្ធល្អច្រើនអាប់ប្ដី    ពាក្យអប្រិយបាញ់អាត្មា ។
ឈើផ្លែបាញ់សន្លឹក    ត្រីវរវឹកទឹកមិនថ្លា
កំណាញ់គ្រៀតម្រា    សោតសឹងអាប់ប្រយោជន៍យស ។

៤៩- នឹងឱ្យៗមើលភាព    ឱ្យអ្នកទាបជាងអ្នកខ្ពស់
អ្នកទិញឈប់សិនបុះ    ក្នុងតែរស់មិនស្លាប់ងាយ ។
កំណាញ់ហួសកំណត់    ពាក្យអ្នកខ្សត់ខ្សបនិយាយ
ទេវតាផ្ដន្ទាទាយ    រលាយអស់រលស់ឯង ។
សទ្ធាមើលធនធាន    ជាតិអ្នកមានមិនអង្វែង
កំណាញ់ដោយកន្លែង    ក្រែងគ្រោះក្រដល់ឆ្នាំក្រោយ ។
អ្នកក្រខ្ចីនេះកុំ    អ្នកមានសុំនេះគួរឱ្យ
អ្នកប្រាជ្ញអង្គាសញ្ញយ    អស់ក៏ដោយឱ្យទៅចុះ ។
អ្នកក្របានជាហាម    ពិបាកតាមទៅឯណោះ
ទាល់ទឹកបួលប្រមុះ    ច្រើនកើតឈ្លោះពីព្រោះយល់ ។

៥០- អ្នកមានគេមានខ្នាស    សងរហ័សមិនអំពល់


Websites: WatKhmers.org or WatKhemaraRatanaRam.org

ជួនយើងមានរវល់　　គេស្គាល់មុខស្រណុកខ្ចី ។
អ្នកក្រៗទាំងចិត្ត　　ស្រូវឆ្មារស្អិតឱ្យមើលស្អី
រាល់ល្អកក្ដាំងបី　　ទាត់ស្រូវថ្មីទារឆាប់បាន ។
ជួនក្រែងឯងក្រវិញ　　ទោះដូរទិញមើលប្រមាណ
ជឿបុលខ្ចីសន្ដាន　　កុំហ៊ានពារកញ្ជើធំ ។
ខ្លួនក្រកុំបង់ផាត់　　កុំងាយមាត់អាងតែសុំ
ជឿខ្ចីស្អីក្រមុំ　　ស្រូវឯងទុំស្រណុកសង ។
បើជឿខ្ចីគេឱ្យ　　កុំទៅញយគេឱ្យខ្នង
ឯណេះឯណោះផង　　កុំច្រើនដងគេមើលងាយ ។

៥៥- ក្រលុយកុំងុយដេក　　ចូលដំណេកកុំនិយាយ
សំពត់ញាត់សំពាយ　　រាយរើសរៀបញាត់សំពៀត ។
រៀបដេកសំពះគុណ　　កុំដេកស៊ុនឱ្យប្រុងស្នៀត
ភ្លើងឆេះយប់អធ្រាត្រ　　កណ្ដៀតទូលប្រមូលរត់ ។
ខ្លួនរាស្ត្រក្រមាសប្រាក់　　រើបកន្ត្រាក់អាវសំពត់


Websites: WatKhmers.org or WatKhemaraRatanaRam.org

ទំរាំភ្លើងរលត់ ស្ងៀកផ្គង់ផ្គត់សោះខ្មាសគេ ។
កូនអើយគិតឱ្យគ្រប់ រៀងរាល់យប់កុំទំនេរ
ដាងដេកលក់ទទេ យល់សប្ដិដេរបិសាចក្រៅ ។
ទម្លាប់មាត់មមើ ស្រែកថាយើៗអៅៗ
បោរខ្លាំងខ្មោចបិត្តខ្មៅ ហៅមេខ្មែរវៃឱ្យខ្មុក ។
៦០- ដេកផ្អៀងដាងអង្គុយ ល្ងាល្ងាន់ល្ងុយកុំទ្រាំងក់
ពីល្ងាចដេកកុំលក់ មាន់រងាវដក់ស៊ីម្លូស្លា ។
ដាងល្ងឹតឥតអំពើ ឥតអ្វីធ្វើស្វូត្រធមិអាចិ
បើច្បាស់វិបស្សនា ស្មាស្មាធិ៍ស្ម៊ឹងប្រឹងឱ្យស្មោះ ។
គង់ខ្នើយដេកកើយស្មុគ គ្រប់ឱ្យសុខស្វូត្រអម្បោះ
កុំដាក់ដោយគៀនកោះ អស់នឹងសត្វកណ្ដៀរកោរ ។
កណ្ដុរកន្លាតកាត់ ដល់កំណាត់ខាងដេរខោ
ជួនកាលមានអាបោរ លលបលួចលីទៅបាត់ ។
កុំដាក់ឆ្ងាយប្រយោល ទុកជាបោលមិនប្រយ័ត្ន



Websites: WatKhmers.org or WatKhemaraRatanaRam.org

ប្រយោជន៍យប់យាមស្ងាត់ បង្កាត់ភ្លើងបង្គោលគោ ។

៦៩- បង្ការក្រែងមូសខាំ ត្រូវបំណាំខ្យល់ធំនោរ

បាយកកផ្អុកម្ហូបជោរ ឱ្យអាលោស៊ីបាំសេះ ។

កំណើតផ្ដៃញីឈ្មោល ដេកបំណូលតែនឹងផេះ

រៀនប្រើមើលបំណោះ រិះបំណាំតាមកិរិយា ។

ទោះប្រើកូនតូចធំ ឬប្រើខ្ញុំឱ្យធ្វើការ

ធ្វើកលយល់ប្រាជ្ញា អាណាហ៊ានប្រើទៅឆ្ងាយ ។

អាខ្លាចប្រើតែជិត ឥតគំនិតប្រើវៀងអាយ

ខុសម្ដងកុំជេរម្ដាយ ពេលដល់បាយកុំនាំឈ្លោះ ។

មនុស្សឃ្លានវាហ៊ានធ្លើយ ស៊ីរួចហើយបន្ទោសបុះ

បានផ្អែតប៉េងពេញពោះ ស្ដីខុសត្រូវមិនស្ទូវខឹង ។

៧០- កូនអើយពាក្យអាពុក បំណាំទុកពីត្រឹមណឹង

ធ្វើប្រុសឱ្យខំប្រឹង រៀនឱ្យដឹងស្គាល់ពុតស្រី ។

មារយាទនិងមាយា ម៉្យាងបិត្តជាបេះដូងប្ដី



Websites: WatKhmers.org or WatKhemaraRatanaRam.org

ប្ដូរស្លាប់រស់វាហើ យកពីរបីនេះមិនបាន ។
កុំលោភច្រើនៗព្រួយ យកតែមួយសុខក្សេមក្សាន្ត
បិត្តស្រីទាំងប៉ុន្មាន ហ៊ានប្រមូលម៉ៅមិនខុស ។
មិនខ្វបគ្រប់តែស្រី ល្អពីរបីជឿចាំចុះ
ជាតិស្រីលោភលើប្រុស តោះមិនខុសស្រីណាមួយ ។
ខ្លាំងខ្សោយកុំឱ្យខ្វល់ ទោះឆ្ងាយហត់កុំរំអួយ
ធ្វើប្រុសតែងតែព្រួយ ស្រីមិនជួយកុំត្អូញត្អែរ ។
ខ្លួនខ្លាំងកុំគិតខ្លាច ស្រីៗកាចស្លូតដោយខែ
រដូវធ្វើស្រូវស្រែ បែបប៉ែប្រែស្ដីលើប្រុស ។

៧៤- ខែស្ទួងនិងខែប្រួត កាចរហូតដល់ខែបុស្ស
ខែបែនបោករលស់ រលីងអស់អំពីដី ។
ជញ្ជូនដាក់ជង្រុក ពូជពេញទុកស្បោងពីរបី
ដំណើបបបួនជប់ស្អី ស្រីៗស្លូតហើយខែនឹង ។
ស្លូតផុតនៅខែមាឃ ស្ដីធ្ងន់ពាក្យមិនស្ងួវទឹង



Websites: WatKhmers.org or WatKhemaraRatanaRam.org

បើប្រុសៗមិនដឹង ប្រឹងតែព្រួតស្អប់ស្រីៗ ។
ម៉្យាងទៀតមារយាទខូច មាយាបេះក្រូចមាយាដកខ្ទី
មានប្រុសសាហាយថ្មី រឹតថ្នមប្ដីមិនឱ្យអាក់ ។
អីអើតែមាត់ក្រៅ ចិត្តមួម៉ៅគ្មានត្រជាក់
ត្រីសាច់ល្អល្អបលាក់ ដាក់តែឆ្អឹងឱ្យឯងស៊ី ។
៨០- បញ្ជោរបេះបញ្ជើ បញ្ឆោតប្រើឯងវក់វី
វរវឹកព្រួតប្រុសពីរ ស៊ីទាល់ងាប់គាប់សងខាង ។
មួយទៀតផឹតកំលោះ ស្រឡាញ់ស្មោះស្ម័គ្រអស់យ៉ាង
លោមប្ដីលាសំណាង ទាស់ក្មេងក្អាងទារសំបុត្រ ។
បើប្ដីមិនព្រមលែង លបជំទែងជំទយរត់
មួយទៀតខូចបំផុត មត់ឱ្យប្រុសសម្លាប់ប្ដី ។
ម៉្យាងទៀតមារយាទជា មានច្រើនគ្នាក្នុងលោកីយ៍
ប្រាកដពេញជាស្រី ប្រុសពីរបីស្នាលាកម្ម ។
៨៥- ស្លាប់រស់មួយនិងមួយ មិនចង់ព្រួយយកប្រុសប្រាំ


Websites: WatKhmers.org or WatKhemaraRatanaRam.org

ប្ដីស្លាប់បួនដប់ឆ្នាំ ចាំសីលទានមិនមានទៀត ។
ធ្វើបុណ្យផ្សងសច្ចា សុំប្រាថ្នាជួបរាល់ជាតិ
អុបធូបដេកឱបធាតុ កណ្ដៀតចោកោរកាន់ទុក្ខ ។
និយាយពីពុតប្រុស ចូរចាំចុះជាទំនុក
ដំណាតទៅមុខ អាពុកប្រាប់ឱ្យស្រីចាំ ។
ប្រពន្ធមួយមិនស្កប់ ប្រពន្ធដប់គ្រាន់តែស្កាំ
កាចស្លូតរហូតឆ្នាំ រុាំជរាបរាល់រូបា ។
កាចម៉្យាងខាងល្ងាចព្រឹក រឿងបាយទឹកថ្នាំម្លូស្លា
កាចម៉្យាងរឿងធ្វើការ ម៉្យាងទៀតណារឿងប្របណ្ឌ ។
៩០- ប្រជុំជាតិចិត្តប្រុស ត្រូវនិងខុសជាកំណាន់
គំនិតល្អសំខាន់ ប្រកាន់មើលឥរិយាបថ ។
ប្របណ្ឌរាវរាល់ឈ្មោះ ច្រើនកើតឈ្លោះទៅជាខ្សត់
មួយឃើញជាក់ប្រាកដ ប្រកៀកចាប់ធ្វើទោសបាន ។
លកលៃតែខាងប្រុស ប្រពន្ធខុសបង្អង់ខាន



Websites: WatKhmers.org or WatKhemaraRatanaRam.org

ខូចម្ដងខាតប៉ុន្មាន រាប់អានឱបក្រសោបទៀត ។
មួយលកលៃទាំងពីរ នៅរកស៊ីដោយសារញាតិ
ស្រីមាយាឥតមារយាទ ស្មាលាជាតិមិនឱ្យថ្កូន ។
ប្រាប់ណ្ដាទាំងបីបទ គួរគួបកត់ទុកក្នុងខ្លួន
លក់ពីរពេញបំនួន គួនគុំទុកយកជាច្បាប់ ។
៩៥- ប្រាប់ណ្ដាហើយយកទៀត ហៅផ្ដួជាតិមារយាទអាប់
កូនណាយកតម្រាប់ ស្លាប់នឹងស្រីៗមើលងាយ
ទោសតិចកុំទាញផ្សំ ឃើញមិនបំកុំនិយាយ
កុំចាប់ស្មើររវើរវាយ នាំឱ្យវល់អំពល់ចិត្ត ។
ពុតប្រុសនិងពុតស្រី ចប់សេចក្ដីពីក្បត់ផិត
រៀងរើសណាសុខចិត្ត គិតសំគាល់រាល់រូបកាយ ។
បើមានកូនក្រមុំ គួរតែកុំបណ្ដោយឆ្ងាយ
ឱ្យមើលនាយមើលអាយ ស្រេចនៅម្ដាយរក្សាកូន ។
ប្រយ័ត្នកុំឱ្យឃ្លាត ភ្លាត់មារយាទមិនសុទ្ធស្ងួន



Websites: WatKhmers.org or WatKhemaraRatanaRam.org

កុំទុកចិត្តបងប្អូន ជីដូនមួយជួយរក្សា ។

១០០- ក្រមុំមានម្រាក់មិត្រ មេមួយគិតនាំកិច្ចការ

កុំជឿចិត្តនរណា មើលកិរិយានៃកូនឯង ។

ទោះស្ងួងដកយប់ថ្ងៃ ដើរយកដៃដាប់សង្វែង

ប្រុសខូចបលួចបន្លែង តែទាស់ភ្នែកបែកមេបា ។

ប្រើនណាស់តែសែនខ្មោប ក្ដើ៍អសោបផុតអាសា

នាំកូនឡើងសាលា គេថាឱ្យជំងឺចិត្ត ។

បើមានកូនប្រសា មិនទាន់ការគួរឱ្យប្រិត

កុំឱ្យបម្រើផ្អិត អាណិតវាៗសងគុណ ។

យប់ថ្ងៃចូលប្រតិបត្តិ គាតក្រវាត់រត់វែកពុន

អាចនឹងប្រើនជឿមុន ស៊ុនអំពីឱពុកម្ដាយ ។

១០៤- រក្សាកូនប្រពន្ធ រកទ្រព្យធនបង់ធូរបាយ

ជួញជិតគំនិតឆ្ងាយ ជួញរៀងអាយរក្សាគុណ ។

អំពើបាបកុំរៀន កុំអៀនប្រៀនក្នុងការបុណ្យ



Websites: WatKhmers.org or WatKhemaraRatanaRam.org

លាងទោសបេញជាមុន ទើបធ្វើបុណ្យបម្រើនផល ។
បើនឹងបង់គង់ទ្រព្យ កុំទម្លាប់សាងអកុសល
របិញរបុញរៀបកាបកល់ ទេវតាផ្ដល់ផ្ដាប់ធនធាន ។
កុំឈ្នានីសអ្នកខ្សត់ កុំបំភ្លាត់ទ្រព្យអ្នកមាន
បើខ្លួនខ្សត់អត់ឃ្លាន រៀនតែរកតាមទៀតត្រង់ ។
ជួញខាតកុំឈប់ខាន បើបង់បាតកុំខ្លាចបង់
ខ្លាចបាត់ឱ្យធ្វិតធ្វង់ ប្រុងថែទាំឱ្យមាំមួន ។
១១០- កុំភ្លើធ្វើជាភ្លេច ភ្លាត់បន្តិចខ្លាចក្រែងជួន
ក្រែងចោរចូលមកពួន លួនលបលួចយកទ្រព្យទៅ ។
ប្រហែសតែងតែបាត់ ប្រុងប្រយ័ត្នតែងតែនៅ
គិតសព្វគ្រប់ដោយផ្លូវ សូវទ្រាំទ្រើយកុំទ្រាំក្រ ។
នៅផ្ទះស្រះរបង របាបងឱ្យជាប់ល្អ
ប្រើប្រាស់ខ្ញុំកំដរ ឱ្យបរិភោគដោយខ្លួនឯង ។
នឹងប្រើទៅហៅមក កុំគំហកយកកំហែង



Websites: WatKhmers.org or WatKhemaraRatanaRam.org

កុំហាឡើងហងឯង ក្រែងកំហល់ទល់កំហឹង ។

កុំហួសពាក្យសម្ដី ការអ្វីៗឱ្យបេះប្លឹង

កុំប្រើព្រួតលើប្រឹង ក្រែងកើតខឹងវានាំខាត ។

១១៩- មនុស្សខឹងប្រើនៗខុស មនុស្សប្រើនឈ្លោះប្រើនប្រមាថ

ការល្អប្រើនត្រូវខ្នាត យើងបង់ស្អាតកុំខ្លាបយូរ ។

បង់ប្រាជ្ញឱ្យខំប្រឹង បងក្បិនតឹងរកស៊ីធូរ

គំនិតមុនគំនូរ រៀនមានគ្រូមានគេរាប់ ។

បម្រើឪពុកម្ដាយ អ្នកនៅឆ្ងាយគេប្រើនគាប់

អ្នកណាបម្រើខ្ជាប់ ធ្លាប់តែខុសមិនដែលត្រូវ ។

ជាតិមនុស្សទោះខ្ពស់ទាប មិនបោលភាពពីម៉ែឪ

ពាក្យមនុស្សវែងជាងផ្លូវ ស្រូវប្រើនខ្លួបខ្វូបអង្ករ ។

របស់ទ្រព្យថោកថ្លៃ ទុកសំបៃលៃឱ្យល្អ

អុងអាងពាងក្រឡ ត្រជរទិញកុំឱ្យខ្វះ ។

១២០- កើតមកខ្លួនជារាស្ត្រ ក្រប្រាក់មាសឱ្យមានខ្នាស



Websites: WatKhmers.org or WatKhemaraRatanaRam.org

សារពើគ្រឿងប្រើប្រាស់ ឱ្យមានចាស់ឱ្យមានថ្មី ។
ពូថៅដឹងកាំបិត ពន្លាកទិ្វតចបចវែងខ្លី
ខ្សែស្រះគោក្របី ឫស្សីផ្ដៅកាប់សង្រែក ។
ការងាយកុំឱ្យក្រ អាក្រក់ល្អមានដោយខ្សែក
ថ្ងៃនេះរបេះបាក់បែក ស្អែកខំរើធ្វើជាធាប់ ។
ឈ្មោះការប្រើលើដី កុំបាំស្រីតឿនប្រើប្រាប់
ឱ្យមានគ្រប់ប្រដាប់ សម្រាប់រាល់ឱ្យសល់ប្រើ ។
កុំខ្ជិលល្ងង់ខ្លៅពេក ឱ្យបេះដេកឱ្យបេះដើរ
បេះសព្វគាប់ប្រសើរ កុំបង់ហើរហួសភាពខ្លួន ។
បង់ក្ដីឱ្យរៀនច្បាប់ រស់និងស្លាប់ឱ្យបេះក្បួន
បេះអ្វីបេះឱ្យមួន កុំបន្លំផ្សំនឹងគេ ។
១២៥- កុំដេកបាំសំណាង កុំក្អេងក្អាងបាំបុព្វេ
ខំរកកុំទំនេរ វេរៀនរិះបេះឱ្យគ្រប់ ។
នឹងដើរស្វែងរកផល មិនទាន់ដល់កុំអាលឈប់



Websites: WatKhmers.org or WatKhemaraRatanaRam.org

ឈានខ្លាំងពេកជំពប់ បើដេកយប់ឱ្យស្គាល់យាម ។
កុំដេកយូរទ្រមឹក លក់ហួសព្រឹកខុសទំនៀម
តែភ្លឺឡើងភ្ញាក់ភ្លាម ព្របហាមឡើងក្រោកធ្វើការ ។
ជាតិមនុស្សទោះប្រុសស្រី វាស្រួមន្ត្រីជាធម្មតា
ពេលព្រឹកតែងឧស្សាហ៍ ថ្ងៃក្ដៅល្ហាខ្ជិលល្អិតផ្អឹង ។

១៣០- បង់ធំទំពីតូច បើខ្លាចខូចកុំឆាប់ខឹង
ការអ្វីឱ្យបេះប្ញឹង កុំប្រឹងផុះតាមជំរឺ ។
កុំបង់ខ្ពស់ស្មើមេឃ កុំឱនពេកអាប់រាសី
ទោះដើរនិយាយស្ដី សៃឱ្យល្មមតែគួរសម ។
យល់ឆ្ងាយកុំណាយគិត ទោះយល់ជិតកុំអាលទំ
មិនជាក់មើលឱ្យបំ ក្រែងប្រឡំសជាខ្មៅ ។
ទម្លាប់ធំជាងច្បាប់ បើរៀនគ្រាប់កុំគ្រាប់ខ្លៅ
គ្រាប់ប្រាជ្ញអាចប្រដៅ ស្ដីកូនចៅស្ដីឱ្យស្មោះ ។
ស្ទឹងស្ទើលសិល្ប៍របៀន ឱ្យគេរៀនកុំឱ្យអស់



Websites: WatKhmers.org or WatKhemaraRatanaRam.org

ស្រឡាញ់កុំញ៉េះញ៉ោះ បើខឹងទាស់កុំឱ្យទាយ ។

១៣៩- ផ្លែព្រះកុំព្រួយពេក ឃើញផ្លែដេកកុំមើលងាយ
កំណាប់ដប់សំពាយ កុំនិយាយប្រាប់សំឡាញ់ ។
សំឡឹងមើលឱ្យសព្វ បើនឹងស្អប់កុំអាលបាញ់
ក្ដីឈ្នះគេបុះបាញ់ កុំក្នាញ់តាមផ្ដន្ទាទៀត ។
បើខឹងកុំរំលោភ បើនឹងល្មោភឱ្យល្មមមាឌ
កុំរមាត់ក្រែងភ្លាត់ស្មៀត វាគប្ឫសវង់ផុងគំនិត ។
កំណើតអាក្រក់ល្អ មាននិងក្រពីគំនិត
ពីកាលបុព្វពិត ងងឹតពេកមើលមិនយល់ ។
ដាំដូងឱ្យទំរែ ចង់ស៊ីផ្លែឱ្យដុតគល់
បើដូនសំណាងដល់ វវល់តែស៊ីធ្លាញ់ពិសា ។

១៤០- ប្រាជ្ញប្រិតប្រៀបប្រដៅ ចូរកូនចៅពិចារណា
រំពឹងក្នុងប្រាជ្ញា ស្រាយបញ្ហានេះឱ្យដឹង ។
នេះច្បាប់កេរកាលថ្មី អស់សេចក្ដីតែប៉ុណ្ណឹង



Websites: WatKhmers.org or WatKhemaraRatanaRam.org

កូនប្រុសអ្នកខំប្រឹង សំឡឹងចាំតទៅមុខ ។
ពីឆ្នាំប តទៅ ខំធ្វើស្រែវដាក់ជង្រុក
អាសូរពាក្យអាពុក ទុកឱ្យកូនចៅគ្រប់គ្នា ។
អាពុកកាន់តែចាស់ ស្ដាយខ្លួនណាស់ចូលជរា
ពាក្យពិតប្រាំរយឃ្លា ជាសូរេបម្លេះឯងហោង ។
អ្នកប្រាជ្ញភិរម្យល្បី លើកច្បាប់ថ្មីអស់ល្បត់ល្បង
ឈ្មោះ អ៊ូ ហៅ ង៉ុយ ផង បងជាច្បាប់សម្រាប់ជន ។
១៤៥- ខ្ញុំសូមផ្សងសច្ចា កើតជាតិណាសូមមានបុណ្យ
មូលកូនមូលប្រពន្ធ ធនសម្បត្តិសម្បូរបាយ ។
ស្មាលាក្រលំបាក សូមជៀសបាកបតុរាបាយ
សូមល្អពង្សរូបកាយ កុំឱ្យឆ្ងាយពីព្រះពុទ្ធ ។
ប្រាជ្ញាកុំទើសទាល់ បេះអាចិធមិឱ្យមាំមុត
សូមជាប់សីលបរិសុទ្ធ រលត់ទុក្ខសោករោគភ័យ ។
អានិសង្សបុណ្យខ្ញុំបាន សាងប៉ុន្មានក្នុងលោកីយ៍


Websites: WatKhmers.org or WatKhemaraRatanaRam.org

សម្បត្តិសួគ៌ាល័យ កុំបីឃ្លាតវាតវែងឆ្ងាយ ។

១៤៩ ពីជាតិនេះទៅមុខ មូលអាពុកជួបមូលម្ដាយ

បងប្អូនកុំខ្វាត់ខ្វាយ អធិប្បាយបែងចប់ឯវ៉ិ ។



Websites: WatKhmers.org or WatKhemaraRatanaRam.org

# សេចក្តីរំលឹកដាស់តឿន

អ្នកព្រះភិរម្យភាសា អ៊ូ		លើកដៃទាំងគូប្រណម្យផ្ទង់
បង្គំព្រះពុទ្ធគ្រប់ព្រះអង្គ		ព្រះធម៌ព្រះសង្ឃប្រសើរសាយ ។
ព្រះគុណគ្រូឧបជ្ឈាយាចារ្យ		មាតាបិតាបង្កើតកាយ
បង្កើតប្រាជ្ញាថ្លាវែងឆ្ងាយ		ខ្ញុំសូមអធិប្បាយបែកពាក្យជូន ។
ព្រះពុទ្ធសករាជព្រះសាសនា		អតិកន្តាកន្លងធួន
ពីរពាន់បួនរយបិតសិបបួន		ជួនខែនិងថ្ងៃគ្មានកន្លង ។
ដើមឆ្នាំមមែក្នុងត្រីស័ក		ពិសាខភ្លៀងធ្លាក់កាត់ទឹកម្តង
មួយរោចថ្ងៃសៅរ៍កើតសៅហ្មង		ឮពាក្យអ្នកផងទាស់ទែងគ្នា ។
មិនបានកាប់ចាក់ដល់បាក់បែក		ថ្ងៃនេះជជែកថ្ងៃស្អែកជា
ចាក់ដោតរាលរោលពោលពណ៌នា		និន្ទាដៀលត្មះចាស់បុរាណ ។
ពួកចាស់ដៀលត្មះអ្នកប្រាជ្ញថ្មី		រឿងធម៌បាលីស្តីប្រមាណ
ប្រមាថទៅមកមិនឈប់ខាន		ហាមប្រាមមិនបានមិនបាត់មាត់ ។


Websites: WatKhmers.org or WatKhemaraRatanaRam.org

ព្រះធម៌ព្រះពុទ្ធតែមួយអង្គ        លោកសង្ឃបួសរៀនមានដោយវត្ត
សង្ឃខ្លះបេះស្មើរមិនចាំស្ទាត់        ភ្លើៗសូត្រភ្លាត់មិនត្រូវខ្យល់ ។
គេប្រាប់ថាខុសប្រកាន់ខឹង        មិនដឹងថាខ្លួនរៀនមិនដល់
មិនដែលសួរគេព្រោះមិនឆ្ងល់        សម្គាល់ថាខ្លួនត្រូវមិនខុស ។
អ្នកប្រាជ្ញលោកសូត្របំបាលី        ថាគេធម៌ថ្មីស្ដីបន្តុះ
បន្ទោសទៅមកឆ្លើយឆ្លងឈ្លោះ        មិនព្រមបំណុះខុសបំណាំ ។
១០- បំណែកបំណោះបេះរាល់ខ្លួន        បារាជិកបួនវិន័យប្រាំ
មហាវគ្គចុល្លវគ្គអាទិកម្ម        ព្រះអង្គគ្មានផ្ដាំឱ្យឈ្លោះគ្នា ។
ផ្ដាំឱ្យតែកាន់សិក្ខាបទ        អ្នកបួសរាល់វត្តត្រូវសាមគ្គា
ព្រះពុទ្ធរូបរាល់វិហារ        វន្ទាគោរពរាល់យប់ថ្ងៃ ។
នមស្ការបង្គំធម៌បីបទ        សូត្របាហបមាត់ញឿយជើងដៃ
មិនដឹងប្រាកដរតនត្រ័យ        មិនបេះសង្ស័យសួរអ្នកណា ។
អ្នកប្រាជ្ញលោកសូត្របំបាលី        ប្រែចេញសេចក្ដីឱ្យពិស្ដារ



Websites: WatKhmers.org or WatKhemaraRatanaRam.org

អ្នកខ្លៅមិនស្ដាប់តាមពុទ្ធដីកា គេថាខ្លួនខុសប្រកាន់ទឹង ។
ធម៌សម្មុទ្ទេស្សូត្រលាន់ៗ ព្រះពុទ្ធរយពាន់ខ្លះមិនដឹង
ជឿជាក់ថាបេះចប់ប៉ុណ្ណឹង មិនប្រឹងរៀនប្រែបកបរិយាយ ។
១៥- បេះហើយមិនដឹងថាខ្លួនខុស មិនព្រមបំណុះអ្នកប្រាជ្ញប្រាយ
បាលីប្រទ្បំពាក្យនិស្រាយ នឹងស្ដាយបែបបាស់មិនផ្លាស់បេញ ។
គេថាស្វូត្រធម៌មិនបេះប្រែ បានបុណ្យខ្លះដែរតែមិនពេញ
បើបេះប្រែផងបានបំណេញ ខ្លួនរឹតទន្ទេញតែបែបបាស់ ។
បបេសទទឹងរឹងជជែក ប្រកឹងប្រកែកប្រក្លូតម្នះ(៣)
ម្នៅៗ(២)សត្រូវនឹងធម៌ព្រះ ជាតិក្រោយក្រឡាស់ជាល្ងង់ខ្លៅ ។
មានកាលត្រឡប់ជាគថ្លង់ មម៉េងមម៉ងឆ្កួតម្លូម៉ៅ
ពីព្រោះមិនស្ដាប់ប្រាជ្ញប្រដៅ ហ្នឹងហៅបេះហើយមិនប្រសប់ ។
ប្រសិនបើឱនខ្លួនខ្វបខ្វាប អ្នកប្រាជ្ញកាលណាលោកនឹងស្អប់

(៣) ដែលត្រឹមត្រូវគឺៈ មានៈ- មិនទៅ ៗ ប៉ុន្តែនេះ និយមតាមសម្មស្សុកាព្យ ។



Websites: WatKhmers.org or WatKhemaraRatanaRam.org

ធមិអាចិអ្នកណានឹងបេះបប់ កុំកាន់ទម្លាប់ទម្លោយខ្លួន ។

២០- ទម្លាក់ឱ្យទាបសុភាពវ័យ ព្រះសូត្រវិន័យធំជាងក្បួន

ព្រះអភិធម្មជាមាំមួន នេះហើយប្រធួនគួររៀនទៀត ។

ពាក្យពីបុរាណជាពាក្យងាយ ពាក្យក្បួនទូលាយស្រណុកជ្រៀត

ឯពាក្យគម្ពីរទីបង្អៀត គួរឆ្លៀតជ្រើសរកយកឱ្យបាន ។

ឱ្យបែកគំនិតគិតច្រើនផ្លូវ មួយខុសមួយត្រូវជាពីរស្ពាន

គេប្រាប់ថាខុសគួរឈប់ខាន ឃើញត្រូវប៉ុន្មានប្រមូលយក ។

ព្រះឱស្ឋព្រះអង្គទ្រង់ទេសនា អ្នកប្រាជ្ញបែងបារបងទុកមក

ព្រះសូត្រវិន័យលោកលៃលក ប្រែសព្ទសៀតសឹកច្រើនប្រការ ។

ពាក្យពិតប្រាកដបទបាលី ប្រែចេញសេចក្តីឃើញពិស្តារ

គួរស្តាប់ឱ្យស្តែងសិនសុំថា កុំអាងតម្រាតម្រាប់ចាស់ ។

២៤- តម្រាយបុរាណយូរអង្វែង មិនលែងប្រទ្បំមានលើសខ្វះ

អ្នកប្រាជ្ញជំនុំឃើញខុសណាស់ បោលខ្លះទុកខ្លះដោយពិស្តារ ។



Websites: WatKhmers.org or WatKhemaraRatanaRam.org

យ៉ាងធមិ "តិរោក" ពីបុរាណ មិនដឹងជាបានពីគ្រូណា
សូត្រលាយចម្រុះខុសអក្ខរា មិនបានជាការប្រយោជន៍អ្វី ។
អ្នកប្រាជ្ញឃើញខុសប្រើនអន្លើ រុះរើរៀបចំផ្សំបាលី
អ្នកខ្លៅហៅធមិតិរោកថ្មី សំដីបែបឡូកចំអកខឹង ។
សង្ខេបរឿងសូត្រធមិត្រូវខុស កូនចៅប្រុសៗគួរខំប្រឹង
ប្រឹបរកអ្នកប្រាជ្ញប្រិតឱ្យដឹង សម្លឹងអក្ខរាឱ្យប្រាកដ ។
ប្រការមួយទៀតចាស់ជាន់មុន ធ្វើបុណ្យអភិសេកបែបប្រើនបទ
ប្រើនបែបរាប់អានគ្មានកំណត់ សន្មតថាធ្វើតាមបុរាណ ។
៣០- អាចារ្យមួយប៉ែកអភិសេកខ្ទិល បង្វិលពពិលរំពេចបាន
អាចារ្យមួយថាធ្វើតាមដាន លំអានគម្ពីរបឋមត្រាស់ ។
ទេសទុសជាតក៏ចប់អភិសេក ព្រឹកស្អែករៀបចំមធុបាយាស
មានមារលើកពលច្បាំងដេរដាស ធ្វើប្រាស់ត្រឡប់ក្រោយជាមុន ។
បើធ្វើឱ្យត្រូវតាមសាស្ត្រា ឆាងឆាថសុជាតាគេមានគុណ



Websites: WatKhmers.org or WatKhemaraRatanaRam.org

ថ្វាយមធុបាយាសព្រះមានបុណ្យ    និមន្តទៅផ្សងបីដងត្រាស់ ។
ទេវតាផ្អើលបុះពេញផែនដី    គ្រប់ទិសប្រាំបីមីរដេរដាស
កក្រើកញាប់ញ័រទាំងអាកាស    អរណាស់ថ្វាយសព្ទសាធុការ ។
ហេតុនេះអ្នកបេះបាំនិទាន    ធ្វើរោងធ្វើរានថ្វាយទេវតា
អ្នកប្រាជ្ញបេះប្មីស្រដីថា    អាចារ្យនាំធ្វើខាតប្រយោជន៍ ។
៣៤- អាកាសទេវតានៅស្ថានខ្ពស់    គេខ្ពើមជាតិមនុស្សក្លិនអសោច
ឱស្សាហ៍ដាក់នំឱ្យហិនហោច    បំណោញស្រមោចចោមរោមស៊ី ។
អាចារ្យមួយទៀតបេះរៀបចំ    ប្រណាម្យសំពះក្រុងពាលី
ព្រះឥសូរព្រះនារាយណ៍មានរិទ្ធី    ពេញទីបោលត្រៃសរណាគមន៍ ។
បំណីបំណែកបែកដាក់ពៃ    បំណោញបានឆ្អែវាស៊ីនំ
នាងហ៊ឹងធរណីថាជាធំ    សូមសុំទឹកដីសាងកុសល ។
អាចារ្យជាន់ចាស់ដោះសង្ស័យ    ថារតនត្រ័យគេតម្កល់
តម្កើងលើកឡើងជាដើមផល    ប្ដឹងដល់ទេវតាជាសាក្សី ។



Websites: WatKhmers.org or WatKhemaraRatanaRam.org

សសង្ខារិករលឹកគុណ ធ្វើបុណ្យអភិសេកព្រះពុទ្ធថ្មី
បូជាភ្ញីផ្កាស្លាបារី គ្រប់ទិសប្រាំបីសឹងឱ្យមាន ។
៤០- អភិសេកព្រះពុទ្ធតាំងកសាង តំណាងព្រះពុទ្ធដ៏ទ្រង់ញាណ
រំលឹកទេវតាជាប្រធាន ប្រាថ្នានិព្វានស្ថានផុតទុក្ខ ។
ថាបើទេវតាខ្ចីមបំណី ស្អប់ស្លាបារីមិនចង់ជក់
បិសាចភ្លើៗមិនលែងភ្លក់ អារុក្ខទេវតាមិនលែងសោយ ។
នំនែកបំណីឆ្អែតស្អប់ស្អល់ សេសសល់បានប្រេតគ្នាស៊ីក្រោយ
ស៊ីគ្រាន់រួចរស់ព្រោះគេឱ្យ បានដោយមគ្គផលកុសលដារ ។
លោកសូត្រតិរោកតែរាល់ព្រឹក យំកិញ្ចិប្រួបទឹកថែមយថា
បញ្ជូនអានិសង្សដល់ដូនតា ប្រាថ្នាដួបម្តេចក៏សឹងបាន ។
ក្រែងដូនតាណាទៅជាប្រេត ឬមួយអណ្តែតជាតិរច្ឆាន
លើសខ្វះប៉ុណ្ណោះខុសប៉ុន្មាន រាប់អានទេវតាប្រាថ្នាសុខ ។
៤៥- ថាបើទេវតាមិនព្រមសោយ កុំឱ្យតែខុសបុះនរក



Websites: WatKhmers.org or WatKhemaraRatanaRam.org

នរូកើតភាន់ផុតក្នុងភក់ វីវក់ក្នុងវាលវដ្តសង្សារ ។
មិនដាច់សង្ស័យដូចអរហត្ត លោកកាត់កាមគុណនិងតណ្ហា
ត្រង់ភ្លឹងមិនងាកពឹងទេវតា ប្រាថ្នានិព្វានគ្មានត្រឡប់ ។
ឃើញធ្លងមិនផុតភពទាំងបី ធម៌អាថ៌បាលីបេះមិនចប់
មិនបោលសីល ៥ កម្មបថ ១០ ភររៀបឱ្យសព្វកុំឱ្យសល់ ។
សម្បត្តិសួគ៌សុខកើតពីទាន ឈោងយកនិព្វានឈានមិនដល់
មិនដើរហួសសោតាមគ្គផល តម្កល់និព្វានទុកដោយឡែក ។
នេះចប់ចម្លើយអ្នកប្រាជ្ញចាស់ ប្រាជ្ញថ្មីចង់ឈ្នះប្រឹងប្រកែក
ប្រាកដនិព្វានជាស្ថានឯក បំណែកសោតាក្នុងតែបាន ។
៤០- ជ្រះថ្លាធ្វើបុណ្យក៏ធ្វើបុះ ទានណាខាតខុសត្រូវឱ្យខាន
អារុក្ខអារក្ខកុំរាប់អាន ជាស្ថានទាបថោករកធ្វើអ្វី ។
សង្ខេបរឿងសូត្រធម៌ត្រូវខុស កូនចៅស្ដាប់ចុះទាំងប្រុសស្រី
អ្នកប្រាជ្ញពួកចាស់និងពួកថ្មី គប្បីចូលចិត្តជឿពួកណា ។



Websites: WatKhmers.org or WatKhemaraRatanaRam.org

បើរឿងសូត្រធម៌អាថ៌បាលី គួរចូលប្រាជ្ញថ្មីខំសិក្សា
ប្រយោគប្រធានមានមាត្រា រាជការបានធីប្រឡងជាប់ ។
ប្រាជ្ញចាស់ជាន់មុនធ្វើបុណ្យទាន ធ្វើរានទេវតាដោយសារធ្លាប់
អ្នកឆោតល្ងង់ខ្លៅគ្នាខ្លាចងាប់ អាចារ្យបង្គាប់គ្នាធ្វើទៅ ។
បើបែរជាខានមិនបានសុខ មិនបានធ្លាក់ចុះនរកជ្រៅ
បើធ្វើទេវតាមិនជ្រកនៅ ស្ពានគេសន្ធៀសន្ធឹងហោះ ។

៥៥- ហេតុនេះគួរគិតគួររំពឹង ជញ្ជឹងកុំឱ្យសល់បន្លោះ
ចាស់មុនមានគុណរាប់មិនអស់ មិនឱ្យចោលសោះក៏មិនបាន ។
គួរគិតឱ្យគ្រប់សព្វអន្លើ គួរធ្វើឬគួរបង្អង់ខាន
បើធ្វើមិនខាតបង់ប៉ុន្មាន បើខានក៏គ្មានទោសទាស់អ្វី ។
ប៉ុន្តែមិនបាត់ពាក្យចាក់ដោត ដ្បិតមនុស្សច្រើនឆោតទាំងប្រុសស្រី
ពេលថាធ្វើបុណ្យតាមប្រាជ្ញថ្មី អាយុថយខ្លីជាងជួនតា ។
ពាក្យនេះសង្ខេបស្លេះមួយប៉ែក មានឈ្មោះប្រកែកច្រើនប្រការ


Websites: WatKhmers.org or WatKhemaraRatanaRam.org

មិនចាំប្រាកដគម្ពីរណា ពោលថាទឹកដីនេះគ្មានគុណ ។
អ្នកប្រាជ្ញនាំឱ្យអ្នកខ្លៅឆ្ងល់ សាយសុសសួរដល់ពួកអ្នកមុន
អ្នកមួយវេវារវង់វែកពុន មិនទាន់ចូលស៊ុនស៊ប់ម្ខាងៗ ។
៦០- អ្នកក្រោយបណ្ដោយសួរអ្នកមុន ថាដីមានគុណប៉ុន្មានយ៉ាង
សម្គាល់គោលអ្វីជាតឹកតាង មានអាងឃើញក្នុងគម្ពីរណា ។
អ្នកម្ខាងថាអាងនរគរកាយ បរមត្ថអធិប្បាយក្នុងសាស្ត្រា
ធាតុទឹកត្ត ៤ អង្គអក្ខរា ជាគុណមាតាពីរដណ្ដប់ ។
ធាតុទឹករំលឹកពីសេម្ហ៍ វកំ យកនំ រហូតចប់
ធាតុដី កេសា មំសំ សព្វ បញ្ចប់ បិត្តំ គុណបិតា ។
អ្នកបេះបិដកឆ្លើយបីផង ថាតោះជាកងពួកកេសា
ហៅធមិអាចម៍តោមក៏ល្អើមល្អា អ្នកណារំលឹកគ្មានប្រយោជន៍ ។
អ្នកមួយថាភាវនាកុំឈប់ ថាទីអសុភផ្លូវអសោច
អសារឥតការស្លាប់ជាខ្មោច គេដុតឆេះខ្លោចគ្មានខ្លឹមសារ ។



Websites: WatKhmers.org or WatKhemaraRatanaRam.org

៦៥- គួរគិតកុំស្តាយកុំស្រណោះ | រូបរាងទាំងអស់ជាអនិច្ចា
អនិច្ចំមិនទៀងល្អៀងសង្ខារ | សង្ឃឹមរូបានេះមិនបាន ។
សរសៃសាច់ស្បែកសង្វេគគ្រប់ | ជាសាកអសុភកម្មដ្ឋាន
របស់ខាងក្នុងទាំងប៉ុន្មាន | មុខជាមិនខានរលាយបាត់ ។
ទឹកដីខាងក្រៅក៏មានគុណ | ព្រោះដីកើតមុនទើបកើតសត្វ
កើតសព្វរូបកាយអធិប្បាយកាត់ | លើកឡាត់លះឃ្លាឱ្យយ៉ាងខ្លី ។
គម្ពីរត្រៃភេទដើមសាសនា | ត្រៃយុគត្រៃតាគ្រប់ជាបី
ព្រះពុទ្ធបេញសាងអាងទឹកដី | សន្សំបារមីក្នុងភទ្ទកប្ប ។
ភទ្ទកប្បនេះមានព្រះពុទ្ធ ៥ | បានរៀនបេះចាំជាសណ្តាប់
សំដែងថាចុះនរកមួយកប្ប | លោកប្រាប់ថាព្រោះជេរទឹកដី ។
អ្នកម្ខាងថាអាងរៀនសាស្ត្រា | ប្រែអស់គាថាបទបាលី
ព្រះពុទ្ធទតគ្រប់ភពទាំងបី | ត្រង់គុណទឹកដីមិនឃើញមាន ។
កេសាអក្ខរាទាំង ៥ តួ | មិនគួរបើយកមកសន្និដ្ឋាន


Websites: WatKhmers.org or WatKhemaraRatanaRam.org

យើងបេះដឹងដែរតែមិនហ៊ាន
ដូចពោលបំពានហួសពុទ្ធដីកា ។
ពាក្យនេះអ្នកខ្លៅកើតសង្ស័យ
សព្វថ្ងៃនៅក្នុងឧបេក្ខា
មិនទាន់ដាច់ស្រេចទៅខាងណា
មិនឃើញពិស្ដារស្ដាប់មិនបាន ។
ម្យ៉ាងទៀតប្រាជ្ញថ្មីស្ដីដៀលត្មះ
បង្អាក់ថ្វាយព្រះថាឱ្យខាន
ដ្បិតព្រះមិនឆាន់នៅពេញបាន
របស់ប៉ុន្មានបានអាចារ្យ ។
របៀបរាប់បាត្រមានកន្សោង
មួយឈោងពីរឈោងហៅបាយដារ
បាយដាក់ហ្នឹងតើឱ្យអ្នកណា
អសារឥតការឥតប្រយោជន៍ ។

៧៤- ព្រះពុទ្ធមិនឆាន់មិនបេះស្ដី
យើងអាងបាលីឧទ្ទិសដល់
តម្កើងបង្អាក់លើតម្កល់
សេសសល់ប្រគេននេនសាមណេរ ។
សមណៈបួសរៀនមានសីលដប់
ប្រសប់ប្រសើរគ្រាន់បើដែរ
បញ្ជូនមគ្គផលដល់ឪម៉ែ
បង្វែរឧទ្ទិសតាមប្រាថ្នា ។
អ្នករេគំនិតគិតតែកាញ់
ចូលបទកំណាញ់ក្រៅតម្រា
ទុកស៊ីមាត់ឯងធ្លាញ់ពិសា
ខ្លាចបានអាចារ្យស៊ីខាតទុន ។



Websites: WatKhmers.org or WatKhemaraRatanaRam.org

អ្នកម្ខាងថាអាងដាក់ឱ្យប្រេត    ដោយហេតុគ្នាឃ្លានគ្នាហិនហោច

គ្នាស៊ីខ្ទុះឈាមក្លិនអសោច    បិចបោចបែកទានគ្នាស៊ីផង ។

ប្រេតត្រូវជាញាតិធមិតិរោក    គ្នាបានដើមមកព្រោះគេផ្សង

បានស៊ីដោយសារដារម្ដងៗ    បានជួបបំណងបំណាច់នឹក ។

៨០- បង្ហាត់ថ្វាយព្រះត្រូវបូជា    អាចារ្យវិន្នាសូត្ររំលឹក

ព្រះពុទ្ធមានគុណមុនលោកភិក្ខុ    បាយទឹកជាទានមានមគ្គផល ។

ម៉្យាងទៀតប្រាជ្ញថ្មីស្រដីផ្ដាច់    ថាពួនភ្នំខ្សាច់មិនបានបុណ្យ

ជីកដីលៀនភ្នែកវែកតត្រុន    ដឹងបានជាគុណប្រយោជន៍អ្វី ។

នាំគ្នាអុជធូបហែទក្សិណា    អាចារ្យដោះឆ្អិនខាងបាលី

ហើយមិនបេះធម៌បំបួសដី    មិនដឹងថាដីឆ្លើយថាម្ដេច ។

អ្នកមួយថាពួនភ្នំខ្សាច់ស្អាង    តំណាងចេតិយព្រះសរពេជ្ញ

ព្រះសារីរិកធាតុយើងមិនភ្លេច    ដ្បិតបុណ្យយើងតិចទៅមិនដល់ ។

បើធ្វើដោយវាលកណ្ដាលថ្ងៃ    គង់ជាប់និស្ស័យបានកុសល



Websites: WatKhmers.org or WatKhemaraRatanaRam.org

បើដើមពោធិ៍ពិតរឹតបានផល    តម្កល់ដើមពោធិ៍យកជាម្លប់ ។

៨៥- ពូនភ្នំតម្កើងពោធិព្រឹក្ស    រំលឹកដល់អង្គព្រះបមភព

ប្រះក្ដារ ៤ ផ្ទាំងបង្ខាំងផ្ទប់    កុំឱ្យកំពប់ហៀរហូរដី ។

បើបេះរំលឹកបានបុណ្យណាស់    ជឿចុះប្រាជ្ញចាស់កុំជឿថ្មី

ប្រាជ្ញចាស់ក៏បេះប្រែបាលី    បរលោកលោកីយ៍ក៏ចាស់ដឹង ។

ចាស់ម៉្យាងចាស់ពិតគំនិតពោល    ចាក់ដោតរោលរាលនាំក្មេងខឹង

ចាស់ម៉្យាងផឹកស្រាក្លាស្រវឹង    ចាស់ហ្នឹងហៅក្មេងក៏សឹងបាន ។

ចាស់ជាន់ពីមុនប្រើនខ្លាបច្បាប់    ធ្វើតាមតម្រាប់ចាស់បុរាណ

បុរីនគរធ្លាប់រាប់អាន    តែខានខ្លាបខុសក្បួនតម្រា ។

ប្រើនជឿតម្រាប់ក្បួនលោកីយ៍    មានកូនប្រុសស្រីត្រូវរៀបការ

សម្លាប់ជ្រូកមាន់ស៊ីហ៊ុហា    ផឹកស្រាសៀនភ្នែកជជែកឈ្លោះ ។

៩០- បណ្ដោយឱ្យយកគ្នាទទេ    មេបាធ្វើគេព្រែងមិនរស់

នាំកូនសែនខ្មោចអសោចឈ្មោះ    ពីព្រោះមានប្ដីមិនរៀបការ ។



Websites: WatKhmers.org or WatKhemaraRatanaRam.org

រៀបកិច្ចមង្គលមានច្រើនយ៉ាង
ពួកចាស់ច្រើនអាងក្បួនតម្រា
បើតាមតម្រាយព្រះសូត្រថា
មេបាតាំកូនចុះនរក ។
បុត្តទារស្ស សង្គហោ
ហ៏នោ គាមោ ធម៌អ្នកស្រុក
សង្គ្រោះកូនផ្ទុងទៅក្នុងភក់
ហ្នឹងហៅអាពុកពន្លិចកូន ។
បើធ្វើមង្គលឱ្យរួបបាប
រូបពៀរជរាបអស់តាដូន
មង្គលយ៉ាងល្អបរិសុទ្ធសូន្យ
ប្រមូលបងប្អូនស៊ីម្ហូបល្ហា ។
ជ្រូកមាន់កុំចាំបាច់សម្លាប់
តែសោកមានស្រាប់ទិញពីផ្សារ
ផ្សំកូនប្រុសស្រីគាល់មេបា
អាចារ្យប្រមូលអស់ចាស់ទុំ ។
៩៥- ប្រុសស្រីអង្គុយកាន់ពពិល
បង្វិលប្រាំបួនជណ្ដាប់ជុំ
ធ្វើកិច្ចមង្គលក្នុងជំនុំ
ផ្សំផ្គុំកូនប្រុសនិងកូនស្រី ។
ចាស់ៗធ្វើច្រើនធ្វើក្នុងឆោត
ចង់ឱ្យគេកោតនាលោកិយ៍
យើងធ្វើយ៉ាងតិចក្រឡេបខ្ចី
បានប្ដីប្រពន្ធដូចៗគ្នា ។
ហៅកូនសង្គ្រោះម្ដាយអាពុក
រួបទោសរួបទុក្ខអស់មឹងមា



Websites: WatKhmers.org or WatKhemaraRatanaRam.org

អាពុកសង្គ្រោះគ្មានវេរា អាវាហ៍វិវាហមង្គល ។
មិនគួរបង្គាប់ឱ្យកោរជុក ហេតុម្ដាយអាពុកនាំរវល់
អាចារ្យតែក្បួនឱ្យអំពល់ ពន្យល់អ្នកល្ងង់ឱ្យបង់ទ្រព្យ ។
អ្នកខ្ជិលគេជឿសីលមាំមួន ពាក្យក្បួនតម្រាគេមិនរាប់
គេថាមិនរស់ពីព្រោះឆ្លាប់ មិនងាប់ពីព្រោះមិនធ្វើធ្មេញ ។
១០០- យ៉ាងដូចបិនយួននៅដាក់ផ្សារ ស្រុកស្រែបំការក្រុងភ្នំពេញ
កើតឡើងដុះសក់មិនកោរវិញ រវល់ដូរទិញអង្គុយលក់ ។
ប៉ុន្តែជាតិបិនល្មោភស៊ុសាប់ តមដាប់មិនដែលស៊ុព្រហាក់
ខ្មែរៗប្រហែលខ្វះម្ទេសជ្រក់ ទូលស្រូវកន្ទក់ទៅដូរបិន ។
ហេតុតែជាខ្មែរសម្បុរខ្មៅ គំនិតគិតឆៅមិនសូវឆ្អិន
រកស៊ុមិនឆ្អែតជឿបែសិន អាបិកវាកិនទាវទាល់បាន ។
១កើតអស្សុជសម្លាប់មាន់ បំអិនគ្រប់គ្រាន់ដួសដាក់ចាន
រៀបសែនព្រះភូមិតាមបុរាណ ថាខានខុសក្បួនប្រពៃណី ។



Websites: WatKhmers.org or WatKhemaraRatanaRam.org

ហ្នឹងហៅចាស់ឆោតនាំក្មេងព្រើល ហែកមាត់មាន់មើលបង្កាពីរ
អាដែងព្រះភូមិមានឈ្មោលញី ថាសែនរកស៊ីបានផលស្រួរ ។

១០៩- មានជូនជូនតាទៅស្រុកប្រេត បណ្ដែតសំប៉ានប្រាំសំពៅ
សំពត់អារក្ខជួរខាងឪ ខាងម៉ែក៏ត្រូវមិនសូវខុស ។
ថ្វាយបេកថ្វាយស្រាជារង្វាន់ ខ្មោចចូលជិះជាន់រូបស្រីប្រុស
កូនចៅអើយជឿពុទ្ធដីកាបុះ រូបស្លាប់ពីព្រោះតែផលកម្ម ។
រូបសុខដោយសារតែផលបុណ្យ កាលជាតិពីមុនខ្ជាប់សីល ៥
ជាតិនេះអាយុអង្វែងឆ្នាំ កូនចៅអ្នកចាំជឿឱ្យជាក់ ។
ឱ្យបេះពិចារណាបិត្តឯងផង ស្ដាប់ធមិម្ដងៗគួរឱ្យភ្ញាក់
កុំផ្ញើរូបកាយនឹងអារក្ខ ក្រែងធ្លាក់ទៅក្នុងចតុរាបាយ ។
បើចង់អាយុវែងយឺនយូរ គោរពគុណគ្រូអាពុកម្ដាយ
បើចង់រកស៊ីសុខសប្បាយ ផ្ញើកាយនឹងគុណរតនត្រ័យ ។

១១០- នមស្ការបង្គំពេលល្ងាចព្រឹក ភាវនារំលឹករាល់យប់ថ្ងៃ


Websites: WatKhmers.org or WatKhemaraRatanaRam.org

កុំថាធម៌ណាថោកណាថ្លៃ　　សង្ស័យត្រូវសួររាជបណ្ឌិត ។
កុំឱ្យមន្ទិលធម៌ថ្មីចាស់　　មួយធម៌ក្រដាសមួយស្លឹករឹត
រាជការជំនុំរួមគំនិត　　រិះគិតតម្កើងព្រះសាសនា ។
តម្កល់សីលប្រាំ សីលប្រាំបី　　ឱ្យមនុស្សប្រុសស្រីរួមរក្សា
ផ្ទាត់ផ្ទៀងខ្លាបស្មៀងព្រះពុទ្ធដីកា　　ពិនិត្យអក្ខរាយកត្រឹមត្រូវ ។
ជំនុំបោះពុម្ពដាក់ក្រដាស　　ជាការរហ័សធ្វើសៀវភៅ
ឱ្យមានសូត្ររៀនប្រើតទៅ　　ទុកនៅជាកេរ្តិ៍អង្វែងឆ្ងាយ ។
សព្វថ្ងៃអ្នកខ្លៅស្អប់អ្នកប្រាជ្ញ　　ពោលខ្លាំងគិតខ្លាចឮសុសសាយ
ថាធម៌សៀវភៅធម៌ក្លែងក្លាយ　　អធិប្បាយខ្សឹបៗតែគ្នាឯង ។
១១៥- ឱ្យស្មៀមពីថ្ងៃនេះតទៅ　　ឯធម៌សៀវភៅផែនដីតែង
មិនមែនអ្នកប្រាជ្ញណាហ៊ានក្លែង　　ខ្លាចក្រែងរាជការចាប់ដាក់គុក ។
គម្ពីរស្លឹករឹតជាគំរូ　　តម្កល់ក្នុងទូបាក់សោទុក
គម្ពីរសៀវភៅប្រើគ្រប់មុខ　　ទំនុកបម្រុងក្នុងសាសនា ។



Websites: WatKhmers.org or WatKhemaraRatanaRam.org

ចាស់ៗជាន់មុនមានគំនិត
គម្ពីរស្លឹករឹតដួលគេចារ
ពុំនោះជាវគេដោយជ្រះថ្លា
ប្រើនមានប្រាជ្ញាតិបអ្នកបេះ ។
សង្វេបបទបែបរឿងប្រដៅ
ទុគ្គតអ្នកខ្លៅឈប់ទុកស្នេះ
សុំក្រើនអ្នកប្រាជ្ញមានតម្រិះ
កុំតិះដៀលត្មះចាស់ជាន់មុន ។
កុំថាចាស់ល្ងិតល្ងង់ល្ងីល្ងើ
ក្រែងពារទៅលើអ្នកមានគុណ
កុំពោលថាចាស់ថយថោកធុន
ក្រែងស៊ុនទៅលើគ្រូអាត្មា ។
១២០- ដ្បិតសិស្សនិងគ្រូមិនអ្នកក្រៅ
ជាក្មួយជាចៅជាជីតា
ជាសាច់ខាងមាតាឬបិតា
ជាកម្មវាចាខ្លះជាបង ។
ខ្លះត្រូវជាធំខ្លះជាមា
ជាគ្រូឧបជ្ឈាយ៍បំបួសផង
ប្រដៅសព្វថ្ងៃវាយម្ដងៗ
ព្រោះលោកបំណងចង់ឱ្យបេះ ។
ដល់ខ្លួនរៀនចាំជាក់បាលី
ឡើងពាក្យសម្ដីអាងតម្រិះ
តម្រូវខាងណោះខុសខាងណេះ
ដៀលតិះថាគ្រូខ្លួនឯងល្ងង់ ។
លោកគ្រូមិនដឹងប្រឹងតែអរ
ខំផ្ញើអង្ករបាវការុង



Websites: WatKhmers.org or WatKhemaraRatanaRam.org

ស្ករក្អមស្ករស្រោក់លាក់មិនគង់ ចង់ថ្កើងពូជពង្សល្បីកេរ្តិ៍ឈ្មោះ ។
ខ្លួនចេះបន្តិចកំប៉ិចឡើង ចចើងចចេសជជែកឈ្លោះ
ចេះកប់ពពកយកកំពស់ បន្តុះបន្ទន់គុណទាបទៅ ។

១២៨- បើចិត្តចង់ធំកុំចចើង គួរលើកតម្កើងគុណទុកនៅ
ទោសនោះធ្លាក់ចុះនរកជ្រៅ ម្នៅៗឱ្យបាបពីព្រោះមាត់ ។
ព្រោះមាននិទានពុទ្ធឃោសា អាងចេះសាស្ត្រាគម្ពីរស្ទាត់
ថាចេះលើសគ្រូៗបំភ្លាត់ បំប្លែងកំបាត់ឱ្យទណ្ឌកម្ម ។
ប្រដូចនិទានតែប៉ុណ្ណោះ អស់លោកក៏ចេះបានរៀនចាំ
ផ្ដួចផ្ដើមមួយឃ្លាជាពាក្យផ្ដាំ ដូចមានចំណាំចំណោទជួន ។
ទំនុកបុរាណមានប្រាជ្ញា ចេះចែងបញ្ហាសាស្ត្រាក្បួន
ទុកឱ្យអ្នកក្រោយដោះសំនួន បើគិតឱ្យមួនគួរមានភ័យ ។
ចំណោទថាសត្វបរោខោ អង្គុយមែកឈើស៊ីផ្លែជ្រៃ
បុរសខុសជ្រុលគ្មានលក់ព្នៃ បង់គោក្របីទាំងមេកូន ។



Websites: WatKhmers.org or WatKhemaraRatanaRam.org

១៣០- បុរសម្នាក់ទៀតឡើងដើមឈើ បេះផ្លែខាងលើបែកបងប្អូន
ស៊ីផ្លែតបន្តិចភ្លេចគល់សូន្យ បុរសម្នាក់បានកូនភ្លេចគុណម្ដាយ ។
បំណោទទីបីបំណែកនេះ គួររិះឱ្យជិតកុំគិតឆ្ងាយ
កុំឆ្ងល់នឹងពាក្យពោលអធិប្បាយ ប្រឹងគិតដោះស្រាយប្រាជ្ញាស្រាប់ ។
និយាយដើមគ្រូដោយកំបាំង មានខ្សឹបមានខ្លាំងពោលបង្អាប់
បង្អើលឱ្យអ្នកដទៃស្ដាប់ បង្អន់ដូចកាប់គាស់ឫសគល់ ។
ស៊ីផ្លែឆ្ងាញ់ផ្អែមតាមទំនូ ឫសលិចក្នុងដីមើលមិនយល់
មិនយកដីចាក់កប់គុណទល់ អំពល់ឱ្យបាបអំពីមាត់ ។
ពីមុនកាលកើតមានរូបកាយ អ្នកម្ដាយបិញ្ចឹមបានធំធាត់
នាំយកទៅទុកឱ្យនៅវត្ត រៀនបេះបាំស្ទាត់បំភ្លាត់គុណ ។
១៣៤- ភ្លេចគោក្របីទាំងមេកូន សាបសូន្យកុសលដែលសាងមុន
សាងក្រោយសាងឱ្យតែខាតទុន ពីព្រោះបាបស៊ុនស៊យពីចិត្ត ។
ពិចារណាគួរតែកោតខ្លាច ខ្លួនបានជាប្រាជ្ញព្រោះគ្រូប្រិត



Websites: WatKhmers.org or WatKhemaraRatanaRam.org

ប្រឹងប្រៀនប្រដៅច្បាប់ក្រមក្រឹត្យ | អាណិតដល់គុណធ្ងន់អនេក ។
អនាគតកាលទៅខាងមុខ | ចូរបងចាំទុកដល់ស្អែកៗ
កុំស្អប់ចាស់ថ្មីស្ដីដោយឡែក | មើលបែកចាត់ចិត្តថ្លឹងឱ្យស្មើ ។
ធ្វើបុណ្យឱ្យស្មោះកុំរើស្ម័គ្រ | បាលីបីថ្នាក់ចាំហើយតើ
មនោសេដ្ឋំចិត្តប្រសើរ | ប្រសប់គ្រាន់បើធ្វើបុណ្យបាន ។
ប្រាជ្ញថ្មីធ្វើតិចធ្វើតាមបុះ | កុំថាគេខុសហើយឈប់ខាន
ប្រាជ្ញចាស់ច្រើនធ្វើតាមបុរាណ | ច្រើនលើសប៉ុន្មានបានដោយបទ ។
១៤០- កុំធ្វើដោយរាប់អានស្រឡាញ់ | ទុកជាកំណាញ់ហួសកំណត់
កំណើតមគ្គផលជឿប្រាកដ | សន្មតថាបានច្រើនប្រការ ។
កុំធ្វើប្រកាន់ដោយយល់មុខ | ហៅបុគ្គលិកទានគ្មានផលា
តាំងចិត្តបុះផ្លូវឧបេក្ខា | រក្សារូបសុខដល់សួគិនាយ ។
សួគិនេះបើចង់ឱ្យបានឆាប់ដល់ | សាងមគ្គសាងផលកុំរាយមាយ
ឃើញគេខុសចិត្តកុំមើលងាយ | កុំពោលនិយាយកាន់ម្ខាងៗ ។



Websites: WatKhmers.org or WatKhemaraRatanaRam.org

អ្នកប្រាជ្ញបេះថ្មីត្រូវដោយឡែក    បំណែកប្រាជ្ញចាស់ត្រូវដោយយ៉ាង
កាន់យកទាំងពីរជាទីអាង    សន្សំខំសាងនឹងបានសុខ ។
ពីថ្ងៃនេះទៅនៅឱ្យនឹង    ស្ទៀមមាត់ឱ្យឈឹងខ្លាចនរក
ពីព្រោះឈ្លោះគ្នារៀងរាល់ស្រុក    បឹងថ្លុកត្រពាំងរាំងប្រេះដី ។
១៤៥- មិនឈ្លោះពីរឿងកេរ្ដិ៍រឿងកោះ    ឬទ្រព្យរបស់គោក្របី
នេះឈ្លោះពីធម៌ចាស់ធម៌ថ្មី    ក្ដៅចិត្តកើតក្ដីរកបាញ់ឈ្នះ ។
បើក្ដីពីស្រែពីចំការ    ចៅក្រមសាលាងាយជម្រះ
នេះក្ដីពីធម៌ថ្មីធម៌ចាស់    នោះក្រែងតែព្រះទើបកាត់បាន ។
ចៅក្រមសព្វថ្ងៃឧបាសក    បេះខ្មេចបិដកព្រះកម្មដ្ឋាន
កាត់ក្ដីត្រូវច្បាប់អម្បាលម៉ាន    អ្នកក្ដីមិនខានប្ដឹងឧទ្ធរណ៍ ។
អាដែងមនុស្សម្នះរឹងបបេស    បានតែនិរទេសក្រៅនរគ
តែទុកវានៅវាតាំងវរ    ជំហរតែរឹងទទឹងច្បាប់ ។
សង្ខេបបទបែបរឿងប្រដៅ    អ្នកល្ងឹងល្ងង់ខ្លៅគួរតែស្ដាប់


Websites: WatKhmers.org or WatKhemaraRatanaRam.org

អ្នកចេះសូត្រធម៌មិនស្គាល់សព្ទ　　គួរត្រាប់អ្នកប្រាជ្ញចេះបាលី ។

១៥០- ធ្វើបុណ្យធ្វើទានកុំចោលចាស់　　ចោលចេញទុកខ្លះក្បួនលោកីយ៍

សូត្ររៀនតាមបែបអ្នកប្រាជ្ញថ្មី　　កុំបីភ្លេចគុណចាស់បុរាណ ។

ធម៌អាថ៌ប្រឡំកុំប្រឡោត　　ពាក្យពោលចាក់ដោតឱ្យឈប់ខាន

រួមចិត្តសះសាបានសុខសាន្ត　　នឹងឱ្យរុងរឿងរីកសាសនា ។

កុំឱ្យវៀចវោយរីតរងកម្ម　　រាំងរីងរាល់ឆ្នាំ ៥ វស្សា

វស្សន្តរដូវត្រូវមនុស្សថា　　រំដួលទេវតាក្ដៅក្រហាយ ។

មនុស្សភូតកុហកឆក់ឆរបោក　　ឆ្នាំនេះស្រូវថោករាស្ត្រអត់បាយ

ក្រលុយក្រកាក់ខ្វះប្រាក់ចាយ　　មហាជនទាំងឡាយកើតវេទនា ។

ភិរម្យខ្ញុំបាទដើមឈ្មោះ អ៊ូ　　ពូជពង្សអម្បូរខ្មែរអ្នកជា

អាពុកឈ្មោះ អ៊ុក មានសក្តិងារ　　ចៅពញាធម្មធារាមេស្រុក ។

១៥៥- ក្នុងខេត្តភ្នំពេញ ឃុំកំបូល　　ពូជពង្សត្រកូលជាម្ចាស់អង្គប៉ុក

ជីតាខាងម្ដាយឈ្មោះពញាម៉ុក　　គាត់ធ្វើមេស្រុកឃុំស្ពានថ្ម ។



Websites: WatKhmers.org or WatKhemaraRatanaRam.org

អ្នកម្ដាយអាពុកបងប្អូនជិត ជីទួតមួយពិតពូជបិត្តល្អ
ដូនតាផ្សំផ្គុំជាតំណ បង្កកើតមកជាខ្ញុំបាទ ។
ពូជខាងអាពុកមានប្រាជ្ញា ច្រើនចេះសាស្ត្រាចាំក្បួនខ្នាត
ត្រកូលខាងម្ដាយប្រាជ្ញាឆ្លាត រូបរាងច្រើនស្អាតគ្មានគេស្អប់ ។
ខ្ញុំពួមនុស្សឈ្មោះពីធម៌អាថ៌ គិតក្រែងសាសនាប្រែត្រឡប់
ខ្ញុំចាប់អធិប្បាយពុំសាយសព្វ សន្មតថាចប់ម្ល៉េះឯងហោង ។



Websites: WatKhmers.org or WatKhemaraRatanaRam.org

# ពាក្យកាព្យប្រដៅជនប្រុស~ស្រី

(បទពាក្យ៧)

ខ្ញុំសូមបង្គំព្រះសម្មា- សម្ពុទ្ធណាៗក្នុងត្រៃភព
បម្រើនកម្មដ្ឋានក្រោមពោធិ៍ម្លប់ ខ្ញុំសូមគោរពនមស្សការ ។
ព្រះបមបក្រពិនតនិរន្តបូទ្ធ័ ជាម្ចាស់ជីវិតលើសិរសា
សូមថ្វាយបង្គំព្រះករុណា សូមទ្រង់មេត្តាប្រោសប្រណី ។
ឱនកាយបង្គំប្រណម្យនឹក សូមក្រើនរំលឹករាស្ត្រប្រុសស្រី
ធ្លាប់ជ្រកទីពឹងព្រះបារមី ឱ្យរៀនបាលីទៅបរលោក ។
សរណគមន៍បីឱ្យប្រតិបត្តិ កំចាយកំចាត់ក្ដីទុក្ខសោក
រូបយើងសព្វថ្ងៃថ្លៃមិនថោក បានមកភពភាគ់ទាន់សាសនា ។
៤- ផ្លូវប្រែតនរកទៅញឹកញយ គួរកុំបណ្ដោយតាមតណ្ហា
គួរគិតសង្វេបឃាត់សង្ខារ សង្ឃឹមព្រះសិអារ្យនឹងមកត្រាស់ ។
ជម្ពូទ្វីបនេះធំបំផុត មួយម៉ឺនយោជន៍គត់ដំណៃលព្រះ
សត្វស្លាប់តាមកម្មមិនចាំបាស់ អាយុខ្លីណាស់ក្រាស់អកុសល ។
រូបំ អនិច្ចំ អនត្តា កើតរូបកាលណាកម្មតាមដល់



Websites: WatKhmers.org or WatKhemaraRatanaRam.org

តាមដានដរាបបាបឱ្យផល បាបខ្លះសេសសល់ពីនរក ។
ខ្លះមកអំពីប្រេតតិរច្ឆាន ខ្លះមកពីស្ថានសួគ៌សោយសុខ
វេរាតាមរកបានឃើញមុខ ចុះមករងទុក្ខទទួលកម្ម ។
អ្នកធ្លាប់ទៅរងនរកប្រេត ដើមហេតុពីព្រោះដាច់សីល ៥
ទឹកក្តៅខ្លះដែកទៅដេកត្រាំ រាប់លានកោដិឆ្នាំទំរាំរួច ។
១០- មកកើតជាមនុស្សស្ថានកណ្តាល មិនរាងមិនចាលដល់តិចតួច
ប្រពន្ធកូនគេនៅតែលួច សត្វធំសត្វតូចរឹតតែសម្លាប់ ។
ស្រារឹតតែផឹកឱ្យស្រវឹង គុណទោសមិនដឹងប្រឹងចាក់កាប់
ស្រេកឃ្លានបំពានធ្វើលើច្បាប់ មិនស្តាប់ពុទ្ធដីកាព្រះអង្គផ្តាំ ។
ពិតមែនជាមិនឮព្រះឱស្ឋ ព្រះសង្ឃទ្រង់ប្រោសឱ្យសីល ៥
ទទួលរំពេចភ្លេចមិនចាំ ប្រព្រឹត្តសាងកម្មមិនព្រមលែង ។
កើតមកពូជពង្សពេញជាមនុស្ស សេចក្តីត្រូវខុសចាំជាក់ស្តែង
សម្លាប់រូបសត្វឥតគិតក្រែង បំពេញរូបឯងឱ្យធំធាត់ ។
សម្លាប់មិនថាសត្វឈ្មោលញី យកសាច់មកស៊ីឱ្យឆ្ងាញ់មាត់



Websites: WatKhmers.org or WatKhemaraRatanaRam.org

ទទួលសីលភ្លើធ្វើឱ្យភ្លាត់ លក់សត្វឱ្យព្រាត់មេព្រាត់កូន ។

១៩- ព្រាត់គ្នាកំសត់វដ្ដសង្សារ ដូចលក់ជីតាលក់ជីដូន
ពុំនោះលក់បងបំបែកប្អូន ងងឹតឈឹងសូន្យមើលមិនយល់ ។
ខ្លះទៅនរកមិនទាន់មក ខ្លះឃ្លាតទៅជ្រកពួកអសុរ
ជវនសង្ខារឡប់វិលវល់ អំពល់តែកើតស្លាប់កើតស្លាប់ ។
កម្មកិតតាមខ្លួនមិនដែលឃ្លាត គ្រប់ប្រាំរយជាតិមិនដែលធាប់
សត្វជ្រូកមាន់ទាគេចាក់កាប់ សម្រាប់គេស៊ីជាអាហារ ។
សត្វគោក្របីដំរីសេះ គេជិះគេទឹមជាធម្មតា
គេកាប់លក់សាច់ផ្ដាច់សង្សារ រកបិត្តមេត្តាករុណាគ្មាន ។
រូបខន្ធរលត់រលាយទៅ សល់នៅសង្ខារនិងវិញ្ញាណ
វេទនាសញ្ញានឹងស្រេកឃ្លាន សន្និដ្ឋានថាដូចអ្នកមានគុណ ។

២០- សត្វញីសត្វឈ្មោលអន្ទោលទុក្ខ អាពុកឬម្ដាយពីជាតិមុន
ជាតិមកពីរងទោសទុក្ខធ្ងន់ ក្រែងស៊ុនទៅលើសាច់ញាតិឯង ។
ជ្រូកគោក្របីនៅតួបស្នារ គេគ្រៀកវះគ្រៀវឃើញស្ដែងៗ



Websites: WatKhmers.org or WatKhemaraRatanaRam.org

បើគិតឱ្យសព្វគ្រប់កន្លែង ជួនក្រែងជាតិមនុស្សមកជាសត្វ ។
អ្នកពឹងនឹងអ្នកធ្វើដៃដល់ ចៅក្រមអកុសលជំនុំកាត់
បញ្ជីទាំងពីរឈ្មោះមិនបាត់ គេបាត់ធ្វើទោសទាំងអស់គ្នា ។
មិនមានអ្នកណាធ្ងន់ណាស្រាល យមបាលវះក្រៀវគ្រប់វេលា
មានលោកយមរាជរាជសភា ជំនុំគិតគ្នាមើលបញ្ជី ។
បញ្ជូនអ្នកធ្វើចុះនរក ជំនុំឃុំទុកអ្នកទិញស៊ី
ទិញសត្វស្លាប់រស់ទោះឈ្មោលញី ទាំងពីរចំណែកបំណាំមុខ ។
២៥- អ្នកមួយទិញស៊ីមិនរួបខ្លួន ត្រឹមឯត្រីអួនយួនដូរលក់
អណ្ដែងក្រាញ់ផ្ដោជៀបរស់ផ្អក់ បង់ទិញស្មោរជ្រក់ទោតថ្លៃ ។
ឃើញច្បាស់ជារស់មិនទាន់ងាប់ អង្គុយបង្អាប់ឱ្យយួនវៃ
រកខ្យល់ប្រឡោតដោតញ័រដៃ ឃើញក្បៀយស្រាប់ៗមិនទិញយក ។
អានេះបន្ទូរលែងមិនបាន ត្រូវប្រុំធាក់ប្រាណឱ្យជ្រុលជ្រក
ទម្លាក់ឱ្យជ្រៅរងទុក្ខសោក លែលកអ្នកទោសរឿងអ្នកទិញ ។
អ្នកទៅឃើញត្រីនៅបម្រះ វេទនាបិត្តណាស់ប្រាសដើរចេញ



Websites: WatKhmers.org or WatKhemaraRatanaRam.org

អ្នកនេះត្រូវលែងឱ្យទៅវិញ មានសៃហ្វលិញគិញក្នុងនរក ។
ឱ្យជូនខ្លាចក្រែងវង្វេងផ្លូវ ត្រូតមើលខុសត្រូវគ្រប់ភូមិស្រុក
បើកក្រាំងសៀវភៅកត់ឈ្មោះទុក បញ្ជីពីរមុខបាបនិងបុណ្យ ។
៣០- ប្រគល់យមរាជយមបាល ដាក់ស្រាលដោយស្រាលធ្ងន់ដោយធ្ងន់
អ្នកសាងមគ្គផលស្គាល់ទោសគុណ ទៅសោយសុខមុនតាមទុនទាន ។
អ្នកសាងធុនទាបភាពអកុសល មិនបង់បានផលសួគ៌និព្វាន
ប្រព្រឹត្តអាក្រក់រកល្អគ្មាន មិនហ៊ានកាន់សីលថាខ្លាចដាច់ ។
មិច្ឆាទិដ្ឋិចូលពេញទី បញ្ជីសម្រាំងតាំងសម្រេច
ចុះវង្សអាជីវកភ្លក់ស៊ីអាចម៍ ព្រោះពោលបង្អាប់ព្រះពុទ្ធដីកា ។
វបីទុច្ចរិតមានគ្រប់យ៉ាង ទានសីលមិនសាងអាងផឹកស្រា
ឰលោកសំដែងធម៌ទេសនា ពីរោះពិស្ដារមិនបេះស្ដាប់ ។
អស់យើងគួរស្ដាយជាតិកំណើត សំណាងមកកើតក្នុងភទ្ទកប្ប
អគារវិន័យព្រះប្រញប្ដ ជាឫសគល់ច្បាប់គួររក្សា ។
៣៥- សីល ៥ បងចាំឱ្យប្រាកដ កុសលកម្មបថ ១០ ប្រការ



Websites: WatKhmers.org or WatKhemaraRatanaRam.org

កុំឈ្លោះប្រកែកពីធម៌អាចិ ប្រកាន់សាសនាឱ្យប្រាកដ ។
កើតមកជាមនុស្សមានសខ្មៅ មានប្រាជ្ញមានខ្លៅមានក្រខ្សត់
មានខ្លាំងមានខ្សោយដោយបែបបទ សន្មតថាល្អក៏មិនបាន ។
ជម្ពូទ្វីបនេះមនុស្សកម្មក្រាស់ ព្រះពុទ្ធតែងត្រាស់មិនដែលខាន
ហេតុនេះមហាជនទាំងប៉ុន្មាន សម្រាកសម្រាន្តសម្រួលចិត្ត ។
បំណាច់សម្ដេចព្រះទ្រង់ញាណ កាលហៀបនិព្វានមានកម្រិត
ផ្ដាំមហាអានន្ទឱ្យអាណិត អានុជអ្នកប្រើតប្រោសសត្វផង ។
សត្វផុងទៅក្នុងជ្រោះជ្រាំជ្រៅ តថាគតនៅនាំចម្លង
ដាក់ដល់និព្វានអស់ហ្មត់ហ្មង រួចពីចំណងវដ្ដសង្សារ ។
៤០- នៅសល់សង្ស័យសត្វខាងក្រោយ ឥន្ទអើយទុកអោយព្រះសិអារ្យ
អាណិតសត្វណាស់ណាអ្នកណា តថាគតជិតនិព្វានហើយ ។
ព្រះឱស្ឋព្រះអង្គល្អមស្រណោះ សប្បុរសទាំងអស់កុំកន្តើយ
ប្រះខ្នងដេកលើកន្ទេលខ្នើយ កុំសៀមមាត់ឡើយរំលឹកគុណ ។
ខ្លួនខ្ញុំកំណើតរាស្ត្រអ្នកស្រែ ខ្ញុំបរិលខ្ជិលដែរពីកាលមុន


Websites: WatKhmers.org or WatKhemaraRatanaRam.org

កាលមោហ៍បាំងបិទងងឹតស៊ុន ធ្វើបាបនិងបុណ្យទម្ងន់ស្មើ ។
មិនស្មោះតែរួបចតុរាបាយ អស់លោកទាំងឡាយកុំសរសើរ
ខ្ញុំជូនដំណឹងតាមដំណើរ ព្រោះខ្ញុំគ្រាន់បើជាងអ្នកលង់ ។
ជាតិក្រោយកុំឱ្យខ្ញុំល្វីល្វើ ជាតិនេះបាស់ស្មើរខ្ញុំប្រឹងស្ទង់
ប្រឹងស្ទុះឱ្យរួចពីអន្លង់ ភ័យភិតខ្លាចផុងទៅក្នុងភក់ ។

៤៥- ក្នុងភពសង្សារខ្ញុំសង្ស័យ សព្វថ្ងៃខ្ញុំភ័យខ្លាចនរក
ម៉្យាងទៀតខ្ពើមជាតិអាជីវក ជាតិល្មោភហួបល្មក់ព្រោះល្មិលគុណ ។
ប្រើនល្មើសបន្ទូលបន្ទោសព្រះ ខ្ញុំភ័យខ្ញុំណាស់ក្រែងខ្ញុំស៊ុន
ខ្ញុំសូមស្មារលាទោសពីមុន សូមបុណ្យជួយបាំងបាបឱ្យបាត់ ។
ឱ្យបានទាន់តួព្រះសិអារ្យ ឱ្យបែកប្រាជ្ញាឆ្លាតបរមត្ថ
ព្រះអង្គទេសនាទ្រង់ប្រោសសត្វ សូមលុះអរហត្តដូចបំណង ។
បំណាច់ខ្ញុំផ្សាយច្បាប់រំលឹក អស់លោកជួយនឹកសព្វាផ្សង
ធ្វើបុណ្យបែកផលដល់ខ្ញុំផង នឹកឈ្មោះម្តងៗដូចធម្មតា ។
សប្បុរសប្រុសស្រីគប្បីស្តាប់ ឈ្មោះច្បាប់គន្លងព្រះឱង្ការ


Websites: WatKhmers.org or WatKhemaraRatanaRam.org

ឱកាសឱ្យគិតប្រឹតប្រាជ្ញា ទាន់ព្រះសិអារ្យទាំងប្រុសស្រី ។
៨០- កុំរៀនព្រហើនប្រហែសធ្វេស កើតក្នុងប្រទេសរាជបុរី
ឱ្យមានបារម្ភភ្ញាក់ស្មារតី សីលប្រាំ-ប្រាំបីទំសិក្សា ។
ជាតិមនុស្សជាន់ខ្ពស់ពីបុរាណ គេបានជួបជាក់ឃើញភក្ត្រា
បានត្រងរងត្រាប់ព្រះពុទ្ធដីកា បានលុះសោតាអរហត្តហោះ ។
យើងទាន់តែត្រឹមពាក្យបណ្ដាំ បណ្ដូលសីលប្រាំជាកេរ្តិ៍កោះ
កិច្ចការកងកម្មចាំមិនអស់ របស់ឬសគល់គួររក្សា ។
នេះបប់បំណែកខាងបាសក កុំធ្វើអាក្រក់រាល់រូបា
រំពឹងក្រែងជួបព្រះសិអារ្យ នមស្ការគោរពរំលឹកគុណ ។
ព្រះបមបក្រពង្សមុនីនាថ កំពូលផុតជាតិជាងមហាជន
ទ្រង់សោយសម្បត្តិសម្បើមបុណ្យ សម្បូណ៌លើសលន់លុបលោកា ។
៨៥- លោកីយ៍ដឹងហើយគួរកោតខ្លាច ទ្រង់មានអំណាចព្រះបេស្កា
គួរស្ដាប់ព្រះរាជឱង្ការ បន្ទូលត្រួតត្រាគួរត្រងត្រាប់ ។
ព្រះទ័យទ្រង់ត្រេកស្រឡាញ់សង្ឃ ប្រមាណសែនអង្គក្នុងភទ្ទកប្ប


Websites: WatKhmers.org or WatKhemaraRatanaRam.org

ព្រះពុទ្ធទ្រង់ប្រឹតប្រាមប្រញប្ដ ឈ្មោះច្បាប់បាដិមោក្ខសំវរសីល ។
បែកបេញជាកងសិក្ខាបទ កំណាត់ពីររយម្ភៃប្រាំពីរ
មិនឱ្យមានមោះហ្មងមន្ទិល អ្នកបួសកុំខ្ជិលកាន់ឱ្យខ្ជាប់ ។
បាណាអទិន្នាជាបឋម ជាតិរូបទៀតផ្សំត្រូវជាដប់
លោកសង្ឃឥឡូវកាន់មិនសព្វ កាន់ក្នុងបន្ទប់លាយបន្លំ ។
បន្លិចលុយកាក់លាក់សម្ងាត់ ទោសត្រូវអាបត្តិលាក់សំងំ
បាសកផ្ញើទានគ្មានបារម្មណ៍ សន្សំតែទ្រព្យក្ដៅក្រហាយ ។
៦០- ប្រសិនបើកាន់ច្បាប់ព្រះពុទ្ធ មិនមានធម្មយុត្តិមហានិកាយ
បើបេះខ្លាចក្រែងមិនក្លែងក្លាយ សមសុខសប្បាយមិនទាស់គ្នា ។
លោកសង្ឃគ្រប់វត្តមានធំតូច សង្ឃខ្លះខិលខូចសង្ឃខ្លះជា
បរិស័ទថ្កោលទោសគ្រូឧបជ្ឈាយ៍ មានពាក្យនិន្ទាតែរាល់វត្ត ។
បាដិមោក្ខពីររយម្ភៃប្រាំពីរ អ្នកល្ងង់ហើយខ្ជិលចាំមិនស្ទាត់
កងបាចិត្តិយនិងទុក្កដ ប្លូលមាត់ប្លូលកមិនដឹងខ្លួន ។
កងបាចិត្តិយកៅសិបពីរ និស្សគ្គិយ៍សាមសិបបារាជិកបួន


Websites: WatKhmers.org or WatKhemaraRatanaRam.org

បើបេះហើយបាំឱ្យមាំមួន | ល្អបរិសុទ្ធសួនមិនសាយសុស ។
ប៉ុន្តែសិក្ខាមិនសូវចាំ | បំណាំត្រង់ណោះបោលត្រង់ណោះ
ត្រង់ណាដែលដឹងថាខ្លួនខុស | ហ៊ានឈ្លោះពីព្រោះគេមិនដឹង ។

៦៩- សង្ខ្យាទិសេសប្រហែលបាន | ដប់បីសន្តានប្រមាណថ្លឹង
បើធ្លាប់សង្រួមឱ្យយ៉ាងតឹង | មិនអរមិនខឹងមិនខាតខុស ។
ឥន្ទ្រីយ៍ប្រាំមួយនាំឱ្យភ្លាត់ | បាបិត្តិយទុក្កដលាយបំរុះ
ឥន្ទ្រីយ៍ត្របៀកភ្នែកប្រមុះ | ភ្នែកមើលណោះណោះឃើញសុសសាយ។
សោតិន្ទ្រិយោស្ទូរតិបខ្លាំង | បក្ខុន្ទ្រិយំឃើញជិតឆ្ងាយ
ជីវ្ហិន្ទ្រិយាពោលនាយអាយ | សើចលេងសប្បាយបំអន់គ្នា ។
បរិស័ទអាបត្តិទុក្កដញឹក | បារាជិកច្រើនណាស់តែឧបជ្ឈាយ៍
ទ្រព្យក្នុងសំបាច់សំបូណិហៀរ | ត្រូវទោសអទិន្នាគរុភណ្ឌ ។
ទ្រព្យសង្ឃជាដើមគឺបំណាំ | អវហារម្ភៃប្រាំចាំគ្មេរគ្នាន់
ឱបទុកខ្វះខ្វែងក្រែងមិនគ្រាន់ | អវហារប្រាំជាន់បារាជិក ។

៧០- ម្យ៉ាងទៀតទ្រព្យសង្ឃក្នុងបំណែក | កិបទុកមិនបែកឱ្យលោកភិក្ខុ



Websites: WatKhmers.org or WatKhemaraRatanaRam.org

គ្រឿងយាវជីវិកកាលិក ទុកខ្លួបល្វាចព្រឹកម៉ោតែឯង ។
ម៉្យាងទ្រព្យគេហែបូលវិហារ បាសកប្ងូជាដល់គម្ដែង
គេវេរបាលីមានខ្លីវែង គេតែងនឹកថាសង្ឃស្ស្ន ។
ប្រកាសប្រគេនជំនុំសង្ឃ បំពោះគ្រប់អង្គថាទេមៈ
លោកសង្ឃសាធុគ្នានសល់ម្នាក់ សង្ឃរាជទុកដាក់មិនបែកបាយ ។
ខ្ញុំបាទបែងតាមខ្ញុំបេះបាំ អវហារម្ដែប្រាំបែកបរិយាយ
នេះសុទ្ធតែសីលផ្ដួសអន្ដរាយ លោកសង្ឃទាំងឡាយកុំប្រព្រឹត្ត ។
ពីព្រោះឥន្ទ្រីយ៍ទាំង ៦ លោកណាមិនព្រួយមិនប្រុងគិត
លោភោមោហោបាំងងងឹត សិស្សមានគំនិតមិនហ៊ានថា ។

៧៤- ស្ងូមទានសន្ដោសសំដែងច្បាប់ ព្រះសង្ឃកុំចាប់បងទោសា
ខ្លួនខ្ញុំស្ងូមសុំបវារណា ប្រោសប្រាណមេត្តាបណ្ដាសង្ឃ ។
ខ្ញុំមិនមានពោលពាក្យបង្អាប់ ខ្លាចសីលលោកដាច់ខ្ញុំដម្រង់
ដម្រូវតែតាមច្បាប់ព្រះអង្គ ព្រះឱស្ឋត្រឹមត្រង់ត្រូវមាត្រា ។
កាលអង្គសម្ដេចព្រះបមភព បន្ទូលប្រារព្ធគ្រប់ប្រការ



Websites: WatKhmers.org or WatKhemaraRatanaRam.org

ប្រកាសប្រាកដបទសិក្ខា ប្រញាប់ប្ដេជ្ញាមហាបរិស័ទ ។
ភិក្ខុភិក្ខុនីអស់អរហន្ត អានឥតមិនទាន់បានអរហត្ត
ព្រះធម៌វិន័យកុំឱ្យបាត់ ប្រយ័ត្នឱ្យគង់ប្រយោជន៍យូរ ។
ក្រោយនោះព្រះអង្គចូលនិព្វាន អរហន្តហោះធ្យានមានជាគ្រូ
មិនមានអក្ខរាណាដាក់ទូ ទេសនាបង្ហូរពីព្រះឱស្ឋ ។

៨០- ព្រះអគ្គសាវ័កគ្រប់ព្រះអង្គ ព្រះទ័យស្រោបស្រង់ទ្រង់សង្គ្រោះ
សំដែងធម៌អាថ៌មេត្តាប្រោស បាបបុណ្យគុណទោសនិងសីលទាន ។
ឈ្វេងយល់ថាធម៌នឹងសូន្យស្ងាត់ អរហន្តអរហត្តចូលនិព្វាន
សង្ស័យសេក្ខបុគ្គលមិនទ្រង់ញាណ មិនមានអក្ខរាណាតែងទុក ។
ព្រះធម៌ប្រាំបីម៉ឺនបួនពាន់ ស្រេចលើអានឥតចាំទំនុក
ដំណែលព្រះអង្គដឹងគ្រប់មុខ ជង្រុកធម៌អាថ៌មហាអានន្ទ ។
ជាព្រះអនុជអាណិតសត្វ ក្រែងបាត់បិដកមិនគ្រប់គ្រាន់
ព្រះធម៌ប្រាំបីម៉ឺនបួនពាន់ គ្មេរគ្មាន់ខ្វះខ្វែងបាត់បែងបារ ។
បេះបប់អភិធម្មចាំរហូត វិន័យព្រះសូត្រ ៥ ប្រការ



Websites: WatKhmers.org or WatKhemaraRatanaRam.org

ប្រកាសអស់អង្គអរហន្តា　　បិដកឯណាជាឫសគល់ ។

៨៥- បរមត្ថព្រះសូត្រអានឲ្យចាំ　　វិន័យទាំង ៥ ឱ្យបាលីយល់

អរហន្តទាំងអស់កើតរវល់　　អំពល់អំពីរឿងធមិអាចិ ។

ព្រះបាទអជាតៈសត្រូវ　　ជួយគិតតម្រូវព្រះសាសនា

សម្មតិឱ្យឈ្មោះហៅក្សត្រា　　ព្រោះព្រះមហាក្សត្រិយ៍ចូលគំនិត ។

និយាយឱ្យដឹងដើមកំណើត　　កកើតអក្ខរាបារស្លឹករឹត

បកប្រែបាលីសេចក្ដីពិត　　ពិនិត្យត្រឹមត្រូវតាមពុទ្ធដីកា ។

ទសជាតក៏ទាំង ១០មានគ្រប់វត្ត　　ប្រែត្រូវប្រាកដព្រះគាថា

ព្រះធមិសូត្រមន្ត ឬសូត្រជារ　　អ្នករៀនអក្ខរាពីរបំបែក ។

បំណោះបំណាំចាំដោយខ្លួន　　ខ្លះរៀនមានក្បួនបាស់បារបែក

ហ៊ានភ្នាល់ព្រោះអាងឃើញនឹងភ្នែក　　កើតឈ្លោះប្រកែកប្រកួតខឹង ។

៩០- ប្រកាន់តែខាងខុសរហូត　　មិនរៀនមេសូត្រឱ្យបេះដឹង

អាងបេះតែកកាប៉ុណ្ណឹង　　ខំប្រឹងបំអើតអួតខ្លួនត្រូវ ។

ក្ដៅឈាស់ពីរឿងយោជាយ៉ោ　　ដំឡើងភ្នែកស្លោមុខក្រញូវ



Websites: WatKhmers.org or WatKhemaraRatanaRam.org

ថាធ្លាប់យោនាពីខ្មោចឪ ឥឡូវយ៉ោណាមិនសុខចិត្ត ។
អ្នកម្ខាងអាងស្រះតួប្រាំបី ឱ្យដឹងបាលីជាកម្រិត
ផ្សំតួមេសូត្រប្រឹងប្រែប្រឹត ព្រោះត្បិតឱ្យត្រឹមត្រូវមាត្រា ។
អ្នកបួសគ្រប់វត្តគ្រប់នគរ ស ដាក់ជើង ល រាប់ ស្ល ស្លា
បើ ស ជើង ម រាប់ ស្ម ស្មា អ្នកមានប្រាជ្ញាល្មមស្តាប់បាន ។
កុំល្ងង់ទាល់ងាប់ធ្លាប់មិនដឹង បើខឹងខ្ញុំឃាត់ថាឱ្យខាន
ខ ដាក់ជើង ម ពីបុរាណ ក្មេងតូចប៉ុន្មានស្គាល់ ខ្ម ខ្មា ។

៩៥- ជាតិរាស្ត្រចាស់ក្មេងកុំចិត្តខ្មាំង គួរខ្មាសបារាំងអ្នករាជការ
ដើមហេតុអំពីព្រះករុណា ឱ្យសាងសាលាប្រែបាលី ។
ទ្រង់ចាំទំនៀមពីបុរាណ ហើយបានជំនុំព្រមកុង្សុយ៍
បំណាច់ធ្វើស្តេចគ្រងផែនដី ទិសទាំងប្រាបីរំពៃគ្រប់ ។
ព្រះកាយពលមិនរវល់រែក ព្រះទ័យរំលែកទាំងថ្ងៃយប់
ចូលទៃនបន្ទំទីបន្ទប់ បន្ទូលមិនឈប់រាល់វេលា ។
មេត្តាប្រោសប្រាណអ្នកមានស័ក្តិ ព្រះទានលុយកាក់គ្រប់ភ្នាក់ងារ


Websites: WatKhmers.org or WatKhemaraRatanaRam.org

ទ្រង់ត្រូតស្រីស្ទុំក្រមស្រីង្គារ ក្រែងគ្រូនរងាមិនបានសុខ ។
ព្រះទ័យមេត្តាសព្វមនុស្សសត្វ សោយរាជសម្បត្តិសម្បើមស្តុក
ព្រះកាយប្រកបគង់ស្រណុក ព្រះទ័យវិតក្កជាធម្មតា ។
១០០- មួយព្រួយនឹងឱបព្រះនគរ ពីរព្រួយនឹងពព្រះសាសនា
បីត្រូតលោកសង្ឃកាន់សិក្ខា សង្រួមកិរិយាមិនបរិសុទ្ធ ។
ឿយណាស់ព្រះនេត្រព្រះកាណ៌ ព្រះឱស្ឋត្រួតត្រាប្រើនបំផុត
ដាស់តឿនបំភ័យពួកកុលបុត្រ ឱ្យប្រុងលំអុតសង្រួមកាយ ។
បានចេញប្រកាសដាក់ប្រាកដ ប្រគេនគ្រប់វត្តទោះជិតឆ្ងាយ
លោកសង្ឃមិនត្រូវស្រើបសប្បាយ អស់ល្បែងទាំងឡាយគ្រប់ជំពូក ។
មិនត្រូវបំពោះស្ដាប់តន្ត្រី កុំបីមើលរាំរាំនាំភ្លូក
កុំដើរភ្លើៗមើលអ៊ុំទុក អ្នកបួសធ្វើលោកមិនត្រូវការ ។
បើមានត្រូវកិច្ចដើរយប់ថ្ងៃ សង្ឃបងនិស្ស័យចាស់វស្សា
កុំដើរទឹមស្មាទៅណាៗ អ្នកបេះសិក្ខាគេទាស់ភ្នែក ។
១០៤- លោកនេនកុំសុំលុយបិនបាយ បិណ្ឌបាតតែបាយម្នាក់១វែក



Websites: WatKhmers.org or WatKhemaraRatanaRam.org

គ្រឿងម្ហូបចំណីបាសកបែក កុំស្ពាយពុនវែកវាចោកឫក ។
របស់បាសកគេប្រគេន ប្រគល់លោកនេនបានលោកភិក្ខុ
បិញ្ជឹមជីវិតនឹងបាយទឹក បិណ្ឌបាតតែព្រឹកយប់សូត្ររៀន ។
លោកណាត្រឹមត្រូវមិនសូវខុស ស្ងៀមស្ងាត់ទៅចុះកុំអន់អៀន
លោកណាមិនចេះកុំវេះវៀន ពាក្យប្រៀនប្រដៅឱ្យផ្អើលភ្ញាក់ ។
ពីព្រោះព្រះអង្គបានផ្តាំផ្ញើ វិន័យស្ថិតលើស្តេចមហាចក្រ
ព្រះមហាចមពង្សទ្រង់ជំពាក់ ចំពោះធុរៈនឹងសាសនា ។
ពីត្រឹមនោះរៀងដរាបមក ដល់ស្រុកគោកធ្លកមានសាវតារ
ប៉ុន្មានរាជ្យហើយមិនដឹងថា ដល់មកករុណាយើងសព្វថ្ងៃ ។
១១០- ហេតុនេះលោកសង្ឃប្រុងពិនិត្យ សៀវភៅស្លឹករឹតមានរាល់ដៃ
ផ្ទៀងមើលសិបផ្ទូកវិនិច្ឆ័យ បើនៅសង្ស័យឱ្យសិក្សា ។
លោកសង្ឃបាស់ខ្ទីគប្បីស្តាប់ ឈ្មោះច្បាប់គន្លងព្រះពុទ្ធដីកា
បង្គំថ្វាយដល់ព្រះករុណា សូមទ្រង់មេត្តាជ្រាបព្រះទ័យ ។
ក្រែងជួបប្រទះពាក្យផ្គាំផ្គង ពុំត្រូវទំនងក្រឹត្យវិន័យ


Websites: WatKhmers.org or WatKhemaraRatanaRam.org

សូមទានសន្ដោសអត់ទោសពៃរ៍ ក្រួញក្រាបសិរសីក្រោមព្រះបាទ ។
ព្រះសង្ឃទាំងអស់ទោះតូចធំ អភ័យទោសខ្ញុំសូមអនុញ្ញាត
ពាក្យខ្ញុំមិនមានពោលប្រមាថ សង្ឃជាល្អស្អាតខ្ញុំមិនថា ។
ខ្ញុំពោលតែលោកធ្វើអាក្រក់ បើខ្ញុំកុហកខូចមុសា
ហេតុនោះខ្ញុំសូមបវារណា និង្គិតាសង្ខេបតែប៉ុណ្ណេះ ។
១១៥- ក្មេងណាប្រាថ្នាបួសធ្វើសង្ឃ ឱ្យស្វែងតម្រង់រៀនតម្រិះ
ឱ្យមើលតម្រាប់លោកអ្នកបេះ កុំដេកតែអេះតិះដៀលគ្នា ។
អ្នកម្ដាយឪពុកឱ្យឈ្មោះ **អ៊ូ** ពូជពង្សអំបូរខ្មែរអ្នកជា
អាពុកឈ្មោះ **អ៊ុក** មានស័ក្តិងារ ចៅពញាធម្មធារាធ្វើមេស្រុក ។
ក្នុងខែត្រភ្នំពេញឃុំកំបូល ជាប់ផៅត្រកូលជាម្ចាស់អង្គប៉ុក
អាពុកអ្នកម្ដាយឈ្មោះពញា ម៉ុក គាត់ធ្វើមេស្រុកឃុំស្ពានថ្ម ។
អ្នកម្ដាយអាពុកបងប្អូនជិត ជីទួតមួយពិតពូជបិតុល្អ
បាស់ទុំផ្សំផ្គុំជាដំណា បង្កកើតខ្ញុំទូលបង្គំ ។
បង្កើតអំពីដើមគំនិត ភ័យភិតខ្លាចបាបបង់បានបុណ្យ


Websites: WatKhmers.org or WatKhemaraRatanaRam.org

បានបែងចែងច្បាប់ប្រាប់មហាជន ក្បួនច្បាប់ពីមុនជូនរាជការ ។

១២០- បោះពុម្ពសៀវភៅចែកសព្វសាយ បណ្ណាល័យចាត់ថ្វាយព្រះករុណា

មិនបានថ្វាយផ្ទាល់ដល់ហត្ថា សូមទ្រង់មេត្តាប្រោសប្រណី ។

ឱនកាយប្រណម្យសូមអនុញ្ញាត ក្រាបក្រោមព្រះបាទព្រះបារមី

ចែងច្បាប់បរមត្ថអត្ថបាលី សេចក្តីចែងចប់ម្ល៉េះហើយហោង ។



Websites: WatKhmers.org or WatKhemaraRatanaRam.org

# បណ្ដាំក្រមង៉ុយ

**LES RECOMMANDATION DE KRAM NGOY**

១- នេះបទព្រហ្មប្រាជ្ញប្រែ ប្រាយប្រាប់ខ្មែរទាំងប្រុសស្រី
ឱ្យប្រិតប្រុងស្មារតី គួរគប្បីឱ្យឧស្សាហ៍ ។
២- កុំខ្ជិលកុំល្ងង់ពេក ខំរៀនលេខរៀនអក្ខរា
រៀនគ្រប់សព្វធម៌អាថ៌ ប្រាជ្ញាផ្សំនឹងគំនិត ។
៣- កំណើតកើតជាមនុស្ស មើលឱ្យផ្លុះទោះឆ្ងាយជិត
ចេះស្ទាត់ប្រាកដពិត គិតការអ្វីបានគ្រប់យ៉ាង ។
៤- មនុស្សល្ងង់មិនផ្អើលភ្ញាក់ ដូចភ្នែកខ្វាក់ទាំងសងខាង
មានរូបគ្មានអ្វីអាង សាងទាបថោកកើតមកខ្លៅ ។
៥- ពូជមនុស្សទោះខ្ពស់ទាប កាត់តាមភាពត្រកូលផៅ
អាក្រក់ល្អសខ្មៅ កាត់កូនចៅដូចដូនតា ។
៦- ពូជល្ងង់មិនបានបួស ទុកជាទោសនឹងសាសនា
អ្នកបួសចេះធម៌អាថ៌ កូនសិក្សាខំរៀនសូត្រ ។
៧- ពូជខ្លៅមិនសូវប្រាជ្ញ ពូជកោងកាចមិនសូវស្លូត
ពូជត្រង់ៗរហូត ពូជភរភូតមិនផុតផៅ ។
៨- ឪពុកម្ដាយស្លូតត្រង់ ចិត្តមិនចង់ឱ្យកូនខ្លៅ
ជេរវាយស្ដីប្រដៅ ឱ្យកូនចៅបានចេះដឹង ។
៩- ឪពុកគ្មានតម្រិះ ឃើញកូនចេះមិនដែលខឹង
ឃើញកូនខំប្រិតប្រឹង ឪពុកដឹងតែងត្រេកអរ ។
១០- ដាស់តឿនក្រើនរំលឹក ជេរល្មោចព្រឹកខ្លាចកូនក្រ
ចង់ឱ្យតែកូនល្អ លោមអង្វរឱ្យកូនខំ ។



Websites: WatKhmers.org or WatKhemaraRatanaRam.org

| | |
|---|---|
| ១១- កូនកាចបំពេញទុក្ខ | ម្ដាយឪពុកមានបារម្ភ |
| កូនស្លូតដឹងគួរសម | មេបាថ្ងុំថ្កើងកេរ្តិ៍ឈ្មោះ ។ |
| ១២- ឪពុកម្ដាយខ្សត់ខ្សោយ | កុំបណ្ដោយឱ្យអាប់យស |
| ខំរៀនឱ្យបានខ្ពស់ | គ្រាន់សង្គ្រោះដល់មេបា ។ |
| ១៣- អ្នកល្ងង់ហេតុពីខ្ជិល | ឥតមន្ទិលរឿងធម៌អាថ៌ |
| គួរកូនចៅសិក្សា | រៀនអក្ខរាទាំងប្រុសស្រី ។ |
| ១៤- កាលអង្គព្រះសាស្ដា | មានថេរាមានថេរី |
| ភិក្ខុភិក្ខុនី | ធម៌បាលីចេះចាំស្ទាត់ ។ |
| ១៥- លោកសង្ឃខ្លះចេះស្ទើរ | ចេះភ្លើៗធ្វើឱ្យភ្លាត់ |
| ព្រះអង្គទ្រង់សន្មត | សិក្ខាបទដល់ឥឡូវ ។ |
| ១៦- ទម្លាប់ទំនៀមខ្មែរ | ខំធ្វើស្រែចង់បានស្រូវ |
| អ្នករៀនច្បាប់ខុសត្រូវ | ទុកជាផ្លូវភ្លឺប្រាជ្ញា ។ |
| ១៧- ស្រុកសៀមលាវបារាំង | ចេះតតាំងពីដូនតា |
| ចេះលេខចេះអក្ខរា | សរសេរចារទាំងប្រុសស្រី |
| ១៨- ជាតិខ្មែរមិនចេះខ្មាស | នាំពីចាស់គំនិតខ្លី |
| ល្ងង់ដប់ចេះពីរបី | ចេះជួញក្ដីមិនចេះច្បាប់ ។ |
| ១៩- មិនចេះលេខអក្សរ | មុខមាត់ល្អប្រាជ្ញាអប្ប |
| ឈ្មោះខ្លួនភ្នែកខ្លួនស្រាប់ | គេសូត្រប្រាប់ទើបបានដឹង ។ |
| ២០- ភ្នែកជាភ្លឺក្រឡៃត | ល្ងង់ព្រោះហេតុមិនខំប្រឹង |
| កើតទាស់មានចិត្តខឹង | ពឹងរកគេសរសេរឱ្យ ។ |
| ២១- មនុស្សក្រហេតុពីខ្ជិល | មិនរមិលមើលមុខក្រោយ |
| ម៉្យាងខ្សត់ពីព្រោះខ្សោយ | ញឹកខាងឱ្យរង្វើលរក ។ |
| ២២- ម៉្យាងក្រពីព្រោះល្ងង់ | ជួញលិចលង់មិនលៃលក |
| ទិញថ្លៃទៅលក់ថោក | ចេះតែយកមិនគិតយល់ ។ |
| ២៣- អ្នកមានៗគំនិត | ដេកដើរគិតកើតរវល់ |
| ប្រាជ្ញាជាឫសគល់ | កើតអំពល់អំពីទ្រព្យ ។ |



Websites: WatKhmers.org or WatKhemaraRatanaRam.org

២៤- អ្នកលេងនិងអ្នកចេះ
អ្នកចេះប្រសើរគាប់
បើនឹងរិះរាយរៀបរាប់
លេងឥតភ័ព្វអាប់រាសី ។

២៥- មានរូបមានជីវិត
រូបប្រុសឬកដូចស្រី
មិនចេះគិតចង់ដឹងអ្វី
នឹងហ៊ានស្ដីគ្មានគេស្ដាប់ ។

២៦- លេងម៉្យាងមានអំណាច
ឆាប់ខឹងមិនដឹងច្បាប់
លេងកោងកាចអួតចាក់កាប់
កាលណាស្លាប់គេត្រេកអរ ។

២៧- អ្នកចេះតម្រិះដល់
ចេះល្អិតចិត្តជាល្អ
អ្នកលេងឆ្ងល់មិនសល់ក្រ
ស្ទួយអាករចូលមិនខ្វះ ។

២៨- ចេះម៉្យាងមានអំណាច
គេខុសជេរជៀលត្មះ
អ្នកខ្លៅខ្លាចឱនសំពះ
អ្នកខ្លៅខ្លះគេលបខឹង ។

២៩- ប្រាជ្ញម៉្យាងចេះសព្វសុស
មិនគិតពិនិត្យថ្លឹង
ប្រព្រឹត្តខុសនោះមិនដឹង
ប្រាជ្ញប្រិតប្រឹងប្រដៅគេ ។

៣០- កូនចៅទោះធំតូច
មារយាទខ្លួនខុសគេ
ខុសខិលខូចខឹងវាយជេរ
មិនគ្មាន់គ្នេរកិរិយាឯង ។

៣១- កូនចៅទាំងស្រីប្រុស
គិតគ្រប់សព្វកន្លែង
ការត្រូវខុសគួរគិតក្រែង
តែងនឹងមានរាល់រូបកាយ ។

៣២- ភ្នែកបើកភ្លឺមែនពិត
ភ្នែកធ្មេចមើលឃើញឆ្ងាយ
មើលឃើញជិតៗរៀងអាយ
សព្វសុសសាយមិនសេសសល់ ។

៣៣- រៀនរកស៊ីលក់ទិញ
ឱ្យដឹងការកិច្ចកល
ខាតចំណេញគិតឱ្យដល់
ទើបកើតផលប្រយោជន៍ខ្លួន ។

៣៤- ឱ្យរៀនលេខនព្វន្ត
ដីសនិងក្ដារឆ្នួន
បូកហាគុណឱ្យមាំមួន
ក្រែងចិនយួនបំបាត់បាន ។

៣៥- ជញ្ជីងភ្នែកមានល្បាក់
ក្រែងខុសខាតមិនខាន
មើលឱ្យជាក់កុំប្រមាណ
ធ្លាប់រាប់អានកុំទុកចិត្ត ។

៣៦- ភ្នែកមនុស្សធំរលីង
អ្នកល្អថ្លឹងប្រឹងប្រិត
ភ្នែកជញ្ជីងគេចុចល្អិត
ព្រោះអាណិតខ្មែរល្ងង់ខ្លៅ ។



Websites: WatKhmers.org or WatKhemaraRatanaRam.org

៣៧- ចិនមានពីដូរលក់ ស្រូវកន្ទក់កន្ទាំងតៅ
របស់ទោះឆ្អិនឆៅ សំពត់អាវខោខ្មៅស ។
៣៨- ខ្មែរអាងស្រូវក្នុងដោក ដូរថ្លៃថោកអាក្រក់ល្អ
អស់ស្រូវទៅជាក្រ អង្វរចិនជឿស្រូវឯង ។
៣៩- ធ្វើស្រែនឿយហាត់ណាស់ ចិននៅផ្ទះដេកចំខែង
ផ្ទះចិនពីរបីល្វែង មានកន្លែងជង្រុកស្រូវ ។
៤០- ជាតិខ្មែរឥតគំនិត ស៊ីមិនគិតមើលខុសត្រូវ
ជឿចិនរាល់រដូវ កេរ្ត៍(*)ម៉ែឪចិនអូសអស់ ។
៤១- ចិនមកពីស្រុកនាយ មានសំពាយជារបស់
មិនទាន់ចេះខ្មែរសោះ គ្មានកេរ្ត៍(៤)កោះស្រែចំការ ។
៤២- កវែកចង្ក្រានឆ្នាំង ផ្សំកម្លាំងនិងប្រាជ្ញា
អម្រែកជិះលើស្មា មានម្ហូស្លាជាដើមទុន ។
៤៣- ទំនិញមានគ្រប់មុខ ផ្គាល់ផ្ទេរទុកដាក់ដោយធុន
ចិនរែកមិនដែលពុន ស្រូវជោរជន់ពេញជង្រុក ។
៤៤- ឈប់រែកដេកអង្គុយ រាប់កាក់លុយប្រមូលទុក
ឪទិនស្រាពីមុខ ទុកជាផ្ទាក់ទាក់កខ្មែរ ។
៤៥- ចិនច្រើនខ្លាំងចិត្តខ្មៅ កន្ទាំងតៅធ្វើជាស្រែ
គ្មានត្បាល់គ្មានអង្រែ អង្ករខ្មែរចូលបារចិន ។
៤៦- ជាតិខ្មែរច្រើនឥតខ្មាស ស្រេកស្រាណាស់ផឹកជឿសិន
គំនិតគិតមិនឆ្អិន ផឹកបង្ហិនតែទ្រព្យឯង ។
៤៧- កំណើតអ្នកផឹកស្រា បែកប្រាជ្ញាច្រើនកន្លែង
អ្នកម៉្យាងបែកខាងល្បែង មិនគិតក្រែងខ្លាចខ្លួនក្រ ។
៤៨- អាម៉្យាងបែកល្បួចឆក់ មារយាទអាក្រក់មិនបានល្អ
ផឹកចោលការរបរ ចិនទាក់កធ្វើខ្ញុំបាន ។

---

(៤) កេរ



Websites: WatKhmers.org or WatKhemaraRatanaRam.org

៤៩- មិនដឹងខ្លួនថាឆ្កួត    និយាយអួតប្រាប់សន្ដាន
ថាចិនធ្លាប់រាប់អាន    ផឹកថ្មើម៉ានចិនមិនគិត ។

៥០- ថាចិនមិនចេះកាញ់    ប្រាប់សម្លាញ់ពួកម៉ាកមិត្ត
គូកនទោះឆ្ងាយជិត    រឹតប្រមូលលុយឱ្យចិន ។

៥១- ត្រូវស្រាចង់ស៊ីឆ្ងាញ់    ធុំឆាខ្លាញ់បក់ឆ្ងួលក្លិន
ឃើញបាយសម្លឆ្អិន    ផ្ដាប់ចិត្តចិនយកបាយស៊ី ។

៥២- ផឹកទឹកបោយត្រឡោក    មារយាទទាបថោកឫកសៀធី
ចិនប្រើសែងវែកលី    ស៊ីញយៗចិនមើលងាយ ។

៥៣- ជាតិចិនកំណាញ់ស្វិត    នឹកក្នុងចិត្តមិននិយាយ
មារយាទខ្មែរច្រើនរាយមាយ    រលាយទ្រព្យអភ័ព្វខ្លួន ។

៥៤- ស៊ីឆ្ងាញ់ឆ្អែតស្កប់ស្កល់    ទាបថោកដល់ប្រពន្ធកូន
អាប់យសទាំងបងប្អូន    ដល់តាដូនពូជពង្សខ្មែរ ។

៥៥- ជាតិចិនសុទ្ធសឹងស    មានទ័លក្រខ្សត់ខ្លះដែរ
ស៊ីផឹកស្និទ្ធតាមសែ    តមបាយខ្មែរមិនស៊ីសោះ ។

៥៦- មានផ្ទះមានដំណាំ    កាប់ដីដាំដោយកៀនកោះ
ដំឡូងត្រាវចេកម្នាស់    ស៊ីមិនអស់ទុកលក់ដូរ ។

៥៧- ខ្មែរច្រើនខ្ជិលប្រមឹក    កែងកោងឫកអួតអម្បូរ
ខ្វះលុយអង្គុយថ្ងូរ    កើបបង្ហូរស្រូវជង្រុក ។

៥៨- កូនអើយរៀងដំណាំ    គួរតែដាំឱ្យគ្រប់មុខ
ដីកេរ្តិ៍(*)ម្ដាយឪពុក    មិនត្រូវទុកចោលទំនេរ ។

៥៩- រាជការវាស់មានថ្លៃ    ផ្ចិតមេដៃផ្ដាច់ជាកេរ្តិ៍(*)
មិនវាស់លេងទទេ    រេរិះយកពន្ធរាល់ឆ្នាំ ។

៦០- ដូងស្វាយអំពៅចេក    កុំខ្ជិលពេកដេកប្រចាំ



Websites: WatKhmers.org or WatKhemaraRatanaRam.org

| | | |
|---|---|---|
| | ម្លូស្លាម្រេចខ្ទឹមថ្នាំ | ត្រូវតែដាំកុំឱ្យខ្វះ |
| ៦១- | ទេសឯកសំពត់ស | ដីវាលល្អដាំកប្បាស |
| | កុំខ្ជិលតាមចាស់ៗ | មនុស្សនឿយណាស់មិនដែលក្រ ។ |
| ៦២- | បន្លែដាំគ្រប់មុខ | យកគ្រាប់ទុកដាំបន្ត |
| | ចាក់ជីជាតិល្អៗ | បង្ហារស្លពេលល្ងាចព្រឹក ។ |
| ៦៣- | ម្លូស្លាថ្នាំខ្ទឹមម្រេច | លូតលាស់លេចពីស្រោចទឹក |
| | បានផលផ្លែឬស្លឹក | កុំឆ្មើងឬកវាក្រខ្លួន ។ |
| ៦៤- | ត្រីងៀតផ្អកប្រហុក | ខ្មែរគ្រប់ស្រុកទិញដូរយួន |
| | អំបិលធ្វបក្រមួន | ពីតាដូនតែងដូរទិញ ។ |
| ៦៥- | ដូរទុកដាក់តម្កល់ | ស៊ីឱ្យដល់ខួបខែវិញ |
| | ឱ្យបរិបូណ៌ពោរពេញ | ខាតចំណេញកុំទិញតិច ។ |
| ៦៦- | អំបិលទិញមួយចុង | ច្រកពេញអុងអាងខាងលិច |
| | កុំទិញក្ដោបខ្ចប់វេច | អស់រំពេចគេចទិញទៀត ។ |
| ៦៧- | អំបិលមួយស្រូវបី | វាល់នឹងល្អីទូលកណ្ដៀត |
| | ខ្លួនក្រត្រដរឆ្លៀត | មារយាទយ៉ាងហ្នឹងកុំប្រព្រឹត្ត ។ |
| ៦៨- | កូនចៅទាំងប្រុសស្រី | គួរគប្បីប្រុងគំនិត |
| | ចិញ្ចឹមជន្មជីវិត | គិតឱ្យវែងកុំគិតខ្លី ។ |
| ៦៩- | ទំនេរល្វែធ្វើការ | ស្វត្រធម៌អាថ៌ទាំងប្រុសស្រី |
| | ឱ្យត្រឹមត្រូវបាលី | ដូចស្រដីខាងដើមស្រាប់ ។ |
| ៧០- | វាល់រូបទាំងប្រុសស្រី | កាលចេះស្ដីព្រោះចេះស្ដាប់ |
| | ម៉ែឪតម្រូវប្រាប់ | កូនចៅត្រាប់តាមដូនតា ។ |
| ៧១- | ចាស់ម៉្យាងសាងសីលទាន | មិនបំពានខុសពុទ្ធដីកា |
| | កូនកាត់តាមមេបា | មិនទៅណាឆ្ងាយពីផ្លូវ ។ |
| ៧២- | ចាស់ម៉្យាងសាងផលកម្ម | ស្អប់សីលប្រាំដូចសត្រូវ |
| | កូនកាត់តាមម៉ែឪ | អាស្រូវភាសវិនាសខ្លួន ។ |



Websites: WatKhmers.org or WatKhemaraRatanaRam.org

៧៣- មិនជឿមគ្គជឿផល ធ្លាក់ទៅដល់អបាយបួន
កងកម្មចាំគុំគួន គេចវេះពួនមិនកំបាំង ។

៧៤- ព្រះអង្គមានពុទ្ធដីកា ប្រៀបឧបមាជាទីតាំង
ដូចគោមានកម្លាំង សម្រាំងទុកទឹមរទេះ ។

៧៥- នឹងបរផ្លូវវៀចត្រង់ ឬនឹងចង់បរគេចវេះ
កង់វិលមិនរបេះ ជិះជើងគោមិនឃ្លាតឃ្លា ។

៧៦- រាល់រូបទាំងតូចធំ ចូលរូងភ្នំរូងគុហា
យកថ្មផ្ទាំងរាំងទ្វារ កម្មវេរាតោងតាមបាន ។

៧៧- កងសីលមានអង្គប្រាំ វេរាកម្មជិតដោយដាន
នរកប្រេតតិរច្ឆាន ខានឃាត់ខាំងបាំងមគ្គផល ។

៧៨- គួរខំសាងសីលទាន យកនិព្វានជាត្រើយថ្កល់
យូរឆាប់គង់តែដល់ កុសលជួយចាកសង្សារ ។

៧៩- កូនចៅរេរិះគិត មើលគំនិតចិត្តដូនតា
ប្រព្រឹត្តខុសសាសនា គេចកិរិយាកុំធ្វើត្រាប់ ។

៨០- មើលចាស់ណាត្រឹមត្រូវ ចុះក្នុងផ្លូវគន្លងច្បាប់
ចាស់ស្ដីគប្បីស្ដាប់ ប្រិតប្រៀងប្រាប់ឱ្យប្រុងចាំ ។

៨១- គោរពគុណទាំងបី សូត្របាលីតាមចំណាំ
រក្សាអង្គសីលប្រាំ កម្មវេរាតាមមិនទាន់ ។

៨២- សាសនានៅវែងឆ្ងាយ កន្លងប្លាយជាងពីរពាន់
សព្វថ្ងៃលៃគ្នេរគ្នាន់ មិនទាន់គ្រប់ជាប្រាំរយ ។

៨៣- ឥឡូវចិតប្រាំបី នៅម្ភៃមួយខាងក្រោយ
កូនចៅកុំបណ្ដោយ ឱ្យលិចលង់ក្នុងសង្សារ ។

៨៤- មានពាក្យចាស់ដំណាល ថាកណ្ដាលព្រះសាសនា
ទំនាយក្បួនតម្រា ថានឹងវៀរហើយរីកវិញ ។

៨៥- ហេតុនេះអស់កូនចៅ ទោះល្ងង់ខ្លៅយ៉ាងណាមិញ
ខំឧស្សាហ៍ទន្ទេញ បំពេញពាក្យពុទ្ធទំនាយ ។



Websites: WatKhmers.org or WatKhemaraRatanaRam.org

| | | |
|---|---|---|
| ៨៦- | តាំណពីថ្ងៃនេះ | រៀនតម្រិះកុំវាយមាយ |
| | កូនណាមិនស្វាធ្យាយ | មិនរលាយរលត់ទុក្ខ ។ |
| ៨៧- | ដល់សាសនាគ្រប់គ្រាន់ | ជួបប្រាំពាន់ទៅខាងមុខ |
| | ទំនាយរាយទំនុក | ថាឪពុកម្ដាយស្អប់កូន ។ |
| ៨៨- | ថាកើតអន្តរកប្ប | គុំសម្លាប់គ្នាបងប្អូន |
| | មិនដឹងតាដឹងដូន | សូន្យសីលទានមិនមានសល់ ។ |
| ៨៩- | គួរគិតកុំសាងកម្ម | កាន់សីលប្រាំចាំតម្កល់ |
| | ខំសាងមគ្គសាងផល | នឹងបានដល់ឋានសាន្តសុខ ។ |
| ៩០- | នឹងរួចពីកាប់ចាក់ | មិនបានធ្លាក់ទៅនរក ។ |
| | ព្រះសិអារ្យត្រាស់ខាងមុខ | រសាយទុក្ខសោករាល់ថ្ងៃ ។ |
| ៩១- | នេះហៅច្បាប់បណ្ដាំ | ជាពាក្យប្រាំៗមួយផ្ទួន |
| | បទព្រហ្មគ្រប់ឃ្លាប្អូន | ជូនថែងចប់ម្ល៉េះហើយហោង ។ |

អ្នកព្រះភិរម្យភាសា អ៊ូ ហៅ ង៉ុយ



Websites: WatKhmers.org or WatKhemaraRatanaRam.org

# ជីវប្រវត្តិ

## អ្នកព្រះភិរម្យភាសា អ៊ូ ហៅ ង៉ុយ
## (១៨៦៥-១៩៣៦)

អ្នកព្រះភិរម្យភាសាអ៊ូ, ឈ្មោះពេញ អ៊ុក អ៊ូ ហៅ ង៉ុយ កើតនៅ គ.ស. ១៨៦៥ ( ព.ស. ២៤០៨ ) នៅភូមិព្រៃអណ្តូងស្វាយ ឃុំកំបូល ស្រុកភ្នំពេញ, ខេត្តកណ្តាល ។

- បិតាលោកនាម អ៊ុក ធ្វើមេឃុំកំបូល មានគោរម្យងារ ជា «ចៅពញាធម្មធារា» ។ ចៅពញាអ៊ុក ជាប់ជាសាច់ញាតិនឹងម្ចាស់អង្គប៉ុក ។

- មាតាលោកនាម អៀង ជាបុត្ររបស់ចៅពញា ម៉ុក មេឃុំស្ពានថ្ម ស្រុកខេត្តជាមួយគ្នា ។ មាតានិងបិតាលោក ត្រូវជាបងប្អូនជីដូនមួយនឹងគ្នា។ លោកជាកូនទីពីរ នៅក្នុងគ្រួសារ ។

កាលពីនៅវ័យកុមារ លោកបានរៀនសូត្រលេខនព្វន្ត អក្សរសាស្ត្រ នៅវត្តអង្គបឹងចក ភូមិបែកស្គរ ឃុំបែកចាន ក្នុងស្រុកកំណើតរបស់លោក ។ កុមារ អ៊ុក អ៊ូ ជាក្មេងម្នាក់ឧស្សាហ៍រៀនសូត្រ ។ លោកបានបួសជាសាមណេរនៅក្នុងវត្តនោះ ។ ប៉ុន្មានឆ្នាំក្រោយមក លោកបានលាចាកសិក្ខាបទទៅបម្រើមាតាបិតា ហើយបានធ្វើជាស្មៀន របស់ឪពុកលោកក្នុងការដើរហូតពន្ធស្រូវអាជ្ញាហ្លួង ។ លុះអាយុបាន ២១ ឆ្នាំ លោកបានបំពេញឧបសម្បទាជាភិក្ខុ នៅក្នុងវត្តដដែល ដោយមានព្រះឧបជ្ឈាយ៍ នាម សាស់ និងលោកគ្រូសូត្រស្តាំនាម ជ្រូក ជាកម្មវាចា, លោកគ្រូសូត្រឆ្វេងនាម អ៊ុង ជាអនុស្សាវនៈ ។ ភិក្ខុ អ៊ូ បានរៀនសូត្រធមិ



Websites: WatKhmers.org or WatKhemaraRatanaRam.org

អាជិ និងរៀនប្រែព្រះត្រៃបិដកដំបូង ក្នុងសំណាក់លោកគ្រូអាចារ្យ « ទិត្យ » នៅវត្តអង្គបឹងចក ។ បន្ទាប់មក លោកបានស្វែងរករៀនវិបស្សនាកម្មដ្ឋាន ក្នុងសំណាក់លោកអាចារ្យជាច្រើនកន្លែងទៀត ។ លោកបានគង់នៅក្នុងផ្នួសជា ភិក្ខុបាន ៩ ឆ្នាំ ។ លុះចេះដឹងល្មមប្រើការបានហើយ លោកបានលាចាក សិក្ខាបទមកប្រកបជីវភាពជាគ្រហស្ថវិញ ។ ក្រោយពេលលោកចាកផ្នួស មក លោកបានជួយធ្វើការឪពុករបស់លោកដែលជាមេឃុំដោយមានងារជាក្រមជង ជាស្មៀនផង។ ដល់ពេលស្រុកភ័ន្តប្រែលោកលាឈប់លែងធ្វើការរាជការ ហើយរស់នៅជាកសិករធម្មតា ។

លោកជាអ្នកមានវោហារលែបខាយ ប្រាជ្ញាវាងវៃ ចេះចាំរឿងរ៉ាវពីបុរាណៗ ទាំងគតិលោក ទាំងគតិធម៌ជាច្រើន ព្រមទាំងចេះច្រៀង ចេះភ្លេង និងជាអ្នកចម្រៀងខ្សែដៀវយ៉ាងចំណានធ្វើឱ្យកសិករឯទៀត ស្រឡាញ់រាប់អាន ទុកលោកជាអ្នកប្រាជ្ញក្នុងភូមិស្រុកហើយគេនិយមហៅលោកថា « ភិរម្យង៉ុយ » ។ លោកភិរម្យង៉ុយ មានមាឌធំ ដុះក្បាលពោះកាត់សក់ជ្រងខ្លី ទុកពុកមាត់ខាងលើនិយមស្លៀកសំពត់ចងក្បិន ពាក់អាវកត្រង់ ឡេវធំ ពាក់ស្បែកជើងផ្ទាត់ និងមួកសំបុក ។ ពេលដើរទៅណាមកណា លោកមានបង្វិច និងឈើច្រត់កាន់ជានិច្ច ។ ពេលលោកសូត្រកំណាព្យ លោកតែងដេញខ្សែដៀវកំដរ ។ ខ្សែដៀវរបស់គាត់អាចដោះចេញពីគ្នា ហើយតម្លើងបានភ្លាមៗ កាលណាគាត់ត្រូវការប្រើ ។ ពេលណា លោកត្រូវការច្រៀង លោកស្រាយបង្វិចយកឃ្លោកសាដៀវមកផ្គុំនឹងឈើច្រត់ បានជាដងជាផ្លែ ហើយដាក់ខ្សែ រួចផ្ទាប់នឹងពោះធ្វើជីតប៉ោងៗ ហើយដេញយ៉ាងពីរោះ ។



Websites: WatKhmers.org or WatKhemaraRatanaRam.org

ពេលរដូវរំហើយក្រោយពីការងារស្រែចំការបានចប់សព្វគ្រប់លោកតែងត្រូវបានប្រជាជនអញ្ជើញឱ្យទៅច្រៀងឬទេសនាក្នុងពេលមានបុណ្យទាន ពីភូមិមួយទៅភូមិមួយ។លោកមិនបានទារប្រាក់កម្រៃឈ្នួលពីប្រជាជនទេ ប៉ុន្តែដោយសេចក្តីគោរពស្រឡាញ់ប្រជាជនតែងប្រមូលបច្ច័យ ស្រូវអង្ករជូនលោកតាមសទ្ធា។ពេលធ្វើដំណើរឆ្លងកាត់ក្រុងភ្នំពេញ លោកតែងឈប់សំចតនៅវត្តឧណ្ណាលោមហើយឆ្លៀតពេលនោះដើម្បីពិគ្រោះពិភាក្សាជាមួយសាមណេរ, ភិក្ខុសង្ឃ អំពីបញ្ហាផ្សេងៗដែលទាក់ទងនឹងព្រះពុទ្ធសាសនា ។

ក្នុងការច្រៀងក្តី ទេសនាក្តី លោកតែងលើកយកបញ្ហាដែលជាបច្ចុប្បន្នភាពក្នុងពេលនោះ មកធ្វើជាប្រធានបទ ដូចជាច្រៀង ៖

- អំពីការប្រកបមុខរបររកស៊ីធ្វើស្រែចំការ,
- អំពីការជ្រើសរើសគូស្រករ,
- អំពីភាពក្រីក្រតោកយ៉ាករបស់ប្រជាជន និងមូលហេតុរបស់វា,
- អំពីអវិជ្ជា អនក្ខរភាព របស់ប្រជាជនខ្មែរ,
- អំពីភាពស្ពឹកស្រពន់ មិនសកម្ម ស្វាហាប់ខាងធ្វើពលកម្មដាំដុះ,
- អំពីការបែកបាក់សាមគ្គី ឈ្លោះទាស់ទែងតែគ្នាឯងទាំង គ្រហស្ថ ទាំងអ្នកបួស,
- អំពីការជិះជាន់សង្កត់សង្កិនរបស់បរទេស មកលើប្រជាជនខ្មែរ,
- អំពីការបាត់បង់ឯករាជ្យ និងអត្តភាពខ្មែរ,
- អំពីការរេចរឹលនៃវប្បធម៌ អក្សរសាស្ត្រខ្មែរ ។ ល ។



Websites: WatKhmers.org or WatKhemaraRatanaRam.org

កិត្តិស័ព្ទល្បីល្បាញខាងសំនួនវោហាររបស់កវី អ៊ូ នេះ បានឮខ្ចរខ្ចាយទៅដល់ព្រះមហាក្សត្រ ។

ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះស៊ីសុវត្ថិ បានត្រាស់ហៅលោក ឱ្យចូលគាល់ និងច្រៀងថ្វាយ ។ ហ្លួងព្រះស៊ីសុវត្ថិ ពេញព្រះទ័យនឹងថ្វីមាត់របស់លោកណាស់ ទើបអនុញ្ញាតឱ្យលោកចូលបម្រើក្នុងក្រុមភ្លេងព្រះបរមរាជវាំង ហើយប្រទានងារជា « អ្នកព្រះភិរម្យភាសាអ៊ូ » ប៉ុន្តែ ដោយនៅពេលនោះ មាននាយក្រុមវាំងម្នាក់ឈ្មោះអ៊ូ ដែរនោះ ទើបហ្លួងព្រះស៊ីសុវត្ថិ ទ្រង់ត្រាស់ឱ្យហៅថា « ង៉ុយ » វិញ ដើម្បីកុំឱ្យច្រឡំគ្នា ។ ដូច្នេះបានជាលោកមានឈ្មោះ១ទៀតថា « ង៉ុយ » ឬ ក្រមង៉ុយរៀងដរាបមក ។

កិត្តិស័ព្ទរបស់អ្នកព្រះភិរម្យភាសាអ៊ូ មិនគ្រាន់តែល្បីរន្ទឺ នៅក្នុងប្រទេសទេប៉ុន្តែ បានសាយភាយទៅដល់ប្រទេសថៃ ថែមទៀត ។ ស្តេចសៀម ក្រុមព្រះទំរង់រាជានុភាព និងលោកសឺដេស ជាតិបារាំង បានចូលគាល់ហ្លួងព្រះស៊ីសុវត្ថិ ។ ពេលប្រគំភ្លេងទទួលភ្ញៀវបរទេសនោះ អ្នកព្រះភិរម្យភាសាអ៊ូ ហៅ ង៉ុយ ប្រគំឈ្នះគេខាងខ្សែដៀវ ។ កិត្តិស័ព្ទរបស់លោកបានផ្សាយដល់ស្រុកសៀម ។ ស្តេចសៀមបានធ្វើរាជសារមកសុំអញ្ជើញអ្នកព្រះភិរម្យភាសាង៉ុយ ទៅច្រៀងថ្វាយឯក្រុងបាងកក ។ លោកបានធ្វើដំណើរទៅនៅស្រុកសៀម អស់រយៈពេល ៣ ខែ ហើយបានទទួលសេចក្តីរាប់អានពីសំណាក់ព្រះមហាក្សត្រ និងមន្ត្រីសៀម ។ ពេលនោះស្តេចសៀមបានប្រទានងារជាភិរម្យភាសា « ដៃរ៉ោះលឿកឹន » និងប្រទាន ឡេវអាវប្រាក់ខ្លួង ព្រមទាំងប្រាក់ និងវត្ថុផ្សេងៗទៀតជាច្រើន ។ មាន



Websites: WatKhmers.org or WatKhemaraRatanaRam.org

ដំណាលថា ក្នុងពេលធ្វើដំណើរត្រឡប់ពីប្រទេសសៀមវិញ លោកបានឆ្លងកាត់តាមខេត្តបាត់ដំបង ។ ពេលនោះ នៅខេត្តបាត់ដំបង មានអ្នកចម្រៀងមាត់ឯកម្នាក់ ឈ្មោះភិរម្យយូ ។ ដោយឮល្បីថា អ្នកព្រះភិរម្យភាសាអ៊ូ ពូកែច្រៀង លោកភិរម្យយូ ក៏មកសុំច្រៀងភ្នាល់ ។ ភិរម្យយូបានសួរព្រះភិរម្យង៉ុយថា « ភ្នំព្រះសុមេរុនៅឯណា? មានទំហំប៉ុណ្ណា? កំពស់ប៉ុន្មានយោជន៍? ពីនេះទៅ បើសិនជាវាស់ តើមានប៉ុន្មានគីឡូម៉ែត្រ ? » ។ ព្រះភិរម្យង៉ុយឆ្លើយថា « បើលោកចូលយ៉ាងនេះ តើលោកចង់ឱ្យខ្ញុំឆ្លើយត្រង់ ឬឱ្យឆ្លើយកុហក ? » ។ ភិរម្យយូថា បើសួរត្រង់ ត្រូវតែឆ្លើយឱ្យត្រង់ ។ ភិរម្យង៉ុយ ក៏ឆ្លើយកែដោះសារថា មានប៉ុណ្ណោះគីឡូប៉ុណ្ណោះម៉ែត្រ ហើយបើគិតពីបាត់ដំបងទៅ មានចម្ងាយផ្លូវប៉ុណ្ណោះទៀត បើភិរម្យយូ មិនជឿត្រូវទៅមើលចុះ ។ ភិរម្យយូ ព្រមទទួលជឿ ហើយភិរម្យង៉ុយ ក៏សួរវិញថា « តើពីផ្សារបាត់ដំបង ទៅភ្នំពេញ បើទៅតាមថ្នល់ តើមានប៉ុន្មានគីឡូ? បើទៅតាមទន្លេសាបវិញតើមានប៉ុន្មានគីឡូ ? » ភិរម្យយូ ក៏ទាល់ឆ្លើយមិនរួច ហើយភិរម្យង៉ុយច្រៀងបង្អាប់ភិរម្យយូ យ៉ាងច្រើនថា កន្លែងធ្លាប់ទៅមក ហើយជាប្រទេសរបស់ខ្លួនឯង ភិរម្យយូមិនដឹងទៅហើយ ទៅសង្ស័យសួរកន្លែងមិនដែលទៅ បើទោះជាខ្ញុំកុហក ក៏ត្រូវតែជឿខ្ញុំដែរ ។ ភិរម្យង៉ុយបង្អាប់ទាល់តែភិរម្យយូទាល់ ចុះពីកន្លែងច្រៀង ហើយប្រជាជនអ្នកស្តាប់ទះដៃសរសើរភិរម្យង៉ុយយ៉ាងខ្លាំង ។ លោកប្រមុខខេត្តបាត់ដំបង បានគល់រង្វាន់នៃជ័យជំនះដល់ភិរម្យង៉ុយ គឺសេះស ១ ក្បាល និងប្រាក់សុទ្ធ ៤០០រៀលទៀត ។ ដូច្នេះហើយបានជា អ្នកចម្រៀងនានា មានការញញើតលោកណាស់ មិនសូវមាននរណាហ៊ានច្រៀងតាំងនឹងថ្វីមាត់លោកឡើយមានតែជំទប់ សាន់ នៅឃុំភ្លើងឆេះរទេះ ស្រុក



Websites: WatKhmers.org or WatKhemaraRatanaRam.org

ភ្នំពេញ ដែលជាមិត្តភក្តិនិងជាដៃគូ របស់គាត់ម្នាក់ប៉ុណ្ណោះ ទើបអាចតបតនឹងលោកបាន ។ ពេលអ្នកចម្រៀងទាំងពីរនេះ ទៅច្រៀងនៅកន្លែងណា មនុស្សម្នាប្រុសស្រីនៅភូមិស្រុកឆ្ងាយៗ បានភ្លូកទៅស្តាប់ជាច្រើន ។

នៅពេលក្រោយមកទៀត លោក សឺដេស បាននាំព្រះភិរម្យភាសាអ៊ូ ទៅជួបលោកស្រី ស៊ុយហ្សាន កាប៉ុឡែស (Suzanne Karpeles) ដែលជានាយវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ នៅភ្នំពេញ ។ នៅឆ្នាំ ១៩៣០ អ្នកស្រីនាយក សុំឱ្យអ្នកព្រះភិរម្យភាសាច្រៀងកំណាព្យរបស់គាត់ឡើងវិញទាំងអស់ បែបរង្វើលៗ ដើម្បីឱ្យអ្នកប្រាជ្ញនៅវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យកត់ត្រាទុក។ ជារង្វាន់នៅពេលនោះ អ្នកស្រី ស៊ុយសាន បានឱ្យលោក នូវប្រាក់ ១ រៀល ជានិមិត្តរូបនៃការស្រឡាញ់វប្បធម៌អរិយធម៌ខ្មែរ ។ ដោយចង់រក្សាទុកស្នាដៃនេះឱ្យបានយូរអង្វែងសម្រាប់មនុស្សជំនាន់ ក្រោយពុទ្ធសាសនបណ្ឌិត្យបានចាត់ចែងបោះពុម្ពស្នាដៃរបស់លោកជាប្អូនច្បាប់ ហើយក្រោយមកបានបោះបញ្ចូលគ្នាជាមួយច្បាប់វិញ។

តាមពិត ស្នាដៃរបស់លោកមានច្រើន ប៉ុន្តែគេមិនបានកត់ត្រាព្រោះលោកតាង៉ុយ ជាកវីដែលបង្កើតស្នាដៃដោយច្រៀងផ្ទាល់មាត់ ។

ស្នាដៃរបស់លោក ដែលយើងរកឃើញរហូតដល់សព្វថ្ងៃ មាន៥ គឺ ៖

១- ច្បាប់ល្បើកថ្មី « បទកាកគតិ » ( ឆ្នាំ ១៩២២ ),

២- ច្បាប់កេរកាលថ្មី « បទព្រហ្មគីតិ » ( ឆ្នាំ ១៩២២ ),

៣- សេចក្តីរំលឹកដាស់តឿន « បទពាក្យ ៧ » ( ឆ្នាំ ១៩៣១ ),



Websites: WatKhmers.org or WatKhemaraRatanaRam.org

៤- ពាក្យកាព្យប្រដៅជនប្រុសស្រី « បទពាក្យ ៧ » ( មិនដឹងកាលបរិច្ឆេទ ), អាចក្នុងឆ្នាំ១៩៣៥ព្រោះជាស្នាដៃទី ៥ ។

៥- បណ្ដាំក្រមង៉ុយ « បទព្រហ្មគីតិ » ( ក្នុងរវាងឆ្នាំ១៩៣៥ ) ។

ក្រៅពីស្នាដៃខាងលើនេះ នៅមានស្នាដៃផ្សេងទៀត ដែលគេរកមិនឃើញឯកសារសរសេរ ហើយដែលអ្នកស្រាវជ្រាវពីមុនៗ បានចាត់ទុកថាជាស្នាដៃរបស់អ្នកភិរម្យភាសាអ៊ូ ដែរ គឺចម្រៀងស្ដីអំពី ៖

- ការប្រែប្រួលនៃស្រុកទេស,
- កតញ្ញូកតវេទី,
- ត្រៃលក្ខណ៍
- ចម្រៀងស្រី-ប្រុស...

អ្នកភិរម្យភាសាអ៊ូ មានភរិយាឈ្មោះ អ៊ិន ។ លោកមានបុត្រចំនួន ៦ នាក់ សុទ្ធតែប្រុស គឺ ៖

១- ឈ្មោះ ដួង

២- ឈ្មោះ ចេង

៣- ឈ្មោះ ចា

៤- ឈ្មោះ ចិន

៥- ឈ្មោះ ចុង

៦- ឈ្មោះ ចេវ

ក្នុងចំណោមកូនគាត់ទាំង ៦ នាក់ មានម្នាក់ដែលមានទេពកោសល្យខាងសំនួនវោហារ ប្រហាក់ប្រហែលគាត់នោះគឺ កូនទី ៥ ដែលគេនិយមហៅថាអា



Websites: WatKhmers.org or WatKhemaraRatanaRam.org

ចារ្យ ចុង ។ មានព័ត៌មានខ្លះទៀតថា គាត់នៅមានចៅម្នាក់ទៀត ដែលមានវោហារល្បីខាងច្រៀងអាយ៉ៃដែរ ហើយមានរូបរាងស្គមស្តើង ដែលគេធ្លាប់ឮឈ្មោះថា នាយស្លឹក ។ នៅពេលច្រៀងអាយ៉ៃ នាយស្លឹក តែងបង្ហាញខ្លួនគាត់ថា « ស្រុកខ្ញុំនៅឯលិចពោធិចិនតុង កូនអាចារ្យចុងចៅអាចារ្យង៉ុយ » ។

អ្នកព្រះភិរម្យភាសាអ៊ូ បានទទួលអនិច្ចកម្ម នៅថ្ងៃសុក្រ ៦ កើត ខែមិគសិរ ព.ស. ២៤៧៩ គ.ស. ១៩៣៦ ក្នុងជន្មាយុ ៧១ ឆ្នាំ ដោយជំងឺទល់លាមក ។



Websites: WatKhmers.org or WatKhemaraRatanaRam.org

# សង្គមបរិយាកាសនៅកម្ពុជា

(ពីឆ្នាំ ១៨៦៥ ដល់ឆ្នាំ ១៩៣៦)

នៅរយៈពេលជាង ៧០ ឆ្នាំនេះ នៅប្រទេសកម្ពុជា គេឃើញមានព្រឹត្តិការណ៍សំខាន់ៗជាច្រើន ដែលធ្វើឱ្យមានវិបរិតទូទាំងប្រទេស ទាក់ទងដល់គ្រប់វិស័យរបស់សង្គម និងប៉ះពាល់ដល់ភាពរស់នៅរបស់ប្រជាជនខ្មែរ ទូទាំងប្រទេស ។

ប្រជាជនកម្ពុជា បាត់បង់សិទ្ធិសេរីភាព និងអ្វីៗដែលខ្លួនធ្លាប់មានពីមុនៗមក ក្នុងឋានៈជាម្ចាស់ប្រទេស ចាប់ពីឆ្នាំវក គ.ស. ១៨៨៤[៥] គឺក្នុងពេលដែលពួកអាណានិគមបារាំង បានប្រើអំណាចរំលោភទាំងកំរោលមកលើអធិបតេយ្យភាពរបស់ប្រទេសកម្ពុជា ដោយលែងទទួលស្គាល់កម្ពុជាក្នុងលក្ខណៈជាប្រទេសស្ថិតក្នុងអាណាព្យាបាលរបស់ខ្លួន ។ ផ្ទុយទៅវិញបារាំងបានចាប់យកកម្ពុជា ធ្វើជាប្រទេសអាណានិគមរបស់ខ្លួនតែម្តង ។

ចាប់តាំងពីពេលនោះ គេឃើញមានការ សើរើរៀបចំប្រទេសឡើងវិញនៅគ្រប់វិស័យ ទៅតាមប្រព័ន្ធគ្រប់គ្រងបារាំង ទាំងខាងរដ្ឋបាលទាំងខាងសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ អប់រំសិក្សាធិការ ដូចជា:

- មានការតែងតាំងមន្ត្រីភាគច្រើន ជាជនបរទេស ក្នុងអង្គការរដ្ឋបាលឱ្យត្រួតត្រាប្រទេសខ្មែរ,

---

៥- នៅក្នុងសៀវភៅឈ្មោះ « រាជាធិបតេយ្យកម្ពុជា និងព្រះរាជបូជនីយកិច្ចដើម្បីឯករាជ្យ ( La Monarchie Cambodgienne et la Croisade Rayale pour l'Independance »

សម្តេចព្រះនរោត្តមសីហនុ បានរៀបរាប់យ៉ាងពិស្តារ អំពីខ្លឹមសារអនុសញ្ញា ឆ្នាំ ១៨៨៤ ( ទំព័រ ៥៣ និងបន្តបន្ទាប់ ) ។ ឯកសារមហាបុរសខ្មែរ របស់លោក អេង សុត, ត្រង់រជ្ជកាលព្រះនរោត្តម ភាគខាងចុង ។



Websites: WatKhmers.org or WatKhemaraRatanaRam.org

- មានការវាស់វែងបែងចែកដីធ្លី និងប្រគល់កម្មសិទ្ធិ ឱ្យប្រជាជនដើម្បីងាយដកហូតពន្ធដារ, មានការបោះពុម្ពក្រដាស់ប្រាក់ថ្មីជំនួសប្រាក់សុទ្ធ[៦] ប្រមូលទ្រព្យសម្បត្តិឃ្លាំងព្រះរាជទ្រព្យ យកទៅដាក់រតនាគាររួមហៅថា Tresor unique du Royaume[៧] ការផ្សព្វផ្សាយវប្បធម៌ និង អរិយធម៌លោកខាងលិច នៅក្នុងប្រទេស រាប់តាំងពីអក្សរ ភាសា សីលធម៌ រស់នៅ សម្លៀកបំពាក់សិល្បៈ ភ្លេង របាំ រាំ ច្រៀង ។ល។
- ម៉្យាងទៀត នៅក្នុងឆ្នាំ ១៩១៤ - ១៩១៨ សង្គ្រាមលោកលើកទី១ បានផ្ទុះឡើងនៅប្រទេសអឺរ៉ុប ។ ពិតមែនតែសង្គ្រាមនោះ មិនកើតឡើងលើទឹកដីរបស់យើង ប៉ុន្តែផលវិបាករបស់សង្គ្រាមនេះ បានប៉ះពាល់យ៉ាងធ្ងន់ធ្ងរមកលើប្រជាជនកម្ពុជា។ដោយសារប្រទេសកម្ពុជា ជាប្រទេសអាណានិគមរបស់បារាំង ដូច្នេះឈាមខ្មែរក៏កំពប់ខ្ចាយដោយសារបារាំងធ្វើសង្គ្រាមនៅអឺរ៉ុបដែរ ។ ពេលនោះ បារាំងបានចាប់ប្រជាជន

---

៦- នៅមុនសតវត្សទី ១៨ ការផ្លាស់ប្តូរទំនិញសំខាន់ៗ ក្នុងការលក់ដូរក្នុងស្រុក និងក្រៅប្រទេស គេធ្វើឱ្យមានការផ្លាស់ប្តូរទៅវិញទៅមក ដោយយកទំនិញប្តូរនឹងទំនិញ យកមាសទៅប្តូរក៏មាន (សៀវភៅ Le Cambodge បោះពុម្ពផ្សាយដោយក្រសួងឃោសនាការនៃរាជរដ្ឋាភិបាលកម្ពុជា ភ្នំពេញ, ឆ្នាំ ១៩៦២ ),

-កំណត់ហេតុ ស្តីអំពីទំនៀមទម្លាប់របស់ប្រទេសកម្ពុជា, របស់ ចូវតាក្វាន់( Mémoires sur les coutumes du Cambodge deTchrien - Maison- neuvre Paris 1951 ), សិលាចារឹកស្តុកកក់ធំ, ឯកសារមហាបុរស។

លុះមកដល់ឆ្នាំ ១៥៩៥ ក្នុងរជ្ជកាលព្រះសត្ថាទីមួយ គេបានរកឃើញមានប្រាក់ដែលបោះចាយលើកដំបូង ។ រហូតមកដល់រជ្ជកាលព្រះអង្គឌួងទើបមានការបោះប្រាក់ចាយសាជាថ្មី ក្នុងរវាងឆ្នាំ ១៨៤៧ ត្រង់រជ្ជកាលព្រះអង្គឌួង ។

-សៀវភៅ La Monarchie Cambodgienne និងសៀវភៅ Le Cambodge ដូចបញ្ជាក់ខាងលើ ។

៧- បារាំងបានប្រមូលសម្បត្តិព្រះរាជទ្រព្យ យកទៅដាក់រតនាគាររួម នៅក្នុងឆ្នាំ ១៨៩១ ( សូមអានឯកសារមហាបុរសខ្មែរ ) ។



Websites: WatKhmers.org or WatKhemaraRatanaRam.org

ខ្មែរបុរសៗ ឱ្យធ្វើទាហាន ហើយមួយចំនួនធំត្រូវបានចាត់បញ្ជូនឱ្យទៅជួយច្បាំងបារាំង ។

- ទាហានមួយចំនួនបានពលីនៅលើសមរភូមិ ដោយឥតមានស្គាល់ឈ្មោះ និងស្រុកកំណើតរបស់គេឡើយ[៨] ។

ប្រជាជនកម្ពុជាដែលនៅក្នុងស្រុក ត្រូវទទួលរងទុក្ខវេទនា ដោយសារការហ៊ុំព័ទ្ធសេដ្ឋកិច្ចពីខាងក្រៅ ដោយសារគ្រោះធម្មជាតិ ( ទឹកជំនន់និងរាំងស្ងួត )បណ្តាលឱ្យមានទុរ្ភិក្សជាទូទៅពេញប្រទេស ។ ជំងឺតម្កាត់កើតឡើង ហើយឆ្លងរាលដាលយ៉ាងរហ័ស ដោយសារខ្វះថ្នាំសង្កូវ ។ រីឯពួកអាណានិគមវិញ គិតតែជំរិតទារពន្ធដារលើមនុស្ស សត្វ និងឧបករណ៍សម្ភារៈសព្វសារពើ ដើម្បីយកទៅចំណាយក្នុងសង្គ្រាម និងដើម្បីស្តារប្រទេសរបស់គេឡើងវិញ ក្រោយពេលសង្គ្រាមបានចប់ទៅវិញ ។ ការប្រមូលពន្ធដារលើទំនិញ និងការហ៊ុំព័ទ្ធសេដ្ឋកិច្ច និងការខកខានមិនបានផលិត បណ្តាលមកពីគ្រោះរាំងស្ងួត នាំឱ្យមានអតិផរណាទំនិញសព្វសារពើចេះតែឡើងថ្លៃរៀងរាល់ថ្ងៃ ។ ទន្ទឹមនឹងព្រឹត្តិការណ៍ខាងលើនេះ ពួកឈ្មួញបរទេស និងអ្នកប្រកបមុខរបរលក់ដូរ ឆ្លៀតឱកាសកេងប្រវ័ញ្ច គៃបន្លំយកចំណេញ ដើម្បីធ្វើមានបានពីលើខ្នងប្រជាជនខ្មែរ ដែលភាគច្រើនជាកសិករមិនសូវបានរៀនសូត្រ ទាំងខាងអក្សរសាស្ត្រ ទាំងខាងលេខនព្វន្ត ។

ប្រមូលចងក្រងពត៏មានដោយ យី ធន់

---

[៨]-កាលពីមុនឆ្នាំ ១៩៧៥ គេឃើញមានរូបសំណាកធ្វើអំពីស្ពាន់យ៉ាងធំតម្កល់កណ្តាលសួន នៅខាងកើតស្ថានទូតបារាំង ត្រង់មុំវត្តបិនដំដែក ដែលគេនិយមហៅថា រូបពីរ ។ រូបសំណាកនោះ បារាំងបានកសាងដើម្បីឧទ្ទិសបំពោះទាហានបារាំង និងខ្មែរ ដែលបានពលីជីវិតក្នុងការជួយច្បាំងបារាំង ។ ក្រោយឆ្នាំ ១៩៧៥ ក្នុងពេកដែលខ្មែរក្រហមឡើងកាន់អំណាច រូបសំណាកនេះ ត្រូវបានគេកំទេចបោលទាំងស្រុង ។



Websites: WatKhmers.org or WatKhemaraRatanaRam.org

# ទំព័រទទេ

Websites: WatKhmers.org or WatKhemaraRatanaRam.org

# បណ្តាំក្រមង៉ុយ



បោះពុម្ពផ្សាយដោយអង្គការសន្តិស្ម័គ្រចិត្តកម្ពុជា ( អេស វី អេ )

ភ្នំពេញ

ព.ស ២៥៤៩ - គ.ស ២០០៥

Websites: WatKhmers.org or WatKhemaraRatanaRam.org